# វេទិកាគោលនយោបាយ ថ្នាក់ជាតិរបស់កម្មវិធី ពន្លកចំណេះ ឆ្នាំ២០២៥




Australian Aid

PONLOK CHOMNES

The Asia Foundation

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** *i*

**អំពីកម្មវិធីពន្លកចំណេះ** *ii*

**អំពីអង្គការមូលនិធិអាស៊ី** *ii*

**ក្រុមការងារ** *iii*

**អំណះអំណាង** *iii*

**ទិដ្ឋភាពរួមនៃវេទិកាគោលនយោបាយថ្នាក់ជាតិនៃកម្មវិធីពន្លកចំណេះ ឆ្នាំ២០២៥** *v*

**សេចក្តីផ្តើម** *១*

**សុន្ទរកថាស្វាគមន៍** *៥*

**សុន្ទរកថាបើកកម្មវិធី** *៩*

**សុន្ទរកថាគន្លឹះ** *១៥*

**កិច្ចពិភាក្សាពេញអង្គ៖** តួនាទី និងអនាគតនៃវិស័យស្រាវជ្រាវកម្ពុជានៅក្នុងការពង្រឹងដំណើរការគោលនយោបាយប្រកបដោយបរិយាបន្ន *២៦*

**ការពិភាក្សាស្របពេលគ្នា ១ក៖** ការរួមបញ្ចូលការធ្វើចំណាកស្រុកដែលបណ្តាលមកពីអាកាសធាតុ និងកិច្ចគាំពារសង្គមទៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ *៣២*

**ការពិភាក្សាស្របពេលគ្នា ១ខ៖** ការអភិវឌ្ឍជនបទ ប្រកបដោយបរិយាបន្ន៖ ការចូលរួមរបស់សហគមន៍ និងក្រុមសង្គមក្នុងការធ្វើផែនការនិងលទ្ធផលនៃវិនិយោគក្នុងស្រុក ដើម្បីជួយដល់តម្រូវការរបស់ក្រុមសង្គមនៅក្នុងបរិបទប្រែប្រួលអាកាសធាតុ *៤២*

**ការពិភាក្សាស្របពេលគ្នា ២ក៖** វិទ្យាសាស្ត្រមនុស្ស និងវិទ្យាសាស្ត្រសង្គម ក្នុងទិដ្ឋភាពស្រាវជ្រាវដែលកំពុងលូតលាស់នៅកម្ពុជា ៥០

**ការពិភាក្សាស្របពេលគ្នា ២ខ៖ បទបង្ហាញខ្លី៖** គំនិតគោលនយោបាយតូចសម្រាប់អនាគតរបស់កម្ពុជា ៥៦

**សុន្ទរកថាពេញអង្គ** ៦២

**ពិធីប្រគល់ពានរង្វាន់បរិយាបន្ន៖** ចំណាប់អារម្មណ៍របស់ជ័យលាភី ៦៨

**សុន្ទរកថាបិទកម្មវិធី** ៧៣

**សេចក្ដីសន្និដ្ឋាន** ៧៦

**ឧបសម្ព័ន្ធទី១៖** វាគ្មិន វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល ៧៨

**ឧបសម្ព័ន្ធទី ២៖** របៀបវារៈ ៩៦

**ឧបសម្ព័ន្ធទី ៣៖** ការផ្សព្វផ្សាយព័ត៌មាន ១០២

**ឧបសម្ព័ន្ធទី៤៖** ក្រុមការងារតាក់តែងសៀវភៅណែនាំស្ដីពីការស្រាវជ្រាវ និងគោលការណ៍ណែនាំស្ដីពីការពិភាក្សាប្រកបដោយបរិយាបន្នរបស់កម្មវិធីពន្លកចំណេះ ១០៤

# សេចក្តីថ្លែងអំណរគុណ

អង្គការមូលនិធិអាស៊ី (The Asia Foundation) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គល អង្គការ និងម្ចាស់ជំនួយជាច្រើន ដែលបានរួមចំណែកធ្វើឱ្យវេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៥ នេះអាចប្រព្រឹត្តទៅបាន។

អង្គការមូលនិធិអាស៊ី សូមថ្លែងអំណរគុណចំពោះដៃគូយុទ្ធសាស្ត្រ ដៃគូ នវានុវត្តន៍ និងក្រុមជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI Consortium) សម្រាប់ការផ្តល់ធាតុចូល និងកិច្ចសហការក្នុងការរៀបចំកិច្ចពិភាក្សាពេញអង្គ។ យើងខ្ញុំក៏សូមអរគុណដល់វាគ្មិនកិត្តិយស និង អ្នកសម្របសម្រួលសម្រាប់ការចែករំលែកចំណេះដឹង ក្នុងអំឡុងកិច្ចពិភាក្សា និងសូមអរគុណចំពោះរដ្ឋាភិបាលអូស្ត្រាលី សម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុ។

ជាចុងក្រោយ អង្គការមូលនិធិអាស៊ី សូមសម្តែងក្តីអំណរគុណ និងការកោតសរសើរយ៉ាងស្មោះស្ម័គ្រ ចំពោះអ្នកតំណាងមកពីរាជរដ្ឋាភិបាល រួមទាំងមន្ត្រីដែលបានចូលរួមជាវាគ្មិន ក្នុងការចូលរួម និងការចែករំលែកទស្សនៈដ៏មានតម្លៃ។ យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេស ជូនចំពោះទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ការគាំទ្រ និងជូនចំពោះ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ភាពដឹកនាំ និងការលើកទឹកចិត្តរបស់ឯកឧត្តម។

# អំពីកម្មវិធីពន្លកចំណេះ

ផ្អែកលើសមិទ្ធផលទទួលបានពីការអនុវត្តកម្មវិធីពន្លកចំណេះ ដំណាក់កាលទី១ (២០១៩-២០២៣) ដែលមានគោលបំណងពង្រឹងសមត្ថភាពរបស់ស្ថាប័នស្រាវជ្រាវនៅកម្ពុជា ដើម្បីជានាគុណភាពនៃការស្រាវជ្រាវនៅកម្ពុជា អង្គការមូលនិធិអាស៊ី កំពុងអនុវត្តកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា ដំណាក់កាលទី២ (២០២៣-២០២៧)។ ដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី កម្មវិធីនេះមានគោលបំណងរួមចំណែកដល់ការសម្រេចចិត្តផ្នែកគោលនយោបាយសាធារណៈ ដែលផ្អែកលើទិន្នន័យ និងមានការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន ត្រូវបានអនុវត្ត និងក្លាយជាបទដ្ឋាននៅកម្ពុជា។

# អំពីអង្គការមូលនិធិអាស៊ី

អង្គការមូលនិធិអាស៊ី គឺជាអង្គការអន្តរជាតិមិនស្វែងរកប្រាក់ចំណេញ ដែលធ្វើការដើម្បីដោះស្រាយបញ្ហាសង្គម និងសេដ្ឋកិច្ចដ៏លំបាកបំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ផ្អែកលើបទពិសោធជាង ៧០ឆ្នាំ និងចំណេះដឹងមូលដ្ឋានស៊ីជម្រៅ អង្គការមូលនិធិអាស៊ីធ្វើការជាមួយដៃគូនៅតាមបណ្តាប្រទេសជាង ២០ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងពង្រីកឱកាសសម្រាប់ប្រជាជននៅទីនោះ។

## ក្រុមការងារ

### ក្រុមការងារនៃអង្គការមូលនិធិអាស៊ី

Dolgion Aldar
ម៉ន លីហ្សា
ជ័យ ម៉ារ៉ាមី
Meloney Lindberg
គឹម មីរ៉ាតូរី
ម៉ែន ពិចិត្រ
សារី ភិរម្យ
ងិន ពិសិដ្ឋ
ប្រាក់ វត្តធិរា
ហួត សាលីនិត
សាន់ សុជាតា
ផន សុខភួង
ម៉ាលីកា សុខុន
ស៊ឹម សុវចនា
ផុន ស្រីល័ក្ខ

### ដៃគូយុទ្ធសាស្រ្តរបស់កម្មវិធីពន្លកចំណេះ

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា
មជ្ឈមណ្ឌលខេមរសិក្សា
មជ្ឈមណ្ឌលសិក្សាគោលនយោបាយ
វេទិកាអនាគត

### ដៃគូនវានុវត្តន៍របស់កម្មវិធីពន្លកចំណេះ

មជ្ឈមណ្ឌលវិភាគបញ្ហាអភិវឌ្ឍន៍
វិទ្យាស្ថានជាតិសង្គមកិច្ច
សាកលវិទ្យាល័យជាតិបាត់ដំបង
អង្គការភូមិខ្ញុំ

### ក្រុមជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

អង្គការជនពិការកម្ពុជា
អង្គការយេនឌ័រ និងការអភិវឌ្ឍនៅកម្ពុជា
អង្គការនារីដើម្បីសន្តិភាព

### ការគាំទ្រថវិកា

កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖ ទិន្នន័យ
និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា
ទទួលបានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី
និងអនុវត្តដោយអង្គការមូលនិធិអាស៊ី

## អំណះអំណាង

វេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះ ក្រោមប្រធានបទ «ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន នៅក្នុងបរិបទប្រែប្រួល៖ ការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ» បានទទួលការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា របស់អង្គការមូលនិធិអាស៊ី។ ទស្សនៈដែលបានលើកឡើងក្នុងសៀវភៅនេះ គឺជាទស្សនៈរបស់វាគ្មិន និងអ្នកចូលរួមពិភាក្សា ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលី ឬអង្គការមូលនិធិអាស៊ីឡើយ។

រក្សាសិទ្ធិ © អង្គការមូលនិធិអាស៊ី ឆ្នាំ២០២៥


2025
NATIONAL POLICY FORUM
PLENARY PANEL DISCUSSION
"THE ROLE AND FUTURE OF CAMBODIA'S KNOWLEDGE SECTOR IN STRENGTHENING INCLUSIVE POLICY PROCESSES"
Dr. Mak Sithirith
Director of Center for Natural Resources and Environment
Cambodia Development Resource Institute
Ms. San Sophany
President
SheThinks Network
H.E. Khim Finan
Under-secretary of State
Ministry of Agriculture, Forestry and Fisheries
H.E. Dr. Bo Chankoulika
Under-secretary of State
Ministry of Education, Youth and Sport
Mr. Chan Sophal
Executive Director
Centre for Policy Studies
Ms. Kry Suyheang
Executive Director
Women Peace Makers
MODERATOR

# ទិដ្ឋភាពរួមនៃវេទិកាគោលនយោបាយ ថ្នាក់ជាតិនៃកម្មវិធីពន្លកចំណេះ ឆ្នាំ២០២៥

ការតាក់តែងគោលនយោបាយ ប្រកបដោយបរិយាបន្ននៅក្នុងបរិបទប្រែប្រួល៖ ការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥



រាជធានីភ្នំពេញ ប្រទេសកម្ពុជា

| | ស្ត្រី | ជនមានពិការភាព | ជនជាតិដើមភាគតិច |
|---|---|---|---|
| **២៣២** អ្នកចូលរួម | **៨៣** | **១៥** | **១** |
| **៣៧** វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល | **១១** | **២** | **១** |

- ក្រសួង និងស្ថាប័នជាតិសំខាន់ៗ
- មជ្ឈមណ្ឌលស្រាវជ្រាវ
- ស្ថាប័នសិក្សាគោលនយោបាយ
- គ្រឹះស្ថានសិក្សា
- អង្គការសង្គមស៊ីវិល
- សហគមន៍
- ដៃគូអភិវឌ្ឍន៍
- អង្គការក្នុងស្រុក
- តួអង្គវិស័យឯកជន
- និងស្ថាប័នសារព័ត៌មាន

## កិច្ចពិភាក្សា

**១**

តួនាទី និងអនាគតនៃវិស័យស្រាវជ្រាវកម្ពុជានៅក្នុងការពង្រឹងដំណើរការគោលនយោបាយប្រកបដោយបរិយាបន្ន

**២**

ការរួមបញ្ចូលការធ្វើចំណាកស្រុកដែលបណ្តាលមកពីអាកាសធាតុ និងកិច្ចគាំពារសង្គមទៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

**៣**

ការអភិវឌ្ឍជនបទប្រកបដោយបរិយាបន្ន៖ ការចូលរួមរបស់សហគមន៍ និងក្រុមសង្គមក្នុងការធ្វើផែនការ និងលទ្ធផលនៃវិនិយោគក្នុងស្រុក ដើម្បីជួយដល់តម្រូវការរបស់ក្រុមសង្គមនៅក្នុងបរិបទប្រែប្រួលអាកាសធាតុ

**៤**

មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៅក្នុងទិដ្ឋភាពស្រាវជ្រាវដែលកំពុងវិវត្តនៅកម្ពុជា

**៥**

បទបង្ហាញខ្លី៖ «គំនិតគោលនយោបាយតូចៗសម្រាប់អនាគតរបស់កម្ពុជា»

នៅលើវេទិកាបណ្តាញសង្គមកម្មវិធីនេះទទួលបាន

**+៥៤ ០០០**

**ការចូលរួមតាមប្រព័ន្ធអនឡាញ**

**+១០០**

**ការចែករំលែក**

ជួយពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ និងពង្រឹងសន្ទុះ សម្រាប់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យនៅកម្ពុជា

**១៣**

**អត្ថបទសារព័ត៌មាន**

**២**

**ការផ្សាយព័ត៌មានតាមទូរទស្សន៍**

ស្ថានីយទូរទស្សន៍បាយ័ន ប៉ុស្តិ៍ទូរទស្សន៍ព័ត៌មានCNC កាសែតភ្នំពេញប៉ុស្តិ៍ ខ្មែរថាមស៍ Cambodianess គិរីផុស កម្ពុជាថ្មី និង ខេមបូឌា អ៊ិនវេសមិន រីវ្យូ

# សង្ខេបកិច្ចពិភាក្សា




**កិច្ចពិភាក្សាតុមូលពេញអង្គស្តីពី «តួនាទី និងអនាគតនៃវិស័យស្រាវជ្រាវកម្ពុជានៅក្នុងការពង្រឹងដំណើរការគោលនយោបាយប្រកបដោយបរិយាបន្ន»** - វិស័យស្រាវជ្រាវនៅកម្ពុជាអាចសម្រួចគោលនយោបាយប្រកបដោយប្រសិទ្ធភាពបាន លុំកណាទិន្នន័យមានភាពទាន់ពេលវេលា ងាយស្រួលទទួលបាន និងមានបរិយាបន្ន។ ការពង្រឹងកិច្ចសហការរវាងអ្នកស្រាវជ្រាវ អ្នកតាក់តែងគោលនយោបាយ និងសហគមន៍ ជាពិសេស ស្ត្រី យុវជន ជនជាតិភាគតិច និងជនមានពិការភាព គឺជាកត្តាចាំបាច់ ដើម្បីធានាថា យុទ្ធសាស្ត្រជាតិប្រែក្លាយជាផលប្រយោជន៍ពិតប្រាកដសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។




**កិច្ចពិភាក្សាស្របពេលគ្នាស្តីពី «ការរួមបញ្ចូលការធ្វើចំណាកស្រុកដែលបណ្តាលមកពីអាកាសធាតុ និងកិច្ចគាំពារសង្គមទៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ»** - ភាពធន់នឹងអាកាសធាតុរបស់កម្ពុជាអាស្រ័យលើការផ្សារភ្ជាប់កិច្ចគាំពារសង្គម ការធ្វើចំណាកស្រុក និងយុទ្ធសាស្ត្របន្សាំ។ ថ្វីដ្បិតតែការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុមានកម្រិតខ្ពស់ក៏ដោយ យុទ្ធសាស្ត្រទប់ទល់នៅមានកម្រិតនៅឡើយ ដែលរំលេចឱ្យឃើញពីភាពចាំបាច់ក្នុងការបង្កើនគោលនយោបាយប្រកបដោយបរិយាបន្ន ពង្រឹងចំណេះដឹងសហគមន៍ និងលើកកម្ពស់មុខរបរដែលធន់នឹងអាកាសធាតុសម្រាប់ក្រុមងាយរងគ្រោះ។




**កិច្ចពិភាក្សាស្របពេលគ្នាស្ដីពី «ការអភិវឌ្ឍជនបទប្រកបដោយបរិយាបន្ន»** - គោលនយោបាយជាតិអភិវឌ្ឍន៍ជនបទថ្មីរបស់កម្ពុជា គឺជាជំហានឆ្ពោះទៅមុខដ៏រឹងមាំមួយ ដើម្បីឈានទៅសម្រេចបានកំណើនប្រកបដោយចីរភាព និងបរិយាបន្ន។ ជាមួយនឹងការផ្ដោតទៅលើភូមិគំរូ វិមជ្ឈការ និងកិច្ចសហការពីអ្នកពាក់ព័ន្ធចម្រុះ គោលនយោបាយនេះមានគោលបំណងលើកស្ទួយសហគមន៍ជនបទ ពង្រឹងអភិបាលកិច្ចមូលដ្ឋាន និងធានាថាគ្រប់ក្រុមទាំងអស់ ជាពិសេស ស្ត្រី និងសហគមន៍ដែលត្រូវបានគេផាត់ចេញ ទទួលបានផលប្រយោជន៍ពីវឌ្ឍនភាពដែលសម្រេចបានជាបន្តបន្ទាប់របស់ប្រទេស។




**កិច្ចពិភាក្សាស្របពេលគ្នាស្ដីពី «មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមក្នុងទិដ្ឋភាពស្រាវជ្រាវដែលកំពុងវិវត្តនៅកម្ពុជា»** - ការចាប់អារម្មណ៍លើការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រមនុស្ស និងវិទ្យាសាស្ត្រសង្គម កំពុងមានការកើនឡើង ជាពិសេស ក្នុងចំណោមអ្នកសិក្សាជាស្ត្រី ប៉ុន្តែបញ្ហាប្រឈមនៅតែមានជុំវិញការណែនាំបង្ហាញផ្លូវ ធនធាន និងភាពច្បាស់លាស់នៃគោលបំណង។ ការកសាងវប្បធម៌ស្រាវជ្រាវដ៏រឹងមាំមួយ ទាមទារឱ្យមានគោលនយោបាយគាំទ្រ ប្រព័ន្ធទិន្នន័យដែលប្រសើរជាងមុន និងបណ្ដាញដែលមានបរិយាបន្ន ដើម្បីធានាថាអ្នកស្រាវជ្រាវកម្ពុជាអាចរួមចំណែកប្រកបដោយអត្ថន័យដល់អត្តសញ្ញាណជាតិ ការអភិវឌ្ឍ និងចំណេះដឹងសកល។



**បទបង្ហាញខ្លីៗ (Lightning Talk) ស្ដីពី «គំនិតគោលនយោបាយតូចៗ សម្រាប់អនាគតរបស់កម្ពុជា»** - យុវជនមានចក្ខុវិស័យចង់បាន ប្រទេសកម្ពុជាមួយដែលគោលនយោបាយយកប្រជាជនជាស្នូល ប្រកបដោយបរិយាបន្ន និងផ្អែកលើតថភាពជាក់ស្ដែងនៅតាមមូលដ្ឋាន។ សំណើរបស់ពួកគេ ចាប់ពីលំនៅឋាន និងកិច្ចគាំពារសង្គម រហូតដល់សិទ្ធិជនជាតិភាគតិច និងពន្ធ បានរំលេចឱ្យឃើញថា ការតាក់តែងគោលនយោបាយដែលមានប្រសិទ្ធភាព ត្រូវការសម្លេងពីសហគមន៍ ការពារក្រុមងាយរងគ្រោះ និងបង្កើតប្រព័ន្ធដែលមានភាពយុត្តិធម៌ និងចីរភាព។



# សេចក្តីផ្តើម

ស្ថានភាពគោលនយោបាយរបស់កម្ពុជាកំពុងឆ្លងកាត់ការផ្លាស់ប្តូរដ៏សំខាន់មួយ ដែលរំលេចឱ្យឃើញពីភាពចាំបាច់កាន់តែខ្លាំងឡើងនៃការសម្រេចចិត្តផ្អែកលើទិន្នន័យ និងដំណើរការគោលនយោបាយដែលមានការសហការគ្នា។ រដ្ឋាភិបាលអូស្ត្រាលី មានមោទកភាព ដែលបានគាំទ្រដល់ការពង្រឹងកិច្ចសហការរវាងតួអង្គគោលនយោបាយ និងអ្នកស្រាវជ្រាវ និងលើកកម្ពស់ដំណើរការគោលនយោបាយប្រកបដោយបរិយាបន្ន តាមរយៈកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជាដំណាក់កាលទី២(ខែកក្កដា ឆ្នាំ២០២៣ ដល់ខែមិថុនា ឆ្នាំ២០២៧) ដែលអនុវត្តដោយអង្គការមូលនិធិអាស៊ី។

ក្រោមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំប្រឹងប្រែងយ៉ាងសកម្ម ដើម្បីបញ្ចូលទិន្នន័យ ការស្រាវជ្រាវ និងការវាយតម្លៃទៅក្នុងដំណើរការតាក់តែងគោលនយោបាយ។ ការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រជាតិសំខាន់ៗនៅក្នុងឆ្នាំ២០២៤ ដូចជា ផែនការនារីរតនៈទី៦ ស្តីពីសមភាពយេនឌ័រ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពថ្មី ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ និងផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុដំណាក់កាលទី៣ (NDC) ៣.0 ស្តីពីសកម្មភាពអាកាសធាតុ បានបង្ហាញបន្ថែមទៀតពីការប្តេជ្ញាចិត្តរបស់កម្ពុជា ចំពោះការអភិវឌ្ឍប្រកបដោយបរិយាបន្ន។ របៀបវារៈស្រាវជ្រាវជាតិ ឆ្នាំ២០២៥ ទោះបីជាផ្តោតជាចម្បងលើវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ក៏ដោយ ក៏បានឆ្លុះបញ្ចាំងពីការទទួលស្គាល់កាន់តែខ្លាំងឡើងអំពីសារៈសំខាន់នៃការស្រាវជ្រាវ ដើម្បីគាំទ្រដល់អាទិភាពជាតិ។

កំណើនតម្រូវការទិន្នន័យប្រកបដោយបរិយាបន្នរបស់រដ្ឋាភិបាល បង្ហាញពីគុណតម្លៃនៃការលើកកម្ពស់ការធ្វើសមាហរណកម្មវិស័យស្រាវជ្រាវ។ គោលនយោបាយ និងភាពបើកចំហទាំងនេះ នាំមកនូវ ឱកាសប្រកបដោយអត្ថន័យសម្រាប់កិច្ចសហការរវាងស្ថាប័នរដ្ឋ សង្គមស៊ីវិល និងតួអង្គស្រាវជ្រាវ។ ជាពិសេស ការសម្របសម្រួលនៅខាងផ្នែកតម្រូវការការស្រាវជ្រាវ ទិន្នន័យ និងកិច្ចសន្ទនាគោលនយោបាយប្រកបដោយអត្ថន័យដែលកំពុងកើនឡើង និងនៅខាងផ្នែកផ្គត់ផ្គង់ទិន្នន័យទាន់ពេលវេលា គួរឱ្យទុកចិត្ត និងងាយស្រួលប្រើប្រាស់ត្រូវបានធ្វើឡើង ផ្អែកលើការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន។




ខណៈពេលដែលវិស័យស្រាវជ្រាវរបស់កម្ពុជា[១] កាន់តែមានសកម្មភាពខ្លាំងក្លា ដោយមានស្ថាប័នរដ្ឋ និងស្ថាប័នក្នុងស្រុកជាច្រើនផលិតលទ្ធផលស្រាវជ្រាវដែលមានប្រយោជន៍ នៅតែមានចំណុចដែលត្រូវកែលម្អ ជុំវិញរបៀបរបបដែលតួអង្គរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលធ្វើការជាមួយគ្នា។ នៅក្នុងអំឡុងពេលនៃភាពមិនប្រាកដប្រជា កិច្ចសហការនេះដើរតួនាទីយ៉ាងសំខាន់ ដើម្បីឱ្យស្ថាប័ននានាអាចសម្របខ្លួនទៅនឹងបញ្ហាប្រឈមថ្មីៗ និងធានាថាគោលនយោបាយមានការឆ្លើយតបនិងឆ្លុះបញ្ចាំងពីតម្រូវការរបស់ក្រុមដែលមិនសូវមានភាពតំណាង ដូចជា ស្ត្រី យុវជន ជនជាតិភាគតិច និងជនមានពិការភាព ជាដើម។

ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ កម្មវិធីពន្លកចំណេះបានសហការជាមួយបណ្ដាញនៃស្ថាប័នសិក្សាគោលនយោបាយ និងស្ថាប័នស្រាវជ្រាវក្នុងស្រុកជាង ២០ ដើម្បីលើកកម្ពស់កិច្ចសន្ទនាប្រកបដោយបរិយាបន្ន ការស្រាវជ្រាវប្រកបដោយគុណភាព និងការបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និង បរិយាបន្នសង្គម (GEDSI) នៅគ្រប់កិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវ ការផ្សព្វផ្សាយនិងការចូលរួម។

នៅក្នុងបរិបទនេះ វេទិកាគោលនយោបាយថ្នាក់ជាតិនៃកម្មវិធីពន្លកចំណេះ ឆ្នាំ២០២៥ ក្រោមប្រធានបទ **«ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ននៅក្នុងបរិបទប្រែប្រួល៖ ការផ្សារភ្ជាប់ចំណេះដឹងគោលនយោបាយនិងមនុស្សជាតិ»** បានផ្ដល់នូវឱកាសទាន់ពេលវេលាមួយ សម្រាប់កិច្ចពិភាក្សានេះ។ ផ្អែកលើកេរដំណែលនៃវេទិកាមុនៗ ដែលរៀបចំក្រោមកម្មវិធីពន្លកចំណេះ ដំណាក់កាលទី១ វេទិកាឆ្នាំ២០២៥នេះ បានរំលេចអំពីវិស័យស្រាវជ្រាវដែលកំពុងវិវត្តនៅកម្ពុជា និងស្វែងយល់ពីរបៀបដែលអ្នកស្រាវជ្រាវ តួអង្គរដ្ឋាភិបាល និងសហគមន៍អាចធ្វើការរួមគ្នា ដើម្បីពង្រឹងការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យ។

វេទិកានេះមានអ្នកចូលរួមចំនួន ២៣២នាក់ (ស្ត្រី ៨១នាក់ ជនមានពិការភាព ១៥នាក់ ជនជាតិដើមភាគតិច ១នាក់ និង ២១នាក់មិនបានបញ្ជាក់អំពីអត្តសញ្ញាណ) មកពីទូទាំងប្រទេសកម្ពុជា រួមមានតំណាងមកពីរាជរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ និងអប់រំ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ បណ្ដាញយុវជន និងអ្នកដឹកនាំសហគមន៍។ គោលបំណងនៃវេទិកានេះគឺដើម្បីជំរុញកិច្ចសហការរវាងអ្នកតាក់តែងគោលនយោបាយ និងអ្នកស្រាវជ្រាវ បង្ហាញពីរបៀបដែលទិន្នន័យ និងភស្តុតាងអាចផ្ដល់ព័ត៌មានដល់យុទ្ធសាស្ត្រជាតិ និងលើកកម្ពស់បរិយាបន្នដោយធានាថា ស្ត្រី យុវជន ជនមានពិការភាពនិងជនជាតិភាគតិច គឺជាផ្នែកមួយនៃកិច្ចពិភាក្សាគោលនយោបាយជាតិ និងស្វែងរកដំណោះស្រាយ។



វេទិកានេះបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការប្រើប្រាស់ការស្រាវជ្រាវ កិច្ចពិភាក្សា និងបរិយាបន្ន ជាកត្តាជំរុញការអភិវឌ្ឍជាតិ។ ជាមួយនឹងសុន្ទរកថាគន្លឹះដោយ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសុន្ទរកថាបើកកម្មវិធីដោយ ឯកឧត្តម Derek Yip ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា កម្មវិធីនេះបានគូសបញ្ជាក់ពីចក្ខុវិស័យរួមនៃរដ្ឋាភិបាលទាំងពីរ ដើម្បីធានាថាគោលនយោបាយនានា ត្រូវបានរៀបចំឡើងផ្អែកតាមទិន្នន័យដែលទុកចិត្តបាននិងឆ្លុះបញ្ចាំងពីសំឡេងរបស់ប្រជាជនកម្ពុជាគ្រប់រូប។

សៀវភៅនេះចាប់យកនូវសារសំខាន់ៗ ការឆ្លុះបញ្ចាំង និងទិដ្ឋភាពនានាពីវេទិកានេះ ដែលជាការអបអរសាទរវឌ្ឍនភាពរបស់កម្ពុជា ឆ្ពោះទៅរកអនាគតមួយ ដែលគោលនយោបាយមានបរិយាបន្ន ផ្អែកលើទិន្នន័យ និងមានភាពធន់។

១ «វិស័យស្រាវជ្រាវ» សំដៅលើទិដ្ឋភាពស្ថាប័នដែលគ្របដណ្តប់លើរាជរដ្ឋាភិបាល វិស័យឯកជន និងអង្គការសង្គមស៊ីវិល ដែលបង្កើត និងប្រើប្រាស់ការស្រាវជ្រាវ និងការវិភាគ ដើម្បីផ្តល់ជាធាតុចូលដល់គោលនយោបាយសាធារណៈ។




លោកស្រី Dolgion Aldar
នាយិកាកម្មវិធីពន្លកចំណេះ
*អង្គការមូលនិធិអាស៊ី*

# សុន្ទរកថាស្វាគមន៍

## ជម្រាបសួរ និងអរុណសួស្តី

នាងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង តាងនាមលោកស្រី មេឡូនី លីនបឹក តំណាងប្រចាំប្រទេសនៃអង្គការមូលនិធិអាស៊ី និងក្នុងនាមអង្គការមូលនិធិអាស៊ី និងកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍ នៅកម្ពុជា សូមស្វាគមន៍ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា មកកាន់វេទិកាគោលនយោបាយថ្នាក់ជាតិ ឆ្នាំ២០២៥។

ជាបឋម នាងខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្ររបស់រដ្ឋាភិបាលអូស្ត្រាលី និងភាពជាដៃគូរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលការដឹកនាំ និងកិច្ចសហការនេះបានធ្វើឱ្យកិច្ចការនេះអាចប្រព្រឹត្តទៅបាន។ នាងខ្ញុំក៏សូមអរគុណដល់ដៃគូកម្មវិធីពន្លកចំណេះ ដែលបានសហការរៀបចំវេទិកានាថ្ងៃនេះ និងតំណាងសហគមន៍ដែលបានធ្វើដំណើរមកពីបណ្តាខេត្តនានា។

វេទិកាគោលនយោបាយថ្នាក់ជាតិនេះ គឺជាសកម្មភាពលេចធ្លោមួយរបស់កម្មវិធីពន្លកចំណេះ តាំងពីឆ្នាំ២០១៩មក និងបានជួយឱ្យវិស័យស្រាវជ្រាវរបស់កម្ពុជាត្រូវបានគេស្គាល់កាន់តែច្បាស់។ ដំណាក់កាលទី១ នៃកម្មវិធីពន្លកចំណេះ បានដាក់មូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់បរិយាបន្ន ដូចជាការបង្កើតបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ (SheThinks Network) ដែលជាបណ្តាញស្ត្រីអ្នកស្រាវជ្រាវដំបូងគេនៅកម្ពុជា ដែលបន្តឆ្លើយតបចំពោះបញ្ហាវិសមភាពយេនឌ័រនៅក្នុងវិស័យស្រាវជ្រាវ និងលើកកម្ពស់សំឡេងស្ត្រីក្នុងការតាក់តែងគោលនយោបាយ។

នៅក្នុងដំណាក់កាលទី២ (២០២៣–២០២៧) កម្មវិធីពន្លកចំណេះកំពុងពង្រីកកិច្ចការនេះបន្ថែមទៀត។ យើងកំពុងសហការជាមួយស្ថាប័នស្រាវជ្រាវ សាកលវិទ្យាល័យ និងអង្គការសង្គមស៊ីវិលនៅកម្ពុជាជាង ២០ ស្ថាប័ន ក្នុងការដោះស្រាយបញ្ហាសំខាន់ៗចំពោះអនាគតរបស់កម្ពុជា ចាប់ពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍជនបទរហូតដល់កិច្ចគាំពារសង្គម អភិបាលកិច្ចប្រកបដោយបរិយាបន្ន និងទិន្នន័យបើកទូលាយ ព្រមទាំងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។




ប្រធានបទនៃវេទិកានាថ្ងៃនេះគឺ *«ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន នៅក្នុងបរិបទប្រែប្រួល៖ ការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ»* ពិតជាមានភាពសមស្របទៅនឹងកាលៈទេសៈបច្ចុប្បន្ន។ នៅទូទាំងពិភពលោក រដ្ឋាភិបាលនានា កំពុងប្រឈមមុខនឹងភាពមិនប្រាកដប្រជា បង្កឡើងដោយការប្រែប្រួលអាកាសធាតុ ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល និងការផ្លាស់ប្តូរថាមវន្តសង្គម និងសេដ្ឋកិច្ច។ នៅក្នុងកាលៈទេសៈបែបនេះ សារៈសំខាន់នៃការប្រើប្រាស់ចំណេះដឹងមូលដ្ឋាន ជាត្រីវិស័យតម្រង់ទិសក្នុងភាពមិនប្រាកដប្រជា គឺពិតជាមានតម្លៃមិនអាចកាត់ថ្លៃបាន។ ហេតុដូច្នេះហើយ នៅក្នុងវេទិកានេះ យើងនឹងព្យាយាមឆ្លើយតបនឹងសំណួរថា៖ «តើវិស័យស្រាវជ្រាវរបស់កម្ពុជាអាចបន្តសម្របខ្លួនបានយ៉ាងដូចម្តេចនៅក្នុងកាលៈទេសៈនៃភាពមិនប្រាកដប្រជា ?»

វេទិកានេះផ្តល់នូវឱកាស ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាព ពង្រឹងកិច្ចសហការ និងស្វែងយល់ពីរបៀបដែលវិស័យស្រាវជ្រាវរបស់កម្ពុជាអាចគាំទ្របានកាន់តែប្រសើរដល់យុទ្ធសាស្ត្រជាតិ និងការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន។

### គោលបំណងរបស់យើងគឺសាមញ្ញ៖

> - ផ្សារភ្ជាប់ប្រជាជន រដ្ឋាភិបាល អ្នកស្រាវជ្រាវ សង្គមស៊ីវិល និងសហគមន៍ ដើម្បីចែករំលែកគំនិត និងភ្ជាប់ទំនាក់ទំនង
> - បង្ហាញពីរបៀបដែលការស្រាវជ្រាវ និងទិន្នន័យនៅកម្ពុជា អាចផ្តល់ព័ត៌មានពីបញ្ហាប្រឈមផ្នែកគោលនយោបាយនាពេលបច្ចុប្បន្ន និង
> - លើកកម្ពស់បរិយាបន្ន ដោយធានាថាទស្សនៈរបស់ស្ត្រី យុវជន ជនមានពិការភាព ជនជាតិភាគតិច និងក្រុមដែលមិនសូវមានភាពតំណាងផ្សេងទៀត គឺជាផ្នែកមួយនៃកិច្ចសន្ទនាគោលនយោបាយជាតិ និងដំណោះស្រាយ។

ចក្ខុវិស័យរបស់នាងខ្ញុំ គឺចង់ឃើញវេទិកាគោលនយោបាយថ្នាក់ជាតិនៃកម្មវិធីពន្លកចំណេះវិវត្តក្លាយជាវេទិកាទៀងទាត់មួយដែលផ្សារភ្ជាប់តួអង្គទាំងអស់ក្នុងវិស័យស្រាវជ្រាវរបស់កម្ពុជា ស្រដៀងគ្នាទៅនឹងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ឬ វេទិកាភាពជាដៃគូសង្គមស៊ីវិល-រាជរដ្ឋាភិបាល ដែលមានស្រាប់។ ប៉ុន្តែអ្វីដែលធ្វើឱ្យវេទិកានេះមានលក្ខណៈពិសេសនោះ គឺវិស័យដែលវេទិកានេះផ្តោតការយកចិត្តទុកដាក់លើ ជាវេទិកាដែលរៀបចំជាពិសេសសម្រាប់វិស័យស្រាវជ្រាវ។ វេទិកានេះជាឱកាសសម្រាប់អ្នកដែលធ្វើការផ្អែកលើទិន្នន័យ និងគំនិតនានា អ្នកដែលខិតខំដើម្បីឱ្យមានស្តង់ដាររួម និងអ្នកដែលប្តេជ្ញាចិត្ត ចំពោះការអនុវត្តប្រកបដោយបរិយាបន្ន។ នៅពេលអនាគត វេទិកានេះអាចនឹងត្រូវបានសហការរៀបចំ ដោយរដ្ឋាភិបាល និងសង្គមស៊ីវិល ដែលឆ្លុះបញ្ចាំងពីស្មារតីនៃកិច្ចសហការដែលជាបេះដូងនៃការតាក់តែងគោលនយោបាយ។

ជាចុងក្រោយ នាងខ្ញុំសូមគូសបញ្ជាក់ថា វេទិកានេះមិនមែនត្រឹមតែជាការពិភាក្សាប៉ុណ្ណោះទេ ប៉ុន្តែគឺជាការផ្សារភ្ជាប់ទំនាក់ទំនង។ នាងខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកទាំងអស់គ្នាចែករំលែកដោយបើកចំហ ស្តាប់ដោយយកចិត្តទុកដាក់ និងធ្វើការជាមួយគ្នា។

នាងខ្ញុំសូមសម្តែងអំណរគុណចំពោះ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការផ្តល់សុន្ទរកថាគន្លឹះ ឯកឧត្តម Derek Yip ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា សម្រាប់ការគាំទ្រជាបន្តបន្ទាប់ និងចំពោះដៃគូរបស់យើងទាំងអស់ដែលបានខិតខំប្រឹងប្រែងរៀបចំវេទិកានេះ។

សូមអរគុណជាថ្មីម្តងទៀតសម្រាប់ការចូលរួម ហើយនាងខ្ញុំសង្ឃឹមថា អ្នកទាំងអស់គ្នានឹងទទួលបាននូវការពិភាក្សាថ្ងៃនេះដ៏មានតម្លៃ និងពាក់ព័ន្ធនឹងការងាររបស់អ្នក។




ឯកឧត្តម Derek Yip
ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំប្រទេសកម្ពុជា

# សុន្ទរកថាបើកកម្មវិធី

“

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដែលបានចូលរួមជាមួយអ្នកទាំងអស់គ្នានាថ្ងៃនេះ នៅក្នុងវេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៥។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការមូលនិធិអាស៊ី និងដៃគូដទៃទៀត របស់កម្មវិធីពន្លកចំណេះ សម្រាប់ការរៀបចំវេទិកាដ៏សំខាន់នេះឡើង។

ខ្ញុំក៏សូមកោតសរសើរចំពោះកិច្ចសហការ និងការប្ដេជ្ញាចិត្តដ៏រឹងមាំរបស់ រាជរដ្ឋាភិបាលកម្ពុជា និងសមាជិកនៃគណៈកម្មាធិការប្រឹក្សាផ្នែកបច្ចេកទេសរបស់កម្មវិធីពន្លកចំណេះ ចំពោះការរួមចំណែករបស់ពួកគេក្នុងការពង្រឹងការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យនៅកម្ពុជា។

កម្ពុជា និងអូស្ត្រាលី កំពុងប្រឈមមុខនឹងបញ្ហាដ៏ស្មុគស្មាញ និងវិវត្តឥតឈប់ឈរជាច្រើន ដូចជា ការប្រែប្រួលអាកាសធាតុ បញ្ហាសេដ្ឋកិច្ច និងវិសមភាព ជាដើម។ បញ្ហាប្រឈមទាំងនេះ តម្រូវឱ្យយើងរៀបចំគោលនយោបាយឆ្លើយតបផ្អែកលើភស្ដុតាង និងទិន្នន័យ។

អូស្ត្រាលីគឺជាដៃគូដ៏រឹងមាំ និងស្មោះត្រង់របស់កម្ពុជាអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ជាពិសេស នៅក្នុងការផ្ដល់ជំនួយអភិវឌ្ឍន៍។ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ការគាំទ្ររបស់យើងដល់កម្ពុជា បានគ្របដណ្ដប់លើវិស័យជាច្រើន រួមមាន៖ ការអប់រំ សុខាភិបាល កសិកម្ម អភិបាលកិច្ច កិច្ចគាំពារសង្គម និងធនធានទឹកជាដើម។

ការរៀបចំយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពបំផុត ដើម្បីនាំមកនូវវឌ្ឍនភាពនៅក្នុងវិស័យទាំងនេះ ទាមទារឱ្យមានការចូលរួមពីវិស័យស្រាវជ្រាវ។ ក្នុងវិស័យនេះហើយ ដែលគ្រាប់ពូជនៃគំនិតល្អៗចាប់បដិសន្ធិ។ គោលនយោបាយដែលទទួលបានព័ត៌មាន និងគាំទ្រដោយទិន្នន័យរឹងមាំ និងដោយទស្សនៈនៃក្រុមចម្រុះ នឹងជំរុញឱ្យមានការផ្លាស់ប្ដូរជាវិជ្ជមាន និងមានប្រសិទ្ធភាពជាមិនខាន។

នេះហើយជាមូលហេតុដែលចាប់តាំងពីឆ្នាំ២០១៩មក តាមរយៈការគាំទ្ររបស់យើងចំពោះ កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា យើងបាន និងកំពុងវិនិយោគលើគំនិតផ្ដួចផ្ដើមដែលលើកកម្ពស់ការស្រាវជ្រាវ ជំរុញកិច្ចពិភាក្សាប្រកបដោយបរិយាបន្ន និងពង្រឹងដំណើរការគោលនយោបាយសាធារណៈ។

”



នៅក្នុងដំណាក់កាលទី១ កម្មវិធីពន្លកចំណេះបានពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវកម្ពុជា ដូចជាស្ថាប័នសិក្សាគោលនយោបាយ ស្ថាប័នស្រាវជ្រាវ និងក្រុមគោលនយោបាយ ដើម្បីធ្វើការស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់ និងចែករំលែកលទ្ធផលទាំងនោះ ក្នុងរូបភាពដែលអាចជះឥទ្ធិពលដល់គោលនយោបាយ។ ការងារនេះបានដាក់មូលដ្ឋានគ្រឹះនៃជំនាញ បណ្ដាញ និងការជឿទុកចិត្ត។

នាពេលនេះ ស្ថិតក្នុងដំណាក់កាលទី២ កម្មវិធីពន្លកចំណេះ ខិតខំកសាងបន្ថែមទៀត បន្តលើមូលដ្ឋានគ្រឹះ ដោយធានាថាការតាក់តែងគោលនយោបាយដែលមានបរិយាបន្ន និងផ្អែកលើទិន្នន័យ នឹងកាន់តែក្លាយជាបទដ្ឋាន។ កម្មវិធីនេះមិនត្រឹមតែពង្រឹងការស្រាវជ្រាវប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ចូលការស្រាវជ្រាវ និងការពិគ្រោះយោបល់ ទៅក្នុងរបៀបនៃការរៀបចំគោលនយោបាយនៅកម្ពុជា។ នេះគឺជាជំហានទៅមុខដ៏សំខាន់មួយ។

ចំណុចស្នូលនៃកិច្ចខិតខំប្រឹងប្រែងនេះ គឺបរិយាបន្ន។ ដើម្បីឱ្យគោលនយោបាយមានប្រសិទ្ធភាពគោលនយោបាយទាំងនោះត្រូវតែឆ្លុះបញ្ចាំងពីតម្រូវការ ទស្សនៈ និងបទពិសោធរស់នៅរបស់ប្រជាជនដែលទទួលរងផលប៉ះពាល់។ វាពិតជាមានសារៈសំខាន់ណាស់ ដែលស្ត្រី ជនមានពិការភាព ជនជាតិដើមភាគតិច យុវជន និងក្រុមដែលដែលត្រូវបានផាត់ចេញផ្សេងទៀត មានឱកាសរួមចំណែកប្រកបដោយអត្ថន័យដល់ការតាក់តែងគោលនយោបាយ។

ការមានទិន្នន័យស្រាវជ្រាវជាក់ស្ដែងស្ដីពីសក្ដានុពលការដាក់បញ្ចូល និងការដកចេញក្នុងសង្គមនៃក្រុមដែលមិនសូវយកចិត្តទុកដាក់ អាចជាកត្តាជំរុញក្នុងការតម្រង់ទិសដៅគោលនយោបាយសាធារណៈ ទៅរកការលើកកម្ពស់ឱកាសស្មើគ្នាក្នុងការសម្រេចចិត្ត។

នៅឆ្នាំនេះ យើងបានដាក់ឱ្យប្រើប្រាស់ផែនការស្តីពីភាពជាដៃគូអភិវឌ្ឍន៍អូស្ត្រាលី-កម្ពុជា ២០២៥-២០២៩ ដែលប្រែក្លាយអាទិភាពរួមនៃប្រទេសទាំងពីរ ឱ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែង។ ផែនការភាពជាដៃគូនេះ ឆ្លុះបញ្ចាំងពីទំនាក់ទំនងស្ថាប័នដ៏ស៊ីជម្រៅ ទំនាក់ទំនងរវាងប្រជាជននិងប្រជាជនដ៏រស់រវើក និងការប្តេជ្ញាចិត្តរួមគ្នាចំពោះសន្តិភាព ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក។

ផែនការនេះកំណត់នូវគោលបំណងដែលបានឯកភាពគ្នាចំនួនបី ដែលរួមមានរបៀបដែលយើងនឹងធ្វើការរួមគ្នាដើម្បីសម្រេចគោលបំណងទាំងនោះ និងវិស័យដែលអូស្ត្រាលីអាចជួយទ្រទ្រង់បន្ថែមដ៏ល្អបំផុត ដល់អាទិភាពជាតិរបស់កម្ពុជា។ ចំណុចគន្លឹះសំខាន់មួយ គឺការគាំទ្រដល់ស្ថាប័នជាតិ និងដៃគូក្នុងស្រុក ដើម្បីផលិត និងប្រើប្រាស់ទិន្នន័យដែលអាចទុកចិត្តបាន សម្រាប់ការតាក់តែងគោលនយោបាយដែលមានភាពពាក់ព័ន្ធ និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេសស្ត្រី ជនមានពិការភាព និងក្រុមត្រូវបានផាត់ចេញផ្សេងទៀត។

តាមរយៈកម្មវិធីនានាដូចជា កម្មវិធីពន្លកចំណេះ និង កម្មវិធី CAPRED ជាដើម យើងកំពុងបង្ហាញពីការប្តេជ្ញាចិត្តរបស់យើងចំពោះភាពជាដៃគូដ៏ស្មោះត្រង់ និងប្រកបដោយការគោរព ដោយធ្វើការជាមួយទាំងតួអង្គរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនៅកម្ពុជា។ វេទិកានេះគឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះមួយនៃគោលការណ៍នោះក្នុងការអនុវត្តជាក់ស្តែង។

កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដ៏ទូលំទូលាយរបស់យើង ក៏ត្រូវបានតម្រង់ទិសដោយយុទ្ធសាស្ត្រសកលចំនួនពីរផងដែរ។ យុទ្ធសាស្ត្រអន្តរជាតិស្តីពីសមធម៌ និងសិទ្ធិជនមានពិការភាព៖ ការលើកកម្ពស់សមធម៌ដើម្បីផ្លាស់ប្តូរជីវិត ដែលត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយជនមានពិការភាព បានផ្លាស់ប្តូរការយកចិត្តទុកដាក់ពីបរិយាបន្នធម្មតា ទៅជាការផ្លាស់ប្តូរជាប្រព័ន្ធ ដោយដោះស្រាយរបាំងដែលរារាំងដល់ការចូលរួមពេញលេញ និងស្មើភាពនៅក្នុងសង្គម។

និង យុទ្ធសាស្ត្រអន្តរជាតិស្តីពីសមភាពយេនឌ័ររបស់អូស្ត្រាលី បានបញ្ជាក់ជាថ្មីថា សមភាពយេនឌ័រគឺជាសិទ្ធិមនុស្សជាមូលដ្ឋានផង និងជាកម្លាំងជំរុញនៃវិបុលភាពនៅទូទាំងតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិកផង។



វេទិកាឆ្នាំនេះពិតជាសមស្របបំផុតនឹងកាលៈទេសៈជាក់ស្តែងនាពេលបច្ចុប្បន្ន។ ប្រធានបទ «ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ននៅក្នុងបរិបទប្រែប្រួល៖ ការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ» បានឆ្លុះបញ្ចាំងពីបញ្ហាប្រឈមជាសកល និងថ្នាក់ជាតិដែលយើងទាំងអស់គ្នាកំពុងប្រឈម។ ការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យ ផ្តល់នូវមូលដ្ឋានគ្រឹះដ៏ល្អបំផុតជាត្រីវិស័យតម្រង់ទិសក្នុងភាពមិនប្រាកដប្រជា និងសម្រួចអនាគត ដែលផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់។

**វេទិកានាថ្ងៃនេះ៖ នាំពួកយើងឱ្យពិចារណាអំពីតួនាទីរបស់អ្នកស្រាវជ្រាវកម្ពុជានៅក្នុងអនាគតដែលមិនប្រាកដប្រជា៖**

- តើអ្នកស្រាវជ្រាវ និងអ្នកតាក់តែងគោលនយោបាយអាចសម្របខ្លួនទៅនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សដោយរបៀបណា ?
- តើយើងអាចពង្រឹងកិច្ចសហការដោយរបៀបណា ?
- តើយើងអាចធានាដោយរបៀបណាថា ទិន្នន័យ និងការពិគ្រោះយោបល់ គឺជាចំណុចកណ្តាលនៃការតាក់តែងគោលនយោបាយ ?



ទាំងនេះមិនមែនជាសំណួរដែលងាយស្រួលនោះទេ។ ប៉ុន្តែតាមរយៈការមកជួបជុំគ្នានៅក្នុងវេទិកានេះ ការស្តាប់គ្នាទៅវិញទៅមក និងការចែករំលែកទស្សនៈ និងជំនាញ គឺជាអ្វីដែលពួកយើងកំពុងឈានទៅរកការឆ្លើយតបនឹងសំណួរទាំងនោះ។ ជាចុងក្រោយ ខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណចំពោះអ្នកទាំងអស់គ្នាដែលមានវត្តមាននៅទីនេះ។ ខ្ញុំពិតជារីករាយដែលបានឃើញក្រុមអ្នកចូលរួមចម្រុះ តំណាងឱ្យស្ថាប័នសិក្សាគោលនយោបាយ អង្គការសហគមន៍ វិទ្យាស្ថានស្រាវជ្រាវ ស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក អង្គការពហុភាគី និងដៃគូអភិវឌ្ឍន៍អន្តរជាតិនៅក្នុងវេទិកានាថ្ងៃនេះ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនាំមុខគេក្នុងការប្រើប្រាស់ទិន្នន័យ និងភស្តុតាងនៅក្នុងការតាក់តែងគោលនយោបាយ។ ខ្ញុំក៏សូមអរគុណចំពោះអ្នកចូលរួមទាំងអស់នាថ្ងៃនេះ។ វត្តមានរបស់លោក លោកស្រី បង្ហាញពីកំលាំងនៃកិច្ចសហការ។ ខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកទាំងអស់គ្នាចាប់យកឱកាសនេះ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការនិងបន្តកសាងសហគមន៍វិស័យស្រាវជ្រាវដ៏រឹងមាំមួយ។ ការងាររបស់អស់លោក លោកស្រី មានសារៈសំខាន់ណាស់សម្រាប់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយបរិយាបន្នរបស់កម្ពុជា។

**សូមអរគុណ និងសូមជូនពរឱ្យវេទិកានេះទទួលបានលទ្ធផលជាផ្លែផ្កា និងផ្តល់នូវកម្លាំងជំរុញចិត្តបន្ថែមទៀត។**




ឯកឧត្តម វង្សី វិស្សុត
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# សុន្ទរកថាគន្លឹះ

“

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្ដីសោមនស្សដែលបានចូលរួម និងថ្លែងនូវសុន្ទរកថាគន្លឹះក្នុងវេទិកាគោលនយោបាយថ្នាក់ជាតិឆ្នាំ២០២៥ កម្មវិធីពន្លកចំណេះដែលនឹងពិភាក្សាក្រោមប្រធានបទ «ការរៀបចំ គោលនយោបាយប្រកបដោយបរិយាបន្ន នៅយុគសម័យមិនប្រាកដប្រជា៖ ការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងប្រជាជន» នាពេលនេះដែលសហការរៀបចំដោយ Australian AID កម្មវិធីពន្លកចំណេះ និងអង្គការមូលនិធិអាស៊ី។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ ឯកឧត្តម ឯកអគ្គរដ្ឋទូត ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សាស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងភ្ញៀវកិត្តិយសទាំងអស់ដែលចូលរួមក្នុងវេទិកានេះ។

ខ្ញុំក៏សូមយកឱកាសនេះថ្លែងអំណរគុណចំពោះរដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ី ចំពោះភាពជាដៃគូ និងការប្តេជ្ញាចិត្ត ក្នុងការពង្រឹងប្រព័ន្ធអេកូឡូស៊ីនៃវិស័យស្រាវជ្រាវ និងគោលនយោបាយរបស់កម្ពុជា តាមរយៈកម្មវិធីពន្លកចំណេះ ដែលតែងតែគាំទ្រដល់ដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ និងអាទិភាពគន្លឹះរបស់រាជរដ្ឋាភិបាល។ ខ្ញុំក៏សូមធ្វើការវាយតម្លៃខ្ពស់ចំពោះកម្មវិធីពន្លកចំណេះ ដែលបានអនុវត្តកម្មវិធីក្នុងដំណាក់កាលទី១ ក្នុងអំឡុងឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ហើយសម្រេចបាននូវសមិទ្ធផល គួរជាទីគាប់ចិត្តតាមរយៈការសិក្សាស្រាវជ្រាវជាច្រើនហើយ បានរួមចំណែកដល់ការរៀបចំគោលនយោបាយលើវិស័យសំខាន់ៗដូចជា សេដ្ឋកិច្ច កសិកម្ម អប់រំ ទេសចរណ៍ និងសេវាសាធារណៈជាដើម។ល។

”



ជាការពិត ប្រធានបទនៃវេទិកាថ្ងៃនេះមានសារៈសំខាន់ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាកម្ពុជានៅក្នុងបរិការណ៍បច្ចុប្បន្ន និងទៅអនាគត ខណៈដែលស្ថានភាពក្នុងសកលលោក តំបន់ និងក្នុងប្រទេសកំពុងតែប្រែប្រួលយ៉ាងរហ័ស និងមិនអាចប៉ាន់ប្រមាណបាន។ ពិភពលោកកំពុងប្រឈមនឹងស្ថានការណ៍ដែលមានភាពមិនប្រាកដប្រជា និងហានិភ័យកើនឡើងកាន់តែខ្ពស់ទៅៗ ដែលបង្កផលប៉ះពាល់ ដល់រំហូរពលកម្ម មូលធន ទំនិញ និងសេវា ការវិនិយោគ ជាពិសេសការចែករំលែកបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការ។ល។ ក្នុងនោះនិន្នាការដែលគួរឱ្យបារម្ភរួមមាន ការកើនឡើងនូវភាពតានតឹង សង្គ្រាមពាណិជ្ជកម្មសកល ការរងសម្ពាធពន្ធគយបដិការរបស់សហរដ្ឋអាមេរិក ការបែកខ្ញែកសេដ្ឋកិច្ចនិងខ្សែច្រវាក់ផ្គត់ផ្គង់សកល ការប្រែប្រួលអាកាសធាតុ ការកើនឡើងនៃវិសមភាព និងការប្រែប្រួលផ្នែកប្រជាសាស្ត្រ ការប្រកួតប្រជែងក្នុងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលព្រមទាំងបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងជាពិសេស ការផ្លាស់ប្តូរសណ្ឋានភូមិសាស្ត្រសេដ្ឋកិច្ច និងនយោបាយដែលកំពុងលេចឡើងកាន់តែច្បាស់នូវនិន្នាការពហុប៉ូលពិភពលោកដែលបែកខ្ញែក និងតំបន់ភាវូបនីយកម្ម ( Regionalization )។ ជាងនេះទៅទៀត ការថមថយនៃអភិបាលកិច្ចសកល កង្វះភាពជាអ្នកដឹកនាំកម្រិតសកល និងការបាត់បង់ទំនុកចិត្តផ្នែកនយោបាយ និងយុទ្ធសាស្ត្ររវាងប្រទេសនានា នាំឱ្យកាន់តែលំបាកក្នុងការកសាងកិច្ចសហការកម្រិតអន្តរជាតិ ដែលនាំឱ្យប៉ះពាល់ដល់ការស្វែងរកដំណោះស្រាយ ប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាប្រឈមជាសកលដែលកំពុងកើតមាន។

ក្នុងបរិបទនេះ ការធ្វើការសម្រេចជាគោលនយោបាយដែលផ្អែកលើភស្តុតាងប្រកបដោយបរិយាបន្ន គឺមិនមែនជា "តម្រូវការ" ទេ តែគឺជា "ភាពចាំបាច់" ដើម្បីពង្រឹងអភិបាលកិច្ចល្អ នវានុវត្តន៍ផ្នែកគោលនយោបាយ សិនិទ្ធពលសង្គម កាត់បន្ថយវិសមភាពនៃការអភិវឌ្ឍ  កសាងធម្មានុរូបភាពនិងទំនុកចិត្ត  បង្កើនស័ក្តិសិទ្ធិភាពនៃការអនុវត្តគោលនយោបាយដែលបានរៀបចំ  ចាប់យកសក្តានុពលនៃការប្រើប្រាស់ មូលធនមនុស្ស និងពង្រឹងភាពធន់នៃការអភិវឌ្ឍរបស់ប្រទេសយើង។ ជាងនេះទៅទៀត ផ្អែកលើឧត្តមានុវត្ត និងបទពិសោធអន្តរជាតិ ការប្រើប្រាស់ ភស្តុតាង ឬទិន្នន័យដែលអាចជឿទុកចិត្តបាន ដោយត្រូវបានរួមបញ្ចូលទៅក្នុងកិច្ចពិភាក្សា ដោយមានការចូលរួមពីបណ្តាភាគីពាក់ព័ន្ធ នឹងធ្វើឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពខ្ពស់ ក្នុងការធ្វើការសម្រេចចិត្តជាគោលនយោបាយ ដែលមានភាពច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងមានលក្ខណៈបត់បែនតាមសភាពការណ៍ជាក់ស្តែង ព្រមទាំងអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព ក្នុងការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃការអភិវឌ្ឍប្រទេស និងប្រជាជន។ ក្នុងស្មារតីនេះ ខ្ញុំជឿជាក់ថា ការអនុវត្តដំណាក់កាលទី២ នៃកម្មវិធីពន្លកចំណេះ ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧ នឹងរួមចំណែកដល់ការរៀបចំគោលនយោបាយសាធារណៈ ផ្អែកលើទិន្នន័យ និងភស្តុតាង ព្រមទាំងការពិភាក្សាប្រកបដោយបរិយាបន្ន នឹងទទួលបាននូវលទ្ធផលកាន់តែប្រសើរបន្ថែមទៀតតាមរយៈការចូលរួម និងគាំទ្រពីក្រសួង ស្ថាប័ន វិទ្យាស្ថានស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ខណៈពិភពលោកកំពុងប្រឈមនឹងបរិការណ៍ដែលមានការប្រែប្រួលយ៉ាងឆាប់រហ័សដែលមិនធ្លាប់ឆ្លងកាត់ពីមុន ប្រទេសកម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយនៃការអភិវឌ្ឍដែលទាមទារនូវការគិតគូររៀបចំតាក់តែងគោលនយោបាយ និងយុទ្ធសាស្ត្រនានាប្រកបដោយភាពបន្សុំ និងការប្រមើលទៅមុខដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ រាជរដ្ឋាភិបាលកម្ពុជាបានត្រៀមលក្ខណៈជាស្រេចដើម្បីទប់ទល់នឹងការផ្លាស់ប្តូរទាំងនោះ មិនថាក្នុងទម្រង់ណាមួយនោះទេ ពោលគឺបានគិតគូររៀបចំគោលនយោបាយជាតិ និងផែនការកែទម្រង់លើវិស័យសំខាន់ៗជាបន្តបន្ទាប់ ដែលផ្សារភ្ជាប់នឹងចំណេះដឹង និងប្រជាជន ដើម្បីដោះស្រាយស្ថានភាពជាក់ស្តែងក្នុងសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និង សមធម៌ សំដៅពង្រឹងភាពធន់ទៅនឹងវិបត្តិដែលអាចកើតមានឡើងជាយថាហេតុ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាតែងតែធ្វើសេចក្តីសម្រេចគោលនយោបាយដែលផ្អែកលើភស្តុតាង និងប្រកបដោយបរិយាបន្នដើម្បីធានាថា គោលនយោបាយរបស់យើងពិតជាបម្រើសេចក្តីត្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ជាពិសេសអ្នកដែលងាយរងគ្រោះបំផុតនៅចំពោះមុខភាពមិនប្រាកដប្រជា។

ដូចយើងបានដឹងទាំងអស់គ្នា រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានបន្តប្តេជ្ញាចិត្តឥតងាករេចំពោះការរៀបចំ និងការធ្វើសេចក្តីសម្រេចលើគោលនយោបាយនានាៗ ដោយផ្អែកលើភស្តុតាង ផ្អែកលើទិន្នន័យ លើការវិភាគ តែមិនផ្អែកលើអារម្មណ៍ និងមិនផ្អែកលើការស្រមើស្រមៃនោះទេ។ ការណ៍នេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលបានរៀបចំតាក់តែងផ្អែកលើសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេល២៥ឆ្នាំកន្លងមក និងការវិភាគព្រមទាំងប្រមើលមើលក្នុងរយៈពេល ២៥ឆ្នាំទៅមុខបន្ថែមទៀត។

ជាងនេះទៅទៀត ខ្ញុំសូមគូសជម្រាបជូនអង្គវេទិកាថា ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងឆន្ទៈមោះមុតលើការអនុវត្តកិច្ចការកែទម្រង់ស៊ីជម្រៅ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលជាឧបករណ៍ដ៏ចាំបាច់សម្រាប់ជំរុញ និងវាស់វែងសមិទ្ធកម្ម ជាពិសេសតាមដាន និងវាយតម្លៃ ព្រមទាំងការកែតម្រូវការអនុវត្ត គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅសម្រេចបាននូវគោលបំណងគោលនយោបាយ ក៏ដូចជាពង្រឹងគណនេយ្យភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធចំពោះរាជរដ្ឋាភិបាល ហើយម្ខាងទៀត ជានាការកសាង និងពង្រឹងមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសំដៅឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានកំពុងជំរុញនិងលើកទឹកចិត្ត បណ្តាក្រសួងស្ថាប័នរៀបចំចងក្រងប្រព័ន្ធទិន្នន័យដែលអាចជឿទុកចិត្តបាន រួមជាមួយនឹងកិច្ចពិភាក្សាក្នុងស្មារតីបើកចំហរនិងស្ថាបនា ដើម្បីរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវការរៀបចំវិធានការគោលនយោបាយ ក៏ដូចជាការអនុវត្តការងារក្នុងការដ្ឋានកែទម្រង់នៅក្នុងវិស័យមួយចំនួន រួមមាន ការផ្តល់សេវាសាធារណៈ ការរៀបចំផែនការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ កិច្ចគាំពារសង្គម អភិបាលកិច្ច និងបរិវត្តកម្មឌីជីថល ជាដើម។ល។

**ក្នុងន័យដូចខាងលើនេះ ខ្ញុំសូមចូលរួមផ្តល់នូវអនុសាសន៍ចំនួន៨ចំណុច ជូនអង្គពិធីនិងតួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចគោលនយោបាយប្រកបដោយបរិយាបន្នដូចខាងក្រោម៖**

**ជំរុញការបង្កើតសហគមន៍ស្រាវជ្រាវ (Research Community)**

ដោយផ្តោតសំខាន់លើការបង្កើតបណ្តាញទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវ ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរចំណេះដឹង ទិន្នន័យ និងការពិភាក្សាផ្លាស់ប្តូរយោបល់លើគោលនយោបាយទាំងនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ លើវិស័យ ឬមូលបទជាក់លាក់ណាមួយដែលគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងអាទិភាពនានារបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី បាននិងកំពុងរៀបចំក្របខ័ណ្ឌទស្សនាទានគម្រោងនៃការបង្កើតសហគមន៍ស្រាវជ្រាវនេះ ហើយខ្ញុំសូមអំពាវនាវឱ្យដៃគូមានការពាក់ព័ន្ធបន្តជួយរៀបចំការងារនេះឱ្យបានជាផ្លែផ្កានៅពេលអនាគតខាងមុខ។

**លើកទឹកចិត្ត ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល**

បង្កើនកិច្ចសហការជាមួយស្ថាប័នស្រាវជ្រាវ ស្ថាប័នអប់រំ និងដៃគូអភិវឌ្ឍនានាក្នុងកិច្ចការស្រាវជ្រាវ គិតគូរអំពីចក្ខុវិស័យជាយុទ្ធសាស្ត្រ និងធ្វើការវិភាគលើសេណារីយ៉ូផ្សេងៗ (scenario analysis) ក្នុងការលើកកម្ពស់គុណភាពទាំងទម្រង់ និងទាំងជម្រៅខ្លឹមសារ នៃការងាររៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍នានា ជាពិសេសដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ ដាក់វិធានការដែលអាចធ្វើបាន ហើយធ្វើឱ្យមានប្រសិទ្ធភាព និងលទ្ធផលសំដៅដោះស្រាយបញ្ហាឱ្យចំរឿងតាមរយៈការសិក្សាស្រាវជ្រាវផ្អែកលើទិន្នន័យ និងភស្តុតាង។

**កសាងនិងពង្រឹងសមត្ថភាពរបស់អ្នករៀបចំគោលនយោបាយ**

អ្នកស្រាវជ្រាវ និងអ្នកពាក់ព័ន្ធទាំងអស់ តាមរយៈការរៀបចំកម្មវិធីបណ្តុះបណ្តាល និងវេទិកាផ្លាស់ប្តូរ ព្រមទាំងការប្រើប្រាស់ច្ចេកវិទ្យាទំនើប ឬបញ្ញាសិប្បនិម្មិតដើម្បីវិភាគឱ្យកាន់តែស៊ីជម្រៅនិងលឿន សំដៅបង្កើនចំណេះដឹង និងការស្រាវជ្រាវនិងប្រមូលទិន្នន័យប្រកបដោយក្រមសីលធម៌ និងជំនាញវិភាគផ្អែកលើទិន្នន័យ និងភស្តុតាង ហើយជាពិសេសនៅតាមវិស័យអាទិភាពនៃការអភិវឌ្ឍ។

**ធានានូវការប្រើប្រាស់ទិន្នន័យ-ស្ថិតិ ប្រកបដោយសុចរិតភាព (The Use of Data with Integrity)**

តាមរយៈការលើកកម្ពស់គុណភាព ភាពត្រឹមត្រូវ ភាពពេញលេញ សង្គតិភាព និងភាពអាចជឿជាក់បានចាប់តាំងពីការប្រមូលរហូតដល់ការចងក្រងទុកសម្រាប់សិក្សា និងវិភាគ ដែលទាមទារឱ្យមាននូវប្រព័ន្ធការងារត្រឹមត្រូវ និងក្របខណ្ឌនិងយន្តការគ្រប់គ្រងចំណេះដឹងផ្ទៃក្នុងច្បាស់លាស់ (Internal Knowledge Management Framework and Mechanism)។

| | |
|---|---|
| **ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ** | ជាពិសេសមជ្ឈមណ្ឌលផ្ទុកទិន្នន័យ (Data Center) ឬទិន្នន័យធំ (Big data) តាមរយៈការរៀបចំនូវស្តង់ដានៃការគ្រប់គ្រងទិន្នន័យ និងការចែករំលែកទិន្នន័យ រវាងក្រសួង ស្ថាប័ននានា ព្រមទាំងកសាង និងធានាឱ្យបាននូវប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលមានលក្ខណៈអាចស្វែងរកបាន (findable) អាចចូលដំណើរការបាន (accessible) អន្តរប្រតិបត្តិការ (interoperable) និងអាចប្រើឡើងវិញបាន (reusable)។ |
| **លើកកម្ពស់កិច្ចសហការតាមក្រសួង-ស្ថាប័ន និងអន្តរក្រសួង-ស្ថាប័ន** | ដើម្បីកាត់បន្ថយគម្លាតរវាងតម្រូវការទិន្នន័យដែលកំពុងកើនឡើង និងការផ្តល់និងចែករំលែកនូវទិន្នន័យដែលអាចជឿទុកចិត្តបាន តាមរយៈការបង្កើតវេទិកាតួអង្គពាក់ព័ន្ធ (multi-stakeholder dialogue platforms) ស្តីពីការរៀបចំគោលនយោបាយប្រកបដោយបរិយាបន្នដែលរួមមានតំណាងមកពីក្រសួង-ស្ថាប័នសំខាន់ៗ ស្ថាប័នស្រាវជ្រាវ វិស័យឯកជន និងសង្គមស៊ីវិល។ |
| **បញ្ជ្រាបកិច្ចពិភាក្សាប្រកបដោយបរិយាបន្ន ទៅក្នុងវដ្តនៃការរៀបចំគោលនយោបាយ** | ដែលមានការចូលរួមពីភាគីចម្រុះ មិនថាតួអង្គរដ្ឋ វិស័យឯកជន ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល ឬ សហគមន៍មូលដ្ឋានគោលដៅតាមរយៈការរៀបចំនូវវេទិកាពិគ្រោះយោបល់ ឬយន្តការផ្តល់មតិត្រឡប់ (feedback mechanism) ឬវេទិកាសាធារណៈនានា ដែលធានានូវការចូលរួមរបស់ភាគីពាក់ព័ន្ធនៅគ្រប់ដំណាក់កាលនៃការរៀបចំគោលនយោបាយ។ ការណ៍នេះនឹងបង្កើនទំនុកចិត្តរវាងសាធារណជន អ្នករៀបចំគោលនយោបាយ និងអ្នកស្រាវជ្រាវ ក៏ដូចជាទាក់ទាញការចូលរួមអនុវត្តពីភាគីពាក់ព័ន្ធទាំងអស់។ |
| **បន្តពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងការបន្តប្តេជ្ញាចិត្ត** | លើការធ្វើការសម្រេចចិត្តជាគោលនយោបាយដែលផ្អែកលើភស្តុតាង ដើម្បីអាចឆ្លើយតបបាននឹងតម្រូវការជាក់ស្តែងរបស់សង្គម ប្រកបដោយសមធម៌ និងការបង្កើតអនាគតមួយឱ្យកាន់តែល្អប្រសើររុងរឿងបន្ថែមទៀតសម្រាប់ប្រជាជនទាំងអស់គ្នា។ |

ដូច្នេះ ការងារដែលត្រូវធ្វើទាំង៨ចំណុចនេះមានទំហំធំធេង នឹងត្រូវដំណើរការយូរអង្វែងដើម្បីបង្កើតបានវប្បធម៌ផ្សារភ្ជាប់ចំណេះដឹង និងការធ្វើគោលនយោបាយ ដោយផ្អែកលើការសិក្សាស្រាវជ្រាវ និងទិន្នន័យដែលមានគុណភាពខ្ពស់។ ខ្ញុំសង្ឃឹមថា កម្មវិធីពន្លកចំណេះនឹងបន្តធ្វើជាតួអង្គសំខាន់បន្តទៀតក្នុងរយៈពេលវែងទៅមុខ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ខ្ញុំសូមគូសបញ្ជាក់សារជាថ្មីថា ការធ្វើការសម្រេចចិត្តជាគោលនយោបាយប្រកបដោយបរិយាបន្ន និង ផ្អែកលើភស្តុតាង គឺពិតជាមានសារៈសំខាន់សម្រាប់ការរៀបចំគោលនយោបាយប្រកបដោយភាពគ្រប់ជ្រុងជ្រោយដោយការផ្សារភ្ជាប់ជាមួយចំណេះដឹង និងការពិភាក្សារវាងរដ្ឋាភិបាលជាមួយភាគីពាក់ព័ន្ធផ្សេងៗ រួមទាំងប្រជាពលរដ្ឋ ស្ថាប័នស្រាវជ្រាវនិងអប់រំ អ្នកស្រាវជ្រាវក្នុង និងក្រៅស្រុក វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។

ការណ៍នេះនឹងបង្កើតបាននូវបច្ច័យវិជ្ជមានខ្ពស់ដល់សង្គម តាមរយៈការប្រមូលបាននូវចំណេះដឹងបទពិសោធ ស្ថានភាពជាក់ស្តែង ទស្សនៈ និងមតិយោបល់នានា ដែលជាមូលដ្ឋាននៃការបង្កើតការយល់ដឹងភាពជាម្ចាស់ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ យើងអាចត្រៀមខ្លួនបង្កើនភាពរហ័សរហួន និងស្មារតីនវានុវត្តន៍ដែលចាំបាច់ក្នុងការធានាភាពជាម្ចាស់ ភាពធន់ និងការអភិវឌ្ឍប្រទេសជាតិរបស់ខ្លួន។

ជាចុងក្រោយ ខ្ញុំក៏សូមយកឱកាសនេះដើម្បីគូសបញ្ជាក់អំពីការថ្លែងអំណរគុណ និងការវាយតម្លៃខ្ពស់ពីរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ជូនរដ្ឋាភិបាលអូស្ត្រាលីដែលបានផ្តល់អាហារូបករណ៍ជាបន្តបន្ទាប់ ដល់និស្សិតនៃប្រទេសកម្ពុជា ជាពិសេសក្នុងកម្រិតក្រោយបរិញ្ញាបត្រជាហូរហែ គួបផ្សំជាមួយនឹងការបន្តគាំទ្រដល់ស្ថាប័នស្រាវជ្រាវនៅប្រទេសកម្ពុជាដែលពិតជាបានរួមចំណែកយ៉ាងសំខាន់ ក្នុងការពង្រឹងសមត្ថភាពរបស់កម្ពុជាក្នុងការស្រាវជ្រាវ ការអភិវឌ្ឍ និងការរៀបចំគោលនយោបាយឱ្យកាន់តែបានល្អប្រសើរ និងមានប្រសិទ្ធភាព។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណសារជាថ្មីចំពោះស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា កម្មវិធីពន្លកចំណេះ និងអង្គការមូលនិធិអាស៊ី សម្រាប់ការរៀបចំវេទិកាគោលនយោបាយដ៏មានសារៈសំខាន់នេះឡើង តំណាងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន វិទ្យាស្ថានស្រាវជ្រាវ ស្ថាប័នអប់រំ និងអង្គការសង្គមស៊ីវិល ដែលមានវត្តមាននៅទីនេះ។ ខ្ញុំក៏សូមលើកទឹកចិត្តឱ្យអង្គវេទិកាទាំងមូលចូលរួមពិភាក្សានិងផ្តល់មតិយោបល់ឱ្យបានផុសផុល សម្រាប់ជាមូលដ្ឋានក្នុងការប្រែក្លាយចំណុចពិភាក្សានៅពេលនេះ ឱ្យទៅជាសកម្មភាពជាក់ស្តែង ជាពិសេសនឹងបង្កើតឱ្យមានការសន្ទនាដ៏មានអត្ថន័យ បំផុសគំនិតច្នៃប្រឌិត និងនវានុវត្តន៍ និងពង្រឹងភាពជាដៃគូឱ្យកាន់តែប្រសើរឡើង ដើម្បីជាមូលដ្ឋានដល់ការរៀបចំគោលនយោបាយជាតិដែលបម្រើដល់ប្រយោជន៍ និងឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គវេទិកាទាំងមូល សូមមានសុខភាពល្អបរិបូណ៌ សុភមង្គលក្នុងក្រុមគ្រួសារ និងទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមប្រកបដោយ ពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## សូមអរគុណ!

# ពិធីសម្ពោធឯកសារគោលការណ៍ណែនាំ៖ សៀវភៅណែនាំស្តីពី គុណភាពនៃការស្រាវជ្រាវ និងគោលការណ៍ណែនាំស្តីពីការពិភាក្សាប្រកប ដោយបរិយាបន្ន

*លោកស្រី Dolgion Aldar*
*នាយិកាកម្មវិធីពន្លកចំណេះ*
*អង្គការមូលនិធិអាស៊ី*

នាងខ្ញុំពិតជាមានកិត្តិយសយ៉ាងក្រៃលែងក្នុងការណែនាំ *ឯកសារគោលការណ៍ណែនាំរបស់កម្មវិធីពន្លកចំណេះ* ដែលយើងកំពុងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃនេះ។ គោលការណ៍ណែនាំទាំងនេះ គឺជាជំហានដ៏សំខាន់មួយក្នុងការឈានទៅមុខពង្រឹងវិស័យស្រាវជ្រាវនៅកម្ពុជា។

អ្វីដែលកំណត់ថាវិស័យមួយជាវិស័យមួយបាន គឺនៅពេលដែលតួអង្គ និងស្ថាប័ននៅក្នុងសកម្មភាពទាំងនោះមានបទដ្ឋាន និងការអនុវត្តរួម។ ដូចគ្នាទៅនឹងវិស័យសុខាភិបាលត្រូវបានកំណត់ដោយស្តង់ដារវេជ្ជសាស្ត្រ និងវិស័យសារព័ត៌មានដោយក្រមសីលធម៌សារព័ត៌មានដែរ វិស័យស្រាវជ្រាវនៅកម្ពុជាត្រូវការបទដ្ឋាន និងស្តង់ដារផ្ទាល់ខ្លួន ដើម្បីធានាថាការស្រាវជ្រាវ និងកិច្ចពិភាក្សាមានភាពគួរឱ្យទុកចិត្តប្រកបដោយក្រមសីលធម៌ និងបរិយាបន្ន។

សៀវភៅណែនាំស្តីពីការស្រាវជ្រាវនេះ ផ្តល់នូវឧបករណ៍ជាក់ស្តែងសម្រាប់អនុវត្តការស្រាវជ្រាវប្រកបដោយភាពម៉ត់ចត់ និងក្រមសីលធម៌ ចាប់ពីការរចនាការស្រាវជ្រាវ (research design) និងការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ (informed consent) រហូតដល់ការប្រមូលទិន្នន័យ និងការទំនាក់ទំនង។

គោលការណ៍ណែនាំស្តីពីការពិភាក្សាប្រកបដោយបរិយាបន្ន បំពេញបន្ថែមលើចំណុចនេះ ដោយផ្តល់នូវការណែនាំច្បាស់លាស់ និងជាជំហានៗ អំពីរបៀបដើម្បីធានាថាសំឡេងចម្រុះត្រូវបានស្តាប់ឮ និងគោរពនៅក្នុងកិច្ចសន្ទនាគោលនយោបាយ។

ប្រសិនបើឯកសារទាំងនេះត្រូវបានប្រើប្រាស់ និងយកទៅធ្វើជាឯកសារយោងដោយអ្នកពាក់ព័ន្ធសំខាន់ៗ នោះគោលការណ៍ណែនាំទាំងពីរនេះជួយកំណត់នូវបទដ្ឋាន និងការអនុវត្តរួម ដែលនឹងធ្វើឱ្យវិស័យស្រាវជ្រាវរបស់កម្ពុជាកាន់តែរឹងមាំ កាន់តែមានបរិយាបន្ន និងកាន់តែមានផលជះ ។




យើងក៏មានគោលការណ៍ណែនាំមួយច្បាប់ទៀត ដែលកំពុងត្រូវបានបង្កើត ដោយផ្តោតលើការធានានូវផាសុកវត្ថុ (accessibility) ទាំងនៅក្នុងដំណើរការស្រាវជ្រាវ ទាំងក្នុងកិច្ចពិភាក្សា។

ដើម្បីធ្វើឱ្យធនធានទាំងនេះងាយស្រួលប្រើប្រាស់បានយ៉ាងទូលំទូលាយ តាមដែលអាចធ្វើទៅបាន គ្រប់គ្នាអាចទាញយកឯកសារគោលការណ៍ណែនាំទាំងនេះ។[២] ឯកសារទាំងនេះក៏នឹងត្រូវបានចែករំលែកតាមរយៈប្រព័ន្ធតេឡេក្រាមរបស់កម្មវិធីពន្លកចំណេះផងដែរ ដើម្បីឱ្យដៃគូ និងសហការីនៅទូទាំងប្រទេសអាចចូលទទួលបាន និងប្រើប្រាស់ឯកសារទាំងនេះបានយ៉ាងងាយស្រួល។ ហើយនាពេលខាងមុខ យើងនឹងមានឯកសារទាំងនេះបកប្រែជាភាសាខ្មែរផងដែរ។

ថ្ងៃនេះ នាងខ្ញុំសូមគូសបញ្ជាក់ថាគោលការណ៍ណែនាំទាំងនេះមិនមែនសរសេរឡើងដោយអ្នកជំនាញបច្ចេកទេសមួយចំនួន ដោយឯកឯងនោះទេ។ ឯកសារទាំងនេះត្រូវបានរៀបរៀងឡើង ដោយក្រុមការងារ ដែលមានសមាជិកពោរពេញដោយការប្តេជ្ញាចិត្តប្រហែល ១០រូប មកពីដៃគូស្រាវជ្រាវ និងដៃគូសង្គមស៊ីវិលរបស់យើង និងត្រូវបានពិនិត្យដោយអ្នកជំនាញបច្ចេកទេសដើម្បីផ្តល់ធាតុចូល។ ការប្តេជ្ញាចិត្តរបស់ពួកគេ បានធានាថាគោលការណ៍ណែនាំទាំងនេះមានលក្ខណៈជាក់ស្តែង មានមូលដ្ឋានច្បាស់លាស់ និងងាយស្រួលប្រើប្រាស់បាន សម្រាប់ការប្រើប្រាស់ជាក់ស្តែងនៅក្នុងបរិយាកាសគោលនយោបាយរបស់កម្ពុជា។

យើងខ្ញុំចង់យកឱកាសនេះថ្លែងអំណរគុណដល់ក្រុមការងារ ចំពោះការរួមចំណែករបស់ពួកគេ និងទទួលស្គាល់ថាគោលការណ៍ណែនាំទាំងនេះពិតជាសមិទ្ធផលសមូហភាពពិតប្រាកដមួយ។

---

[២] សៀវភៅណែនាំស្តីពីគុណភាពនៃការស្រាវជ្រាវ៖ https://policypulse.org/publications/references/12404/
គោលការណ៍ណែនាំស្តីពីការពិភាក្សាប្រកបដោយបរិយាបន្ន៖ https://policypulse.org/publications/references/guidelines-for-inclusive-dialogue/

# ការឆ្លុះបញ្ចាំងពីសមាជិកក្រុមការងារ

*លោក មាន វិបុលរតនៈ*
*អង្គការជនពិការកម្ពុជា*

ខ្ញុំមានអារម្មណ៍សប្បាយរីករាយ និងរំភើបឥតឧបមា ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការរៀបចំគោលការណ៍ណែនាំនេះ ក្រោមកម្មវិធីពន្លកចំណេះ។ គោលការណ៍ណែនាំទាំងនេះ អាចមានប្រយោជន៍សម្រាប់អ្នកចូលរួមនៅទីនេះ និងសម្រាប់អ្នកដទៃទៀតដែលកំពុងធ្វើការស្រាវជ្រាវ ឬគ្រោងនឹងធ្វើការស្រាវជ្រាវ និងចែករំលែកលទ្ធផលរកឃើញរបស់ពួកគេ។

សម្រាប់អ្នកស្រាវជ្រាវ ប្រហែលជាមានឯកសារច្រើនរួចទៅហើយ ប៉ុន្តែកម្មវិធីពន្លកចំណេះបានរៀបចំគោលការណ៍ណែនាំទាំងពីរនេះ ដើម្បីគាំទ្រដល់ការស្រាវជ្រាវ និងកិច្ចពិភាក្សាប្រកបដោយបរិយាបន្ននាពេលអនាគត។ សម្រាប់អ្នកដែលកំពុងត្រៀមចាប់ផ្តើមការស្រាវជ្រាវ គោលការណ៍ណែនាំទាំងនេះអាចជួយតម្រង់ទិសដៅដំណើរការស្រាវជ្រាវ និងការរៀនសូត្ររបស់ពួកគេ។

គោលការណ៍ណែនាំទាំងនេះ មិនមែនល្អឥតខ្ចោះនោះទេ ប៉ុន្តែវាជាចំណុចចាប់ផ្តើមដ៏សំខាន់មួយ ជាការវិនិយោគក្នុងការជំរុញកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវ ក៏ដូចជាស្ពានតភ្ជាប់អ្នកស្រាវជ្រាវទៅនឹងក្រុម



ដែលមិនសូវមានភាពតំណាងនៅក្នុងការអភិវឌ្ឍសង្គម។ សូមកត់សម្គាល់ថា គោលការណ៍ណែនាំទាំងនេះគឺជាឯកសាររស់ មានន័យថា ឯកសារទាំងនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព និងកែប្រែតាមពេលវេលា ដើម្បីឱ្យសមស្របទៅនឹងបរិបទថ្មីៗ។

ក្នុងនាមជាជនមានពិការភាពកាយសម្បទា និងជាសំឡេងតំណាងឱ្យជនមានពិការភាព ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ទិន្នន័យ និងបទពិសោធចម្រុះនៅក្នុងការស្រាវជ្រាវនឹងត្រូវបានទទួលស្គាល់ និងប្រើប្រាស់ដើម្បីជួយបំពេញសិទ្ធិរបស់យើង ស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងច្បាប់លើកកម្ពស់សិទ្ធិជនមានពិការភាពរបស់កម្ពុជា។ ជាចុងក្រោយ ខ្ញុំចង់និយាយថា មិនត្រូវទុកនរណាម្នាក់ចោលឡើយនៅក្នុងការស្រាវជ្រាវ ឬកិច្ចពិភាក្សា សូមធ្វើការជាមួយយើងខ្ញុំ និងតស៊ូមតិដើម្បីលើកកម្ពស់សិទ្ធិរបស់យើងខ្ញុំ។



# កិច្ចពិភាក្សាពេញអង្គ៖ តួនាទី និងអនាគតនៃវិស័យស្រាវជ្រាវកម្ពុជានៅក្នុងការពង្រឹងដំណើរការគោលនយោបាយប្រកបដោយបរិយាបន្ន

វិស័យស្រាវជ្រាវនៅកម្ពុជាកាន់តែមានសកម្មភាពខ្លាំងក្លា និងមានការរីកចម្រើនជាលំដាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ គ្របដណ្ដប់លើស្ថាប័នសិក្សាគោលនយោបាយ  សាកលវិទ្យាល័យ  វិទ្យាស្ថានស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងក្រសួងស្ថាប័នរដ្ឋ វិស័យនេះកំពុងដើរតួនាទីកាន់តែសំខាន់ក្នុងការផលិត និងចែករំលែកការស្រាវជ្រាវ និងទិន្នន័យដ៏មានតម្លៃ។

ទោះបីជាមានវឌ្ឍនភាពបែបនេះក្ដី បញ្ហាប្រឈមនៅតែមាន។ បរិយាកាសគោលនយោបាយ និងការស្រាវជ្រាវ នៅតែមានភាពបែកខ្ញែកគ្នានៅឡើយ ទិន្នន័យស្រាវជ្រាវមិនមែនសុទ្ធតែងាយស្រួលយល់ ឬងាយស្រួលប្រើប្រាស់នោះទេ ហើយសំឡេងនៃក្រុមដែលត្រូវបានផាត់ចេញ នៅតែបន្តមានតិចតួច នៅក្នុងដំណើរការស្រាវជ្រាវ និងការតាក់តែងគោលនយោបាយនានា។

ស្ថានភាពទាំងនេះកំពុងលេចចេញឱ្យឃើញច្បាស់បន្តិចម្ដងៗ នៅពេលដែលកម្ពុជាកំពុងឆ្លងកាត់របត់គោលនយោបាយយ៉ាងឆាប់រហ័ស និងនៅពេលរាជរដ្ឋាភិបាល ដែគូអភិវឌ្ឍន៍ និងសង្គមទាំងមូលកាន់តែត្រូវការទិន្នន័យដែលគួរឱ្យទុកចិត្ត។ យុទ្ធសាស្ត្រជាតិសំខាន់ៗ ដូចជា យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ ផែនការនារីរតនៈទី៦ និងផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុដំណាក់កាលទី៣ (NDC) ៣.០ ស្ដីពីសកម្មភាពអាកាសធាតុ បានបង្ហាញពីភាពបន្ទាន់នៃអភិក្រមដែលកាន់តែមានបរិយាបន្ន គណនេយ្យភាព និងផ្អែកលើភស្តុតាង។ ទន្ទឹមនឹងនេះ របៀបវារៈស្រាវជ្រាវជាតិឆ្នាំ២០២៥ បញ្ជាក់ពីតួនាទីនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការអភិវឌ្ឍជាតិ ព្រមទាំងបើកលំហសម្រាប់កិច្ចសហការរវាងរាជរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ និងសង្គមស៊ីវិល។




សម្រាប់ពេលខាងមុខ សំណួរសំខាន់គឺថាតើស្ថាប័នស្រាវជ្រាវរបស់កម្ពុជា អាចសម្របខ្លួនទៅនឹងភាពមិនប្រាកដប្រជា ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ ភាពប្រែប្រួលនៃសេដ្ឋកិច្ច និងការផ្លាស់ប្តូរសក្តានុពលសង្គមកម្រិតណា ដើម្បីក្លាយខ្លួនជាដៃគូដែលមានបរិយាបន្ន និងគួរឱ្យទុកចិត្តនៅក្នុងការតាក់តែងគោលនយោបាយ។ ការពង្រឹងកិច្ចសហការរវាងអ្នកតាក់តែងគោលនយោបាយ អ្នកស្រាវជ្រាវ និងសហគមន៍ គឺចាំបាច់ណាស់ ដើម្បីធានាថាយុទ្ធសាស្ត្រជាតិផ្តល់ផលប្រយោជន៍ពិតប្រាកដ ដល់ប្រជាជនកម្ពុជាគ្រប់រូប រួមទាំងស្ត្រី យុវជន ជនជាតិដើមភាគតិច ជនមានពិការភាព និងក្រុមដែលមិនសូវមានភាពតំណាងផ្សេងទៀត។

កិច្ចពិភាក្សាតុមូលពេញអង្គនេះ មានគោលបំណងស្វែងយល់ពីតួនាទី និងអនាគតនៃវិស័យស្រាវជ្រាវនៅកម្ពុជា ក្នុងការជំរុញដំណើរការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន និងផ្អែកលើទិន្នន័យ។ កិច្ចពិភាក្សានេះបានពិនិត្យមើលគម្លាតរវាងតម្រូវការដែលកំពុងកើនឡើងសម្រាប់ទិន្នន័យស្រាវជ្រាវ និងការផ្គត់ផ្គង់ការស្រាវជ្រាវនៅមានកម្រិតទាំងទាន់ពេលវេលា គួរឱ្យទុកចិត្តបាន និងងាយស្រួលប្រើប្រាស់ ស្របពេលដែលរបៀបវារៈអភិវឌ្ឍន៍កំពុងប្រែប្រួលនៅកម្ពុជា។ វាគ្មិនបានកំណត់យុទ្ធសាស្ត្រជាក់ស្តែង ដើម្បីពង្រឹងទំនាក់ទំនងរវាងការស្រាវជ្រាវ និងគោលនយោបាយ ជាពិសេសការរួមបញ្ចូលសំឡេងនៃក្រុមត្រូវបានផាត់ចេញ អោយកាន់តែប្រសើរទៅក្នុងដំណើរការស្រាវជ្រាវ និងការតាក់តែងគោលនយោបាយ។

# សង្ខេបកិច្ចពិភាក្សា

វិស័យស្រាវជ្រាវនៅកម្ពុជាបច្ចុប្បន្ន កំពុងដើរតួនាទីយ៉ាងច្បាស់លាស់ក្នុងការសម្រេចគោលនយោបាយជាតិ។ ស្ថាប័នសិក្សាគោលនយោបាយ សាកលវិទ្យាល័យ ក្រសួងស្ថាប័នរដ្ឋ និងក្រុមសង្គមស៊ីវិល កំពុងផលិតការស្រាវជ្រាវកាន់តែច្រើន និងចែករំលែកលទ្ធផលទាំងនោះជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្ត។ កិច្ចពិភាក្សាតុមូលនេះបានរំលេចពីរបៀបដែលការស្រាវជ្រាវត្រូវបានប្រើប្រាស់ក្នុងការអនុវត្តជាក់ស្តែង បញ្ហាប្រឈមដែលនៅសេសសល់ និងអ្វីដែលត្រូវធ្វើដើម្បីឱ្យការតាក់តែងគោលនយោបាយកាន់តែមានបរិយាបន្ន និងផ្អែកលើទិន្នន័យ។

នៅក្នុងវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រមូលផ្តុំមុខងារស្រាវជ្រាវឱ្យស្ថិតនៅក្រោមឆ័ត្រតែមួយ ដើម្បីពង្រឹងការសម្របសម្រួល។ ទិន្នន័យពីការសិក្សាក្នុងស្រុកកំពុងជួយតម្រង់ទិសគោលនយោបាយ ដូចជាយុទ្ធសាស្ត្រប្រកួតប្រជែងក្នុងខេត្តពោធិ៍សាត់ ដែលគាំទ្រដោយកម្មវិធីពន្លកចំណេះ និងគម្រោងសាកល្បងស្តីពីការធានារ៉ាប់រងកសិកម្មជាមួយអង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ជាដើម។ គោលនយោបាយនានាកាន់តែមានភាពបត់បែន និងត្រូវបានធ្វើបច្ចុប្បន្នភាពនៅពេលមានការស្រាវជ្រាវថ្មីៗ។

នៅក្នុងវិស័យអប់រំ ការស្រាវជ្រាវក៏ជាស្នូលនៃកំណែទម្រង់ផងដែរ។ ក្រសួងអប់រំ យុវជន និងកីឡាបានផ្តួចផ្តើមគំរូ «សាលារៀនជំនាន់ថ្មី» ដែលបានចាប់ផ្តើមជាគម្រោងសាកល្បងតូចមួយ ហើយក្រោយមកត្រូវបានពង្រីកទូទាំងប្រទេសនៅពេលដែលវាបង្ហាញពីប្រសិទ្ធភាព។ ស្តង់ដារបណ្តុះបណ្តាលគ្រូបង្រៀន និងវិទ្យាស្ថានគរុកោសល្យ ក៏ត្រូវបានធ្វើបច្ចុប្បន្នភាពដោយផ្អែកលើលទ្ធផលពីការសិក្សាក្នុងស្រុកផងដែរ។ វាគ្មិនបានសង្កត់ធ្ងន់ថា ការស្រាវជ្រាវដែលធ្វើឡើងដោយអ្នកជំនាញកម្ពុជា មានភាពអាចទុកចិត្តបាន និងពាក់ព័ន្ធជាងការចម្លងគំរូពីបរទេស។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានកត់សម្គាល់ថា ការចូលប្រើប្រាស់ការស្រាវជ្រាវនៅមានកម្រិត ហើយត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីធ្វើឱ្យលទ្ធផលស្រាវជ្រាវមានភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់។ វេទិកានានាដូចជា គេហទំព័រ Policy Pulse របស់កម្មវិធីពន្លកចំណេះត្រូវបានកោតសរសើរចំពោះការជួយធ្វើឱ្យភស្តុតាងកាន់តែមានភាពទូលំទូលាយ។




វាគ្មិនបានយល់ស្របថា បរិបទគោលនយោបាយកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ជាមួយនឹងបញ្ហាប្រឈមថ្មីៗដែលកំពុងលេចឡើង ដូចជា ការប្រែប្រួលអាកាសធាតុ ការផ្លាស់ប្តូរសេដ្ឋកិច្ច និងបញ្ញាសិប្បនិម្មិត (AI)។ ខណៈពេលដែលបញ្ញាសិប្បនិម្មិតអាចសង្ខេបព័ត៌មានដែលមានស្រាប់ វាមិនអាចជំនួសតម្លៃនៃការស្រាវជ្រាវក្នុងស្រុកដែលឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងរបស់សហគមន៍ និងបទពិសោធរស់នៅរបស់ប្រជាជនបានឡើយ។ ដើម្បីធានាបាននូវការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន ការស្តាប់ផ្ទាល់ពីស្ត្រី យុវជន ជនជាតិដើមភាគតិច




ជនមានពិការភាព និងក្រុមដែលមិនសូវទទួលបាន ការយកចិត្តទុកដាក់ផ្សេងទៀត គឺជារឿងដែលសំខាន់ និងចាំបាច់។

ថ្វីបើជាមានវឌ្ឍនភាពយ៉ាងណាក៏ដោយ ស្ថាប័នស្រាវជ្រាវនៅតែប្រឈមមុខនឹងឧបសគ្គ។ ការទទួលបានទិន្នន័យពីរដ្ឋាភិបាលសម្រាប់ការស្រាវជ្រាវនៅមានកម្រិតទាប ការផ្តល់មូលនិធិជាញឹកញាប់អាស្រ័យលើអាទិភាពរបស់ម្ចាស់ជំនួយ ហើយលទ្ធផលស្រាវជ្រាវមិនតែងតែត្រូវបានបង្ហាញក្នុងទម្រង់ដែលអ្នកតាក់តែងគោលនយោបាយ ឬសាធារណជន អាចយកទៅប្រើប្រាស់បានយ៉ាងងាយស្រួលនោះទេ។ ស្ថាប័នសិក្សាគោលនយោបាយ ក៏ប្រឈមមុខនឹងសំណួរអំពីឯករាជ្យភាព នៅពេលធ្វើការស្រាវជ្រាវអំពីបញ្ហារសើប។ វាគ្មិនបានអំពាវនាវឱ្យមានការបោះពុម្ពផ្សាយជាភាសាខ្មែរបន្ថែមទៀត ព្រមជាមួយនឹងឯកសារសង្ខេបគោលនយោបាយខ្លីៗ និងក្រាហ្វិកដែលងាយស្រួលយល់។

បរិយាបន្នគឺជាប្រធានបទសំខាន់នៅក្នុងកិច្ចពិភាក្សាទាំងមូល។ ការស្រាវជ្រាវបែបចូលរួម និងការស្រាវជ្រាវសកម្មភាពបែបស្ត្រីនិយម ត្រូវបានលើកឡើងថាជាវិធីសាស្ត្រ មានការចូលរួមពីសហគមន៍ តាំងពីដើមដំបូងនៃការសិក្សា។ ការចូលរួមរបស់ជនមានពិការភាព ក្នុងនាមជាជំនួយការស្រាវជ្រាវ និងជាអ្នកស្រាវជ្រាវរួមគ្នា គឺជាវិធីមួយផ្សេងទៀត ដើម្បីធ្វើឱ្យទិន្នន័យស្រាវជ្រាវកាន់តែមានលក្ខណៈតំណាង។ វិធានការការពារផ្នែកក្រមសីលធម៌ ដូចជាការយល់ព្រម ផ្អែកតាមព័ត៌មានគ្រប់ជ្រុងជ្រោយ និងការគ្រប់គ្រងទិន្នន័យប្រកបដោយសុវត្ថិភាពក៏មានសារៈសំខាន់ផងដែរ។




កិច្ចពិភាក្សាក៏បានកត់សម្គាល់ពីសារៈសំខាន់នៃឧបករណ៍ជាក់ស្តែងដើម្បីផ្សារភ្ជាប់អ្នកស្រាវជ្រាវ និងអ្នកតាក់តែងគោលនយោបាយ។ គោលការណ៍ណែនាំស្តីពីកិច្ចពិភាក្សាគោលនយោបាយប្រកបដោយបរិយាបន្ន ដែលត្រូវបានរៀបចំឡើងក្រោម កម្មវិធីពន្លកចំណេះត្រូវបានគេមើលឃើញថាជាធនធានដ៏មានតម្លៃសម្រាប់ពង្រីកការចូលរួម និងបង្កើនគណនេយ្យភាព។ ក្រសួងស្ថាប័ននានាកំពុងចាប់ផ្តើមប្រើប្រាស់វិធីសាស្ត្របែបនេះ ដើម្បីពង្រឹងទំនាក់ទំនង និងការផ្តល់មតិត្រឡប់។ វេទិកាដែលរៀបចំជាប្រចាំ ក្រុមប្រឹក្សាស្រាវជ្រាវ និងក្រុមការងារបច្ចេកទេសក៏អាចកសាងទំនុកចិត្ត និងជួយប្រែក្លាយការស្រាវជ្រាវឱ្យទៅជាការសម្រេចចិត្តគោលនយោបាយពិតប្រាកដផងដែរ។

សម្រាប់ពេលខាងមុខ វាគ្មិនបានឯកភាពថា កម្ពុជាត្រូវការវិនិយោគបន្ថែមទៀតលើវិស័យស្រាវជ្រាវ។ នេះរួមមាន ការបង្កើតមជ្ឈមណ្ឌលទិន្នន័យជាតិដែលក្រសួងស្ថាប័ននានាចែករំលែកទិន្នន័យប្រចាំឆ្នាំ ការបង្កើតគម្រោងផ្តល់មូលនិធិប្រកួតប្រជែងសម្រាប់ការស្រាវជ្រាវឯករាជ្យ និងការពង្រឹងប្រព័ន្ធទិន្នន័យបើកទូលាយ។

ទន្ទឹមនឹងនេះ បណ្តាញក្នុងស្រុកដែលមានស្រាប់ ដូចជាមន្ត្រីកសិកម្មឃុំអាចជួយប្រមូលទិន្នន័យ ផ្សព្វផ្សាយលទ្ធផលរកឃើញ និងផ្តល់មតិដែលបានមកពីសហគមន៍ទៅក្នុងកិច្ចពិភាក្សាគោលនយោបាយវិញ។

## វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល

| | |
|---|---|
| **វាគ្មិនកិត្តិយស** | **ឯកឧត្តម យឹម ហ៊ីណង់**<br>*អនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* |
| | **លោកជំទាវបណ្ឌិត បូ ច័ន្ទគុលិកា**<br>*អនុរដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡា* |
| | **លោកបណ្ឌិត ម៉ក់ សិទ្ធិរិទ្ធ**<br>*អ្នកវិទ្យាសាស្ត្រ និងនាយកនៃមជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា* |
| | **លោក ច័ន្ទ សុផល**<br>*នាយកមជ្ឈមណ្ឌលសិក្សាគោលនយោបាយ* |
| | **អ្នកស្រី សាន សុផានី**<br>*ប្រធានបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ* |
| **អ្នកសម្របសម្រួលកិច្ចពិភាក្សា** | **អ្នកស្រី គ្រី ស៊ុយហៀង**<br>*នាយិកាប្រតិបត្តិ នៃអង្គការនារីដើម្បីសន្តិភាព* |

# ការពិភាក្សាស្របពេលគ្នា ១កៈ ការរួមបញ្ចូលការធ្វើចំណាកស្រុកដែលបណ្ដាលមកពីអាកាសធាតុ និងកិច្ចគាំពារសង្គមនៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

*សហការរៀបចំដោយៈ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងវិទ្យាស្ថានជាតិសង្គមកិច្ច*

ដោយសារការពឹងផ្អែកលើឧស្សាហកម្មដែលងាយរងគ្រោះដោយសារអាកាសធាតុ កម្ពុជាគឺជាប្រទេសងាយរងគ្រោះ ជាពិសេសដោយសារផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ ប្រទេសនេះប្រឈមមុខនឹងហានិភ័យសំខាន់ៗជាច្រើន ដូចជាការកើនឡើងកំដៅ ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរដែលកើតឡើងកាន់តែញឹកញាប់ និងខ្លាំងក្លា (ដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួត) និងការកើនឡើងកម្ពស់ទឹកសមុទ្រ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងបន្សាំជាបន្តបន្ទាប់ក៏ដោយ មានការព្យាករថា ការប្រែប្រួលអាកាសធាតុនឹងកាត់បន្ថយផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាចំនួន ៩,៨% នៅត្រឹមឆ្នាំ២០៥០។[៣] ភាពកាន់តែធ្ងន់ធ្ងរ និងញឹកញាប់នៃគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ បង្កការគំរាមកំហែងដល់មុខរបរចិញ្ចឹមជីវិត រួមនឹងការបាត់បង់ដីធ្លី ផ្ទះសម្បែង ដំណាំ និងសត្វពាហនៈ ហើយអាចបង្ខំឱ្យប្រជាជនងាយរងគ្រោះធ្វើចំណាកស្រុកដើម្បីរស់រានមានជីវិត។ សម្រាប់សហគមន៍ជនបទ ការធ្វើចំណាកស្រុកអាចក្លាយជាមធ្យោបាយមួយ ដើម្បីទទួលបានឱកាសសេដ្ឋកិច្ចប្រសើរជាងមុន ជួយឱ្យគ្រួសារបង្កើតប្រាក់ចំណូល ទ្រទ្រង់ជីវភាព និងរក្សាសន្តិសុខស្បៀង នៅចំពោះមុខសម្ពាធបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់អាកាសធាតុមិនត្រូវបានទទួលរងស្មើៗគ្នានោះទេ៖ ស្ត្រី កុមារ គ្រួសារក្រីក្រ និងជនជាតិភាគតិច ជារឿយៗ ប្រឈមនឹងបញ្ហាដ៏ច្រើនលើសលុបនៅក្នុងការងារ ការទទួលបានផលពីធនធានធម្មជាតិ បទដ្ឋានសង្គម ទំនាក់ទំនងយេនឌ័រ និងការសម្របខ្លួនទៅនឹងបច្ចេកវិទ្យាថ្មីៗ។[៤]

ជាការឆ្លើយតប រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចព្រមព្រៀងអាកាសធាតុអន្តរជាតិ និងបានរៀបចំគោលនយោបាយសំខាន់ៗ រួមមាន៖ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១[៥] ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (CCCSP) ២០២៤-២០៣៣[៦] យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយអព្យាក្រឹតកាបូនរយៈពេលវែង (LTS4CN)[៧] យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨[៨] និងផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុដំណាក់កាលទី៣ (NDC)[៩] ។ ខណៈពេលដែលយុទ្ធសាស្ត្រ និងផែនការទាំងនេះមានគោលបំណងដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុបង្កើនភាពធន់ និងលើកកម្ពស់ការអភិវឌ្ឍ




ប្រកបដោយចីរភាព មានការសង្កេតឃើញថា នៅមិនទាន់មានការយកចិត្តទុកដាក់លើការធ្វើចំណាកស្រុកដែលបណ្តាលមកពីអាកាសធាតុឱ្យបានគ្រប់គ្រាន់នៅឡើយទេនៅក្នុងការឆ្លើយតបការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ ស្រដៀងគ្នានេះដែរ កិច្ចគាំពារសង្គម ដែលជាឧបករណ៍គោលនយោបាយសម្រាប់កាត់បន្ថយហានិភ័យលើមុខរបរចិញ្ចឹមជីវិត កាត់បន្ថយភាពក្រីក្រ និងឆ្លើយតបចំពោះបញ្ហាវិសមភាព នៅមិនទាន់ត្រូវបានបញ្ជ្រាបដោយមានអត្ថន័យទៅក្នុងរបៀបវារៈគោលនយោបាយអាកាសធាតុរបស់កម្ពុជានៅឡើយ។

កិច្ចពិភាក្សានេះមានគោលបំណងស្វែងយល់ពីគោលនយោបាយ និងឱកាសជាក់ស្តែង ដើម្បីបញ្ចូលការធ្វើចំណាកស្រុកដែលបណ្តាលមកពីអាកាសធាតុ និងកិច្ចគាំពារសង្គម ទៅក្នុងរបៀបវារៈឆ្លើយតបនឹងអាកាសធាតុរបស់កម្ពុជា ផ្អែកលើការស្រាវជ្រាវថ្មីៗ និងបទពិសោធអន្តរវិស័យ ដើម្បីកំណត់យុទ្ធសាស្ត្រដែលអាចអនុវត្តបានសម្រាប់ការកសាងភាពធន់ប្រកបដោយបរិយាបន្ន។

---

[៣] https://climateknowledgeportal.worldbank.org/sites/default/files/2021-08/15849-WB_Cambodia%20Country%20Profile-WEB.pdf
[៤] https://www.cdri.org.kh/storage/pdf/Res%20report-Climate%20Change_11%2007%202024_low%20resolutions_1720668498.pdf
[៥] https://www.mfaic.gov.kh/files/uploads/1XK1LW4MCTK9/EN%20PENTAGONAL%20STRATEGY%20-%20PHASE%20I.pdf
[៦] https://ncsd.moe.gov.kh/resources/document/cambodia-climate-change-strategic-plan-2024-2033
[៧] https://unfccc.int/sites/default/files/resource/KHM_LTS_Dec2021.pdf
[៨] https://ncsd.moe.gov.kh/resources/document/cambodia-LTS4CN-En
[៩] https://nspc.gov.kh/Images/Cambodia%E2%80%99s%20Nationally%20Determined%20Contribution%203.0_2025_08_29_21_53_42.pdf



# បទបង្ហាញស្តីពីការសិក្សាចំនួនពីរ

ការស្រាវជ្រាវ និងកិច្ចពិភាក្សាគោលនយោបាយនាពេលថ្មីៗនេះ ផ្តោតលើចំណុចប្រសព្វនៃការប្រែប្រួលអាកាសធាតុ ការធ្វើចំណាកស្រុក និងកិច្ចគាំពារសង្គមនៅកម្ពុជា ជាពិសេសនៅតាមបណ្តាខេត្តជាប់មាត់សមុទ្រ និងតំបន់ជនបទដែលងាយរងគ្រោះ។ ការសិក្សានានាបានបង្ហាញថា ខណៈពេលដែលចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុមានការកើនឡើងគួរឱ្យកត់សម្គាល់ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន យុទ្ធសាស្ត្របន្សាំនៅតែមានកម្រិត ហើយជារឿយៗផ្អែកលើការអនុវត្តតាមបែបប្រពៃណី ជាជាងចំណេះដឹងបច្ចេកទេស។



## ការសិក្សាទី១៖ «ការប្រែប្រួលអាកាសធាតុ និងលំនាំនៃការធ្វើចំណាកស្រុក៖ លទ្ធផលស្រាវជ្រាវនៅឃុំ ក្នុងខេត្តបីផ្សេងគ្នានៃប្រទេសកម្ពុជា» អនុវត្តដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

*បទបង្ហាញដោយ៖ លោក ខាន់ ដូនីរ៉ា អ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

កម្ពុជាកំពុងប្រឈមមុខនឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ដូចជា ការកើនឡើងកំដៅ របបភ្លៀងមិនទៀងទាត់ និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរដែលកើតឡើងកាន់តែញឹកញាប់។ បម្រែបម្រួលបរិស្ថានទាំងនេះបាននាំឱ្យមានការរិចរិលដី ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ ការរំខានដល់ការធ្វើកសិកម្ម និងការកើនឡើងនូវភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច-សង្គម នៅតាមសហគមន៍ជនបទ។ ការសិក្សាមួយដែលបានធ្វើឡើងនៅក្នុងឃុំចំនួនបី បានពិនិត្យមើលទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងការចល័តរបស់មនុស្ស។ លទ្ធផលបង្ហាញថា ពលករចំណាកស្រុកភាគច្រើនមានកម្រិតវប្បធម៌ទាប និងចូលចិត្តការធ្វើចំណាកស្រុកដែលមានរយៈពេលវែងជាងការងារតាមរដូវកាល។ បុរសតែងតែប្រកបការងារដែលមានហានិភ័យខ្ពស់ ខណៈដែលស្ត្រីច្រើនតែធ្វើការក្នុងវិស័យកសិកម្ម ឬនៅតំបន់ទីប្រជុំជន។ ទោះបីជាពលករចំណាកស្រុកជាច្រើនបន្តស្នាក់នៅក្នុងខេត្តរបស់ពួកគេក៏ដោយ ស្ត្រីមួយចំនួនធំបានធ្វើដំណើរទៅកាន់ទីក្រុង។

មុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ដែលប៉ះពាល់ដល់សហគមន៍ជាញឹកញាប់បំផុត រួមមាន រលកកំដៅ និងខ្យល់ព្យុះ ខណៈដែលគ្រោះរាំងស្ងួត និងការផ្ទុះឡើងនៃសត្វល្អិតចង្រៃក៏បង្កជាបញ្ហាប្រឈមផងដែរ។ ការគាំទ្រសហគមន៍ដែលមានកម្រិត បានបង្ខំឱ្យគ្រួសារជាច្រើនពឹងផ្អែកលើប្រាក់សន្សំ ឬកម្ចី។ កត្តាចម្បងដែលជំរុញការធ្វើចំណាកស្រុក រួមមាន ភាពក្រីក្រ កង្វះការងារ និងបំណុល ខណៈដែលការប្រែប្រួលអាកាសធាតុដើរតួនាទីដោយប្រយោលនៅក្នុងទំនាក់ទំនងនេះ ដោយបង្កឱ្យមានទឹកជំនន់ គ្រោះរាំងស្ងួត កង្វះខាតទឹក និងការថមថយទិន្នផលដំណាំ។



**ការសិក្សាទី២៖ «ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ តាមរយៈកម្មវិធីផ្ទេរសាច់ប្រាក់នៅកម្ពុជា៖ បទពិសោធជាក់ស្តែងពីសហគមន៍តំបន់ឆ្នេរ»[១០] អនុវត្តដោយវិទ្យាស្ថានជាតិសង្គមកិច្ច (NISA) វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) និងសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)**

*បទបង្ហាញដោយ៖ លោកបណ្ឌិត សំ ចាន់ធី*
*អ្នកស្រាវជ្រាវជាន់ខ្ពស់ នៃវិទ្យាស្ថានជាតិសង្គមកិច្ច*



ការសិក្សាស្តីពី «ការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមរយៈកម្មវិធីផ្ទេរសាច់ប្រាក់នៅកម្ពុជា៖ បទពិសោធជាក់ស្តែងពីសហគមន៍តំបន់ឆ្នេរ» ត្រូវបានធ្វើឡើងនៅក្នុងខេត្តជាប់មាត់សមុទ្រចំនួនបួនគឺ កោះកុង ព្រះសីហនុ កំពត និងកែប។ ការសិក្សានេះបានរកឃើញថា អ្នកផ្តល់សម្ភាសន៍ ៨០% យល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និង ៩១% បានរាយការណ៍ថាធ្លាប់ទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ ការយល់ដឹងអំពីយុទ្ធសាស្ត្របន្សាំនៅមានកម្រិតខ្សោយនៅឡើយ ដោយចម្លើយភាគច្រើនផ្អែកលើចំណេះដឹងមូលដ្ឋានដែលមានស្រាប់ ដូចជា ការផ្អាកសកម្មភាពនៅអំឡុងពេលមានព្យុះ ជាជាងការត្រៀមខ្លួន ឬកាត់បន្ថយហានិភ័យបែបបុរេសកម្ម។

កម្មវិធីផ្ទេរសាច់ប្រាក់ ត្រូវបានរកឃើញថាមានផលវិជ្ជមាន ប៉ុន្តែនៅមានកម្រិត។ ខណៈដែលកម្មវិធីនេះជួយគ្រួសារឱ្យបំពេញតម្រូវការមូលដ្ឋាន និងកាត់បន្ថយភាពងាយរងគ្រោះ វាមិនបានរួមចំណែកគួរឱ្យកត់សម្គាល់ដល់ការបង្កើតប្រាក់ចំណូលនោះទេ។ អ្នកឆ្លើយតប ៩៦% បានប្រើសាច់ប្រាក់ពីកម្មវិធីសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ ដែលក្នុងនោះ ៦៥% បានចំណាយលើទំនិញមិនមែនជាអាហារ និង ៤៦% លើការថែទាំសុខភាព និងការអប់រំ។ ទោះបីជាអ្នកឆ្លើយតប ៩២% បានរាយការណ៍ថាកម្មវិធីផ្ទេរសាច់ប្រាក់មិនបានជួយបង្កើនប្រាក់ចំណូលរបស់ពួកគេក៏ដោយ ភាគរយប្រហាក់ប្រហែលគ្នានេះបានទទួលស្គាល់ថាកម្មវិធីផ្ទេរសាច់ប្រាក់បានជួយបង្កើនភាពធន់ ហើយ ៦០% និយាយថា កម្មវិធីផ្ទេរសាច់ប្រាក់បានជួយពួកគេឱ្យសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ កម្មវិធីនេះបានវិវត្តពីវិធានការសង្គ្រោះបន្ទាន់ក្នុងអំឡុងពេលកូវីដ-១៩ ទៅជាកញ្ចប់ជំនួយគ្រួសាររយៈពេលវែង ដែលបច្ចុប្បន្នត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយគាំពារសង្គម ដោយផ្តោតគោលដៅលើក្រុមងាយរងគ្រោះ ដូចជា ស្ត្រី មនុស្សវ័យចាស់ កុមារ និងជនមានពិការភាព ជាពិសេសអ្នកដែលកាន់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលជាដើម។

[៩០] https://policypulse.org/publications/articles/climate-change-adaptation-through-a-cash-transfer-program-ctp-in-cambodia-empirical-evidence-from-coastal-communities/

## សង្ខេបកិច្ចពិភាក្សា

ប្រព័ន្ធគាំពារសង្គមរបស់កម្ពុជា រួមបញ្ចូលទាំងកម្មវិធីជំនួយសង្គម (សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ) និងកម្មវិធីរបបសន្តិសុខសង្គម (សម្រាប់អ្នកដែលមានលទ្ធភាពបង់ភាគទាន)។ កម្មវិធីនានា ដូចជា មូលនិធិសមធម៌សុខាភិបាល កម្មវិធីកញ្ចប់គ្រួសារ កម្មវិធីផ្តល់អាហារនៅតាមសាលារៀន ការគាំទ្រអាហារូបករណ៍ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ផ្តល់ការគាំទ្រជាបន្តបន្ទាប់ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ។ កម្មវិធីឆ្លើយតបនឹងគ្រោះអាសន្នត្រូវបានដាក់ឱ្យដំណើរការក្នុងអំឡុងពេលមានវិបត្តិ (ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត) ខណៈដែលការគាំទ្រការស្តារនីតិសម្បទា ស្ថិតនៅក្រោមក្របខណ្ឌគាំពារសង្គមជារួម។ កម្មវិធីទាំងនេះត្រូវបានចាត់ទុកថាជាឧបករណ៍រក្សាលំនឹងជីវភាពដោយស្វ័យប្រវត្តិ ដែលជួយបុគ្គលម្នាក់ៗឱ្យស៊ូទ្រាំនឹងការប៉ះទង្គិចសេដ្ឋកិច្ច និងបរិស្ថាន ដោយមិនធ្លាក់ចូលកាន់តែជ្រៅទៅក្នុងភាពក្រីក្រ ។

រាជរដ្ឋាភិបាលខិតខំប្រឹងប្រែងជាលក្ខណៈអន្តរវិស័យ។គំនិតផ្តួចផ្តើមទាំងនេះរួមមាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងផ្សេងៗ។ ក្រសួងសង្គមកិច្ច ធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា លើកម្មវិធីផ្តល់អាហារនៅតាមសាលារៀន ជាមួយក្រសួងសុខាភិបាលលើសេវាថែទាំសុខភាព ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើការកាត់បន្ថយភាពក្រីក្រ និងជាមួយក្រសួងបរិស្ថានលើកិច្ចគាំពារសង្គមដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ថ្មីៗនេះ អង្គភាពតាមវិស័យជាក់លាក់មួយក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីគាំទ្រដល់ការអនុវត្តការចូលរួមចំណែករបស់ផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុដំណាក់កាលទី៣ (NDC)ដោយផ្តោតលើការពង្រឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់សហគមន៍ងាយរងគ្រោះ។






ឯកសារNDC ៣.០ ដែលបានធ្វើបច្ចុប្បន្នភាពនេះ និងដែលកម្ពុជាបានដាក់ជូនលេខាធិការដ្ឋាន UNFCCC នៅខែសីហា ឆ្នាំ២០២៥ បានបញ្ចូលការពិចារណាអំពីបរិយាបន្ន និងសិទ្ធិមនុស្ស ដោយកំណត់គោលដៅលើប្រជាជនងាយរងគ្រោះ រួមមាន មនុស្សវ័យចាស់ ជនមានពិការភាព បុគ្គល LGBTQIA+ និងសហគមន៍ជនជាតិដើមភាគតិច។ រចនាសម្ព័ន្ធស្ថាប័ន ដូចជា ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងកិច្ចសហប្រតិបត្តិការអន្តរក្រសួង ដែលត្រូវបានពង្រឹង បានធ្វើឱ្យប្រព័ន្ធអភិបាលកិច្ចអាកាសធាតុកាន់តែមានភាពរឹងមាំ។

តួអង្គដែលធ្វើការងារសង្គម ដើរតួនាទីយ៉ាងសំខាន់នៅគ្រប់ដំណាក់កាលនៃជីវិតរបស់បុគ្គលម្នាក់ៗ (ពីពេលកើត រហូតដល់ស្លាប់) តាមរយៈការផ្តល់សេវាគាំទ្រជាសារវ័ន្ត។ អន្តរាគមន៍របស់តួអង្គទាំងនេះ រួមមាន ការបង្ការ (ការលើកកម្ពស់ការយល់ដឹង និងការបណ្តុះបណ្តាល) ការគាំទ្រភ្លាមៗ (ដូចជាជម្រកអំឡុងពេលមានគ្រោះមហន្តរាយ) និងការស្តារនីតិសម្បទារយៈពេលវែង ដោយសហការជាមួយអ្នកពាក់ព័ន្ធផ្សេងៗ។ ប្រព័ន្ធការងារសង្គមដែលមានរចនាសម្ព័ន្ធ រួមមាន ភ្នាក់ងារសង្គមកិច្ចកម្រិតបឋម ភ្នាក់ងារសង្គមកិច្ចដែលជាអ្នកជំនាញកម្រិតវិជ្ជាជីវៈ និងភ្នាក់ងារសង្គមកិច្ចពាក់ព័ន្ធ ដែលធានាថាបុគ្គលងាយរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណនិងទទួលបានការគាំទ្រយ៉ាងមានប្រសិទ្ធភាពសូម្បីតែនៅក្នុងស្ថានភាព ដែលមានការធ្វើចំណាកស្រុក ឬការផ្លាស់ទីលំនៅក៏ដោយ។

បន្ថែមពីនេះ គំនិតផ្តួចផ្តើមនានា ដូចជា កសិកម្មឆ្លាតវៃនឹងអាកាសធាតុ ខ្សែច្រវាក់តម្លៃដែលធន់នឹងអាកាសធាតុ និងការអភិវឌ្ឍសហគ្រាស សហគមន៍ដោយប្រើប្រាស់ជំនួយឥតសំណង កំពុងទទួលបានការគាំទ្រ ពីដៃគូនានា ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិអាកាសធាតុ បៃតង (GCF) ដែលជួយសហគមន៍សម្របខ្លួនទៅនឹងការប្រែប្រួល អាកាសធាតុ ហើយក្នុងពេលជាមួយគ្នា លើកកម្ពស់មុខរបរក្នុងស្រុក។ កម្មវិធីនានា ដូចជាកម្មវិធីបញ្ចប់ភាពក្រីក្រ ដែលអនុវត្តដោយមានការ គាំទ្រពីដៃគូអភិវឌ្ឍន៍ មានគោលបំណងបំពាក់បំប៉នគ្រួសារក្រីក្រនូវ បំណិនជីវិត និងជំនាញប្រកបអាជីវកម្ម ដែលអនុញ្ញាតឱ្យមានការ អភិវឌ្ឍមុខរបរប្រកបដោយចីរភាព និងការបន្សាំនឹងអាកាសធាតុ។

ជារួម ខណៈពេលដែលកម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការបញ្ចូលភាពធន់នឹងអាកាសធាតុទៅក្នុងយុទ្ធសាស្ត្រគាំពារសង្គម និងការធ្វើចំណាកស្រុក បញ្ហាប្រឈមនៅតែមាន ក្នុងការធានាឱ្យមាន មុខរបរប្រកបដោយចីរភាព ការកាត់បន្ថយភាពពឹងផ្អែក និងការបង្កើនកិច្ច សហប្រតិបត្តិការអន្តរវិស័យ។ ការពង្រឹងការអនុវត្តគោលនយោបាយ ការលើកកម្ពស់ចំណេះដឹងបន្សាំនៅកម្រិតសហគមន៍ និងការពង្រឹង ការសម្របសម្រួលរវាងក្រសួង គឺជាជំហានដ៏សំខាន់ ដើម្បីកសាង ភាពធន់រយៈពេលវែងនៅចំពោះមុខការប្រែប្រួលអាកាសធាតុ។ ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ជាក់ជាថ្មីពីការប្តេជ្ញា ចិត្តរបស់ខ្លួនក្នុងការពង្រឹងកិច្ចគាំពារសង្គមនៅថ្នាក់មូលដ្ឋាន តាមរយៈ ការកំណត់អត្តសញ្ញាណក្រុមងាយរងគ្រោះ ដូចជា ស្ត្រី ស្ត្រីមានផ្ទៃពោះ កុមារ ជនមានពិការភាព និងបុគ្គលដែលមានបញ្ហាសតិបញ្ញា។ នៅពេលមានករណីត្រូវការអន្តរាគមន៍នៅកម្រិតខ្ពស់ ក្រសួងនឹងសម្រប សម្រួលជាមួយវិស័យ/ក្រសួងផ្សេងទៀត។

# វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល

| | |
|---|---|
| **វាគ្មិនកិត្តិយស** | **ឯកឧត្តម សរ បុរីរក្ស**<br>*នាយកវិទ្យាស្ថានជាតិសង្គមកិច្ច* |
| | **លោក ស្រេង សោភ័ណរស្មី**<br>*អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម* |
| | **លោក ឡុង សូណា**<br>*អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន* |
| **អ្នកធ្វើបទបង្ហាញ** | **លោកបណ្ឌិត សំ ចាន់ធី**<br>*អ្នកស្រាវជ្រាវជាន់ខ្ពស់ នៃវិទ្យាស្ថានជាតិសង្គមកិច្ច* |
| | **លោក ខាន់ ដូនីរ៉ា**<br>*អ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា* |
| **អ្នកសម្របសម្រួលកិច្ចពិភាក្សា** | **លោកបណ្ឌិត អាង រស្មី**<br>*អ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា* |

# ការពិភាក្សាស្របពេលគ្នា ១ខ៖ ការអភិវឌ្ឍជនបទ ប្រកបដោយបរិយាបន្ន៖ ការចូលរួមរបស់សហគមន៍ និងក្រុមសង្គមក្នុងការធ្វើផែនការ និងលទ្ធផលនៃវិនិយោគក្នុងស្រុក ដើម្បីជួយដល់តម្រូវការរបស់ក្រុមសង្គមនៅក្នុងបរិបទប្រែប្រួលអាកាសធាតុ

*សហការរៀបចំដោយ៖ មជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS) និងអង្គការភូមិខ្ញុំ (MVi)*

កម្ពុជានៅតែជាប្រទេសដែលមានប្រជាជនភាគច្រើនរស់នៅតំបន់ជនបទ ដោយប្រជាជនភាគច្រើនពឹងផ្អែកលើកសិកម្ម និងធនធានធម្មជាតិ សម្រាប់ការចិញ្ចឹមជីវិត។ ទោះបីជាមានវឌ្ឍនភាពសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ក៏ដោយ តំបន់ជនបទនៅតែបន្តជួបប្រទះអត្រាភាពក្រីក្រខ្ពស់ ជម្រើសមុខរបរនៅមានកម្រិត និងវិសមភាពប្រាក់ចំណូលគួរឱ្យកត់សម្គាល់ បើធៀបនឹងតំបន់ទីប្រជុំជន។ ផលិតភាពកសិកម្មទាប ដែលបណ្តាលមកពីលទ្ធភាពទទួលបានបច្ចេកវិទ្យា និងសេវាកម្មបន្ថែមនៅមានកម្រិតកាន់តែមានភាពធ្ងន់ធ្ងរមួយកម្រិតទៀត ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដូចជាអាកាសធាតុមិនអាចទាយទុកជាមុនបាន និងការកើនឡើងនៃភាពញឹកញាប់នៃទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលប៉ះពាល់ដល់ក្រុមផ្សេងៗគ្នាក្នុងរូបភាពផ្សេងៗគ្នា រួមមាន៖ ស្ត្រី ជនមានពិការភាព ជនជាតិភាគតិច និងជនជាតិដើមភាគតិចជាដើម។

សហគមន៍ជនបទក៏ប្រឈមមុខនឹងកង្វះហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗផងដែរ ដូចជាផ្លូវថ្នល់ អគ្គិសនី ទឹកស្អាត និងអនាម័យ មិនទាន់គ្រប់គ្រាន់។ កង្វះហេដ្ឋារចនាសម្ព័ន្ធទាំងនេះរឹតត្បិតសកម្មភាពសេដ្ឋកិច្ច និងរួមចំណែកដល់កម្រិតជីវភាពរស់នៅទាប។ លើសពីនេះ គម្លាតឌីជីថល ជាកត្តាដាក់កំហិតលើការទទួលបានការអប់រំ ព័ត៌មានទីផ្សារ និងឱកាសសម្រាប់ការរីកចម្រើនផ្នែកសង្គម និងសេដ្ឋកិច្ច។ សេវាអប់រំ និងថែទាំសុខភាពជាទូទៅ មានគុណភាពទាប និងពិបាកទទួលបាននៅតំបន់ជនបទ ដែលនាំឱ្យមានការបោះបង់ការសិក្សាក្នុងអត្រាខ្ពស់ កង្វះអាហារូបត្ថម្ភ និងជំងឺដែលអាចការពារបាន។




សហគមន៍ជនបទ ជារឿយៗ មានឥទ្ធិពលតិចតួចលើការតាក់តែងគោលនយោបាយ។ រចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន និងអង្គការសហគមន៍នៅខ្វះសមត្ថភាព ហើយគោលនយោបាយអភិវឌ្ឍន៍ជាតិពេលខ្លះ មើលរំលងចំណេះដឹង និងបរិបទមូលដ្ឋាន ដែលនាំឱ្យមានភាពមិនស៊ីសង្វាក់គ្នារវាងគោលដៅគោលនយោបាយ និងតម្រូវការសហគមន៍។ ដូច្នេះ ការផ្សារភ្ជាប់គម្លាតរវាងការស្រាវជ្រាវថ្នាក់មូលដ្ឋាន និងគោលនយោបាយជាតិ មានសារៈសំខាន់ណាស់។ ការបញ្ចូលបទពិសោធន៍ និងទិន្នន័យពីកម្រិតភូមិទៅក្នុងការរៀបចំគោលនយោបាយ អាចជួយធានាថា យុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទមានលក្ខណៈបរិយាបន្ន ឆ្លើយតប និងមានប្រសិទ្ធភាព ក្នុងការដោះស្រាយតម្រូវការរបស់ប្រជាជនជនបទនៅកម្ពុជា។

កិច្ចពិភាក្សាស្របពេលគ្នាស្តីពី «ការអភិវឌ្ឍជនបទប្រកបដោយបរិយាបន្ន» នេះផ្តោតលើរបៀបដែលការស្រាវជ្រាវនៅជនបទ និងករណីសិក្សានៅកម្រិតភូមិ អាចផ្តល់ធាតុចូលដល់ការរៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទ។ កិច្ចពិភាក្សានេះធ្វើឡើងផ្អែកលើលទ្ធផលស្រាវជ្រាវរបស់មជ្ឈមណ្ឌលសិក្សាគោលនយោបាយ និងអង្គការភូមិខ្ញុំ ក៏ដូចជាការយល់ដឹងពីអ្នកតាក់តែងគោលនយោបាយ តំណាងសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ។

## សង្ខេបកិច្ចពិភាក្សា

ខណៈពេលដែលសេដ្ឋកិច្ចកម្ពុជាមានកំណើន និងភាពក្រីក្រត្រូវបានកាត់បន្ថយ គម្លាតនៅតែមានរវាងការអភិវឌ្ឍតំបន់ទីប្រជុំជន និងជនបទ។ ប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាល បន្តប្រឈមនឹងឧបសគ្គក្នុងការទទួលបានឱកាសបង្កើនប្រាក់ចំណូលគ្រួសារ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ពួកគេ។ វិស័យកសិកម្មនៅតែជាប្រភពចំណូលចម្បង សម្រាប់គ្រួសារជនបទភាគច្រើន។ ហេតុដូច្នេះហើយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ត្រូវតែមានលក្ខណៈទូលំទូលាយ និងចំគោលដៅបន្ថែមទៀត ដើម្បីដោះស្រាយតម្រូវការនៅជនបទ។ ក្រសួងអភិវឌ្ឍន៍ជនបទបាននិងកំពុងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២៣ និងគោលនយោបាយផ្សេងទៀត ដើម្បីធានាបាននូវលទ្ធផលវិជ្ជមាន។ ទោះជាយ៉ាងណាក៏ដោយ ជោគជ័យទាមទារឱ្យមានកិច្ចសហការរវាងអ្នកពាក់ព័ន្ធនៅកម្រិតផ្សេងៗគ្នា។

កិច្ចពិភាក្សាស្តីពីការអភិវឌ្ឍជនបទប្រកបដោយបរិយាបន្ន បានរំលេចពីសារៈសំខាន់នៃការប្រមូលផ្តុំអ្នកពាក់ព័ន្ធចម្រុះ រួមមាន រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អ្នកស្រាវជ្រាវ អ្នកអនុវត្ត និងតំណាងសហគមន៍ ដើម្បីធានាថាទាំងការស្រាវជ្រាវ និងបទពិសោធន៍ជាក់ស្តែង ផ្តល់ព័ត៌មានសម្រាប់ការរៀបចំគោលនយោបាយជាតិ។

តាមការលើកឡើងរបស់តំណាងមកពីក្រសួងអភិវឌ្ឍន៍ជនបទ នៅក្នុងនីតិកាលទី៧ រាជរដ្ឋាភិបាលបានចាប់ផ្តើមតាក់តែងគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទគ្រប់ជ្រុងជ្រោយជំបូងគេ ដែលគ្របដណ្តប់លើការអភិវឌ្ឍជនបទនៅទូទាំងប្រទេសកម្ពុជា។ គោលនយោបាយនេះត្រូវបានរៀបចំឡើងដោយមានការស្រាវជ្រាវយ៉ាងទូលំទូលាយ ការត្រួតពិនិត្យផ្ទៃក្នុង និងការពិគ្រោះយោបល់យ៉ាងច្រើន






ជាមួយក្រសួង អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដំណើរការនេះមានគោលបំណងធ្វើឱ្យមានតុល្យភាពរវាងទស្សនវិស័យអភិបាលកិច្ច និងការគ្រប់គ្រងជាមួយតម្រូវការនៅថ្នាក់មូលដ្ឋាន ដែលធ្វើឱ្យគោលនយោបាយនេះមានចីរភាពផង និងឆ្លើយតបផង។ សេចក្តីព្រាងគោលនយោបាយនេះត្រូវបានពិនិត្យដោយទីស្តីការគណៈរដ្ឋមន្ត្រី បន្ទាប់ពីកិច្ចប្រជុំជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ និងក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌។ គេរំពឹងថា គោលនយោបាយនេះនឹងប្រកាសដាក់ឱ្យអនុវត្តនៅខែកញ្ញា ឆ្នាំ ២០២៥។

ផែនការនេះផ្តោតលើការបង្កើត «ភូមិគំរូ» ដែលបង្ហាញពីចីរភាព និងសេចក្តីថ្លៃថ្នូរ។ ដើម្បីជានាបាននូវការឆ្លើយតប ក្រសួងអភិវឌ្ឍន៍ជនបទកំពុងអនុវត្តអភិក្រមវិមជ្ឈការ ដោយផ្ទេរការទទួលខុសត្រូវសំខាន់ៗចំនួនបួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានដូចជា ការថែទាំអនាម័យនិងបង្គន់សាធារណៈ ការជួសជុលប្រព័ន្ធធារាសាស្ត្រ ការថែទាំអណ្តូងទឹក និងការគ្រប់គ្រងផ្លូវជនបទប្រភេទទី៤។ បច្ចុប្បន្នកំពុងមានការផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលមូលដ្ឋានដើម្បីគ្រប់គ្រង និងថែទាំសមិទ្ធផលទាំងនេះ។

ក្រៅពីគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល សហគមន៍អន្តរជាតិក៏បានរួមចំណែកចំពោះការអភិវឌ្ឍជនបទផងដែរ ដូចជា កម្មវិធីស្តីពីសុខភាពនិងអាហារូបត្ថម្ភ ការអប់រំ ទឹកស្អាត និងអនាម័យ មុខរបរចិញ្ចឹមជីវិត ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកិច្ចការពារកុមារជាដើម។ អង្គការទាំងនេះធ្វើការយ៉ាងជិតស្និទ្ធជាមួយឃុំ និងធានាសុវត្ថិភាព និងគណនេយ្យភាពជាពិសេស សម្រាប់ស្ត្រី និងកុមារ។ អង្គការទាំងនេះបានកំណត់ពីចំណុចខ្វះខាតដែលនៅសេសសល់ ដូចជា ការសម្របសម្រួលមានកម្រិតរវាងតួអង្គពាក់ព័ន្ធ ថវិកាមិនគ្រប់គ្រាន់នៅថ្នាក់ក្រោមជាតិ និងឧបសគ្គសម្រាប់ក្រុមងាយរងគ្រោះ ជាពិសេសជនមានពិការភាព។ ដោយសារធនធានមានកម្រិតសកម្មភាពមួយចំនួនទាមទារឱ្យមានកិច្ចសហការរឹងមាំ ការធ្វើផែនការរួមគ្នា និងការបែងចែកធនធានសមស្រប ទើបសម្រេចបាននូវលទ្ធផលតាមគោលដៅ។

តំណាងមកពីក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលស្គាល់បញ្ហាប្រឈមទាំងនេះ និងបានគូសបញ្ជាក់ពីយុទ្ធសាស្ត្រដែលសង្កត់ធ្ងន់លើសហប្រតិបត្តិការប្រសិទ្ធភាព និងភាពជាដៃគូ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ខ្លួនមិនអាចដោះស្រាយរាល់បញ្ហាប្រឈមក្នុងពេលតែមួយបានទេ ដោយសារកង្វះធនធាន។ បច្ចុប្បន្ន អត្រាគ្របដណ្តប់ការផ្គត់ផ្គង់ទឹកស្អាតកម្រិតមូលដ្ឋានមានចំនួន ៨៩% និងអនាម័យកម្រិតមូលដ្ឋានមានចំនួន ៩៤%។ ទោះជាយ៉ាងណាក៏ដោយ មានភាពមិនស៊ីសង្វាក់គ្នារវាងការទទួលបានសេវាកម្រិតមូលដ្ឋាន និងសេវាដែលត្រូវបានគ្រប់គ្រងប្រកបដោយសុវត្ថិភាព។ មានតែប្រជាជន ២១% និង ៥១% ប៉ុណ្ណោះដែលមានលទ្ធភាពទទួលបានសេវាដែលត្រូវបានគ្រប់គ្រងប្រកបដោយសុវត្ថិភាពសម្រាប់ទឹកស្អាត[១១] និងអនាម័យ។[១២]



ដើម្បីដោះស្រាយបញ្ហាសម្របសម្រួល និងថវិកា រាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់យុទ្ធសាស្ត្រ «សហប្រតិបត្តិការប្រសិទ្ធភាព និងភាពជាដៃគូ» ដែលជាផ្នែកមួយនៃ កម្មវិធីទីប្រាំរបស់ខ្លួន។ បច្ចុប្បន្នក្រសួងអភិវឌ្ឍន៍ជនបទរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ជាមួយអង្គការសង្គមស៊ីវិល និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្តដើម្បីពិភាក្សាអំពីឧបសគ្គ និងស្វែងរកដំណោះស្រាយរួមគ្នា។

រាជរដ្ឋាភិបាលសហការដោយបើកចំហជាមួយអង្គការសង្គមស៊ីវិល ទោះបីមាន ឬគ្មានអនុស្សរណៈនៃការយោគយល់គ្នាជាផ្លូវការក៏ដោយ។ វាគ្មិនមួយរូបបានគូសបញ្ជាក់ពីតួនាទីរបស់គណៈកម្មការអភិវឌ្ឍន៍ភូមិ ក្នុងការសម្របសម្រួលការអភិវឌ្ឍដែលផ្តោតលើគ្រួសារ និងបានលើកទឹកចិត្តឱ្យអ្នកពាក់ព័ន្ធតម្រង់ទិសការវិនិយោគឱ្យស្របគ្នាដើម្បីឈានទៅសម្រេចគោលដៅរួម។ ប្រសិនបើដៃគូនានាអាចកៀរគរការវិនិយោគ និងធនធានរួមគ្នា ភូមិអាចត្រូវបានអភិវឌ្ឍទៅជាគំរូនៃអភិបាលកិច្ចល្អ ការអប់រំ បរិស្ថានរស់នៅល្អ មុខរបរចិញ្ចឹមជីវិត ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា។ ភូមិគំរូទាំងនេះមានបំណងផ្តល់ជាឧទាហរណ៍ដែលបំផុសគំនិតដល់ភូមិដទៃទៀត។

---

១១ សេវាទឹកស្អាតដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាពមានន័យថា ទឹកស្អាតដែលបានមកពីប្រភពដែលបានកែលម្អអាចប្រើប្រាស់បាននៅក្នុងបរិវេណផ្ទះ មានទឹកប្រើប្រាស់នៅពេលត្រូវការ និងគ្មានការចម្លងមេរោគ។

១២ សេវាអនាម័យដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាពមានន័យថា ការប្រើប្រាស់បង្គន់អនាម័យដែលបានកែលម្អ ដែលមិនប្រើប្រាស់រួមគ្នាជាមួយអ្នកដទៃ និងមានការចោលកាកសំណល់លាមកដោយសុវត្ថិភាព នៅនឹងកន្លែង ឬយកទៅចោលនៅទីតាំងផ្សេង។



ក្រសួងអភិវឌ្ឍន៍ជនបទមានគោលបំណងអភិវឌ្ឍ «ភូមិសក្តានុពល» ដែលអាចវិវត្តបន្តិចម្តងៗទៅជាភូមិគំរូ។ នៅក្រោមផែនការយុទ្ធសាស្ត្រ ឆ្នាំ២០៥០ ប្រសិនបើភូមិគំរូដែលជោគជ័យនីមួយៗអាចបំផុសគំនិត ឬណែនាំភូមិចំនួនដប់ផ្សេងទៀត នោះការផ្តល់ការគាំទ្រផ្លូវការដល់ភូមិចំនួន ៥០០ អាចនឹងបង្កើតឱ្យមានភូមិគំរូចំនួន ៥០០០ នៅទូទាំងប្រទេស។ គោលដៅបច្ចុប្បន្នរបស់ក្រសួងអភិវឌ្ឍន៍ជនបទ គឺបង្កើតភូមិគំរូចំនួន ៥០ភូមិ ជាការសាកល្បង។

អង្គការមូលដ្ឋានដែលធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ដែលមិនសូវទទួលបានការយកចិត្តទុកដាក់នៅភូមិភាគឦសានបានលើកឡើងពីកង្វល់អំពីការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិយាបន្ន។ ពួកគេបានកត់សម្គាល់ថា ការចូលរួមនៅក្នុងដំណើរការធ្វើផែនការមូលដ្ឋាន ជារឿយៗ នៅមានកម្រិតនៅឡើយ។ ខណៈពេលដែលក្របខ័ណ្ឌគោលនយោបាយទាមទារឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីសហគមន៍ ក្នុងការអនុវត្តជាក់ស្តែង ការចូលរួមនៅមានកម្រិតទាប ជាពិសេសក្នុងចំណោមស្ត្រី ជនមានពិការភាព និងក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់ផ្សេងទៀត។ នេះចោទជាសំណួរថា តើគោលនយោបាយជាតិអាចធានាបាននូវការចូលរួមដែលមានបរិយាបន្ន និងការបែងចែកថវិកាប្រកបដោយសមធម៌បានយ៉ាងដូចម្តេច។

នៅក្នុងផែនការវិនិយោគឃុំ បច្ចុប្បន្នផ្តោតតែលើក្រុមបុរស និងស្ត្រីប៉ុណ្ណោះ ដែលធ្វើឱ្យក្រុមដែលមិនសូវមានតំណាងផ្សេងទៀតមិនត្រូវបានយកចិត្តទុកដាក់ក្នុងគោលនយោបាយ។ សហគមន៍បានសង្កត់ធ្ងន់ថា បញ្ហាជនបទប៉ះពាល់ដល់ប្រជាពលរដ្ឋទាំងអស់ ហើយមិនគួរត្រូវបានដោះស្រាយដាច់ដោយឡែកពីគ្នានោះទេ។ ប្រជាជននៅតំបន់ដាច់ស្រយាលប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ច និងកម្រិតជីវភាពទាប។ ប្រជាជនភាគច្រើនពឹងផ្អែកលើកសិកម្ម ជលផល និងធនធានព្រៃឈើ ដែលរងផលប៉ះពាល់កាន់តែខ្លាំងឡើងដោយគ្រោះរាំងស្ងួត និងរបបភ្លៀងមិនទៀងទាត់។ គ្រួសារខ្លះក៏កំពុងជួបការលំបាកដោយសារតែបំណុល។ ទោះបីជាមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីរបស់រដ្ឋាភិបាល ដំណោះស្រាយនៅតែមានកម្រិតដោយសារធនធានមានកំណត់។

ដើម្បីលើកកម្ពស់បរិយាបន្ននៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ជនបទ គេត្រូវការពេលវេលា និងការយកចិត្តទុកដាក់បន្ថែមទៀតដើម្បីរៀបចំ និងកែទម្រង់គោលនយោបាយដែលជានាថា «មិនទុកនរណាម្នាក់ចោល»។ ដំណើរការគោលនយោបាយ និងការកែទម្រង់នាពេលអនាគត ត្រូវតែមានការចូលរួមប្រកបដោយអត្ថន័យជាមួយសំឡេងនៅថ្នាក់មូលដ្ឋាន ចាប់តាំងពីដំណាក់កាលដំបូង។ ការពង្រឹងយន្តការចូលរួមនៅថ្នាក់មូលដ្ឋាន និងការធានាថាក្រុមចម្រុះ រួមមាន ជនជាតិដើមភាគតិច ជនមានពិការភាព និងស្ត្រី បានចូលរួមយ៉ាងសកម្មនៅក្នុងការសម្រេចចិត្ត មានសារៈសំខាន់ណាស់។ លើសពីនេះ ការសម្របសម្រួលកាន់តែប្រសើររវាងក្រសួង ដៃគូអភិវឌ្ឍន៍ និងរដ្ឋបាលមូលដ្ឋាន គឺជាការចាំបាច់ ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តគោលនយោបាយឱ្យទៅជាសកម្មភាពជាក់ស្តែង។ ការអភិវឌ្ឍជនបទប្រកបដោយចីរភាព និងបរិយាបន្ន អាស្រ័យមិនត្រឹមតែលើយុទ្ធសាស្ត្រល្អៗប៉ុណ្ណោះទេ ថែមទាំងលើគណនេយ្យភាពរួម ការបែងចែកធនធានប្រកបដោយសមធម៌ និងកិច្ចសហការជាបន្តបន្ទាប់រវាងអ្នកពាក់ព័ន្ធទាំងអស់ផងដែរ។

## វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល

**វាគ្មិនកិត្តិយស**

**លោក ទូច ស៊ីផាត**
*អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ*

**លោកស្រី កែវ អនចាន់**
*ជនបង្គោលស្ត្រី នៃឃុំសាមឃួយ ខេត្តស្ទឹងត្រែង*

**លោក ឈុន សុភ័ណ្ឌ**
*មន្ត្រីជាន់ខ្ពស់បច្ចេកទេសមុខរបរ និងចិញ្ចឹមជីវិត នៃអង្គការទស្សនៈពិភពលោក*

**លោកបណ្ឌិត ប៉ ណារិទ្ធ**
*អ្នកស្រាវជ្រាវ នៃអង្គការភូមិខ្ញុំ*

**អ្នកសម្របសម្រួលកិច្ចពិភាក្សា**

**លោក ច័ន្ទ សុផល**
*នាយក នៃមជ្ឈមណ្ឌលសិក្សាគោលនយោបាយ*

# ការពិភាក្សាស្របពេលគ្នា ២ក៖ វិទ្យាសាស្ត្រមនុស្ស និងវិទ្យាសាស្ត្រសង្គម ក្នុងទិដ្ឋភាពស្រាវជ្រាវដែលកំពុងលូតលាស់នៅកម្ពុជា

*រៀបចំដោយ មជ្ឈមណ្ឌលខេមរសិក្សា*

ឆ្នាំ២០២៣ គឺជាពេលចាប់ផ្ដើមនៃយុគសម័យថ្មីមួយ នៅក្នុងទស្សនវិស័យអភិវឌ្ឍន៍របស់កម្ពុជា។ នៅក្នុងនីតិកាលទី៧ នៃរដ្ឋសភារបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី រួមជាមួយគណៈរដ្ឋមន្ត្រី យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ត្រូវបានអនុម័តដោយមានគោលដៅប្រកបដោយមហិច្ឆតា ប្រែក្លាយកម្ពុជាឱ្យក្លាយជាសេដ្ឋកិច្ច ដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងសេដ្ឋកិច្ចដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ គឺជាដំណាក់កាលដំបូងនៃដំណាក់កាលទាំងប្រាំ ដែលមានរយៈពេល ២៥ឆ្នាំ ហើយត្រូវបានរៀបចំឡើងដើម្បីកសាងបន្តលើសមិទ្ធផលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍នានា ក្នុងរយៈពេល ២៥ ឆ្នាំកន្លងមក។ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍របស់ខ្លួន យុទ្ធសាស្ត្របញ្ចកោណត្រូវបានរៀបចំឡើងជុំវិញស្នូលចំនួន ៥ (កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព) និងអាទិភាពគន្លឹះចំនួន ៥ (មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា)។

នៅក្នុងឯកសារយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបានបោះពុម្ពផ្សាយនៅខែសីហា ឆ្នាំ២០២៣ ការស្រាវជ្រាវត្រូវបានចាត់ទុកថាជាសមាសធាតុដ៏សំខាន់នៅក្នុងការរៀបចំ ការអនុវត្ត និងការវាយតម្លៃគោលនយោបាយ និងកម្មវិធីនានា។ ការស្រាវជ្រាវផ្អែកលើទិន្នន័យ ត្រូវបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រជាច្រើនលើកច្រើនសា ទាក់ទងនឹងយុទ្ធសាស្ត្របញ្ចកោណទី១ គឺ៖ ការអភិវឌ្ឍមូលធនមនុស្ស។ ឧទាហរណ៍ ទាក់ទងនឹងការបណ្ដុះបណ្ដាលគ្រូបង្រៀន គ្រូបង្រៀនត្រូវបានលើកទឹកចិត្ត «ឱ្យធ្វើការស្រាវជ្រាវជាប្រចាំ»។ ទាក់ទងនឹងសុខាភិបាល យុទ្ធសាស្ត្រនេះកត់សម្គាល់ពីសារៈសំខាន់នៃ «ការលើកកម្ពស់ការស្រាវជ្រាវវេជ្ជសាស្ត្រ»។ ទាក់ទងនឹងកសិកម្ម យុទ្ធសាស្ត្រនេះចែងពីសារៈសំខាន់នៃ «ការស្រាវជ្រាវ និងការអភិវឌ្ឍដំណាំដែលធន់នឹងអាកាសធាតុ»។ ជាពិសេស ចំណុចដែលមានសារៈសំខាន់សម្រាប់គោលបំណងនៃកិច្ចពិភាក្សាតុមូលនេះ យុទ្ធសាស្ត្រនេះគូសបញ្ជាក់ពីសារៈសំខាន់នៃ «ការពង្រឹងប្រសិទ្ធភាពនៃការស្រាវជ្រាវ




ការចងក្រង និងការផ្សព្វផ្សាយតម្លៃប្រវត្តិសាស្ត្រនៃសំណង់បេតិកភណ្ឌ វត្ថុបុរាណ ទីតាំងបុរាណសាស្ត្រ ស្លឹករឹត» ។ល។ បន្ថែមលើនេះ ទាក់ទងនឹងយន្តការតាមដាន និងវាយតម្លៃយុទ្ធសាស្ត្រនេះវិញ ឯកសារបានចែងថា រាជរដ្ឋាភិបាលកម្ពុជានឹងរៀបចំ «ក្របខ័ណ្ឌតាមដាន និងវាយតម្លៃផ្អែកលើភស្តុតាង ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ»។ [១៣]

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា គោលនយោបាយជាតិត្រូវរៀបចំឡើង «មិនមែនផ្អែកលើការស្រមើស្រមៃ ឬអារម្មណ៍នោះទេ ប៉ុន្តែដោយមានទិន្នន័យជាក់លាក់» ដោយពណ៌នាទិន្នន័យថាជា «ផែនទី និងជាត្រីវិស័យ» សម្រាប់តម្រង់ទិសគន្លងអភិវឌ្ឍន៍របស់កម្ពុជា។ សម្តេចធិបតីបានគូសបញ្ជាក់ថា ទិន្នន័យដែលមានគុណភាពខ្ពស់ និងអាចទុកចិត្តបាន គឺមានសារៈសំខាន់សម្រាប់ការតាក់តែងគោលនយោបាយប្រកបដោយប្រសិទ្ធភាព ទាំងក្នុងរយៈពេលខ្លី មធ្យម និងវែង ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តថ្នាក់ជាតិកាន់តែខ្លាំងឡើង ឆ្ពោះទៅរកការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យ និងប្រកបដោយបរិយាបន្ន។

---

[១៣] https://www.mfaic.gov.kh/files/uploads/1XK1LW4MCTK9/EN%20PENTAGONAL%20STRATEGY%20-%20PHASE%20I.pdf



ទស្សនៈនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងមុតមាំ នៅក្នុងវត្ថុបំណងនៃកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ដែលខិតខំពង្រឹងការរៀបចំគោលនយោបាយផ្អែកលើទិន្នន័យ និងកិច្ចពិភាក្សាប្រកបដោយបរិយាបន្ន រវាងរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងសង្គមស៊ីវិល។ ការវាយតម្លៃដោយឯករាជ្យលើកម្មវិធីពន្លកចំណេះដំណាក់កាលទី១ ដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០២២ ក៏បានអះអាងពីប្រសិទ្ធភាពនៃកម្មវិធី និងការរួមចំណែករបស់កម្មវិធីនេះដល់ការជំរុញការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យនៅកម្ពុជា។

**នៅក្នុងបរិបទនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងកម្មវិធីពន្លកចំណេះដំណាក់កាលទី២ កិច្ចពិភាក្សាតុមូលនេះមានបំណងស្វែងយល់អំពី៖**

១. តួនាទីសក្តានុពលរបស់អ្នកសិក្សាកម្ពុជាដែលធ្វើការក្នុងផ្នែកវិទ្យាសាស្ត្រមនុស្ស និងវិទ្យាសាស្ត្រសង្គម
២. កម្រិតនៃការចាប់អារម្មណ៍ និងសមត្ថភាពរបស់ពួកគេសម្រាប់ការចូលរួមនៅក្នុងបរិបទស្រាវជ្រាវនេះ
៣. បញ្ហាប្រឈមដែលពួកគេជួបប្រទះ និង
៤. យុទ្ធសាស្ត្រដែលអាចធ្វើទៅបានដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ។

## សង្ខេបកិច្ចពិភាក្សា

ការចាប់អារម្មណ៍លើផ្នែកវិទ្យាសាស្ត្រមនុស្ស និងវិទ្យាសាស្ត្រសង្គម កំពុងមានការកើនឡើងក្នុងចំណោមអ្នកសិក្សាកម្ពុជា ប៉ុន្តែបញ្ហាប្រឈមនៅតែកើតមានដូចជា ការគាំទ្រពីស្ថាប័ននៅមានកម្រិត គោលដៅស្រាវជ្រាវមិនច្បាស់លាស់ និងកង្វះឱកាសសម្រាប់អ្នកស្រាវជ្រាវដែលទើបចាប់ផ្តើមអាជីព។ ការយល់ដឹងពីអ្នកសិក្សាស្រាវជ្រាវ និងអ្នកអប់រំ បានបង្ហាញទាំងវឌ្ឍនភាពគួរឱ្យលើកទឹកចិត្ត និងផ្នែកដែលត្រូវការការយកចិត្តទុកដាក់បន្ថែម។

កម្មវិធីដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដូចជា កម្មវិធីស្រាវជ្រាវ និងការបណ្តុះបណ្តាលដោយផ្អែកលើការណែនាំ បានបង្ហាញលទ្ធផលយ៉ាងល្អប្រសើរ។ ជាមួយការណែនាំដ៏ត្រឹមត្រូវ អ្នកចូលរួមអាចបញ្ចប់គម្រោងស្រាវជ្រាវ បោះពុម្ពផ្សាយលទ្ធផលរកឃើញ និងធ្វើបទបង្ហាញនៅក្នុងសន្និសីទនានា។ ទោះជាយ៉ាងណាក៏ដោយ នៅតាមសាកលវិទ្យាល័យជាច្រើន ការចូលរួមស្រាវជ្រាវរបស់និស្សិតនៅតែមានកម្រិតទាប។ ឧទាហរណ៍ ខណៈពេលដែលមាននិស្សិតរាប់រយ



នាក់ចុះឈ្មោះក្នុងកម្មវិធីសិក្សាប្រវត្តិវិទ្យា មាននិស្សិតតែមួយចំនួនតូចប៉ុណ្ណោះដែលបានបញ្ចប់សារណាដោយសារការណែនាំមានកម្រិត និងបន្ទុកបង្រៀនដ៏ធ្ងន់របស់សាស្ត្រាចារ្យ។ អ្នកសិក្សាជាច្រើននាក់ ចាប់ផ្ដើមការស្រាវជ្រាវស៊ីជម្រៅតែបន្ទាប់ពីបញ្ចប់ការសិក្សាប៉ុណ្ណោះ នៅពេលដែលពួកគេអាចទទួលបានធនធាន និងការចូលរួមពីបណ្ដាញនានា។ ទោះជាយ៉ាងនេះក្ដី មានរឿងរ៉ាវជោគជ័យគួរឱ្យកត់សម្គាល់របស់អ្នកស្រាវជ្រាវកម្ពុជា ដែលផលិតបាននូវស្នាដៃស្រាវជ្រាវ ដែលត្រូវបានពិនិត្យដោយអ្នកជំនាញដែលជាការបញ្ជាក់ពីអ្វីដែលអាចសម្រេចបាននៅពេលមានការគាំទ្រជាប់លាប់។

ការផ្លាស់ប្ដូរការសិក្សាគួរឱ្យកត់សម្គាល់ ទៅរកវិទ្យាសាស្ត្រមនុស្ស និងវិទ្យាសាស្ត្រសង្គម បានកើតឡើង ដោយការសិក្សានៅកម្ពុជាប្រហែល ៧៥% ផ្ដោតលើមុខវិជ្ជាទាំងនេះ។ យុទ្ធសាស្ត្របញ្ចកោណចាត់ទុកការស្រាវជ្រាវ និងនវានុវត្តន៍ ជាអាទិភាពជាតិដែលបង្ហាញពីការគាំទ្ររបស់រដ្ឋាភិបាលកាន់តែរឹងមាំសម្រាប់អ្នកសិក្សាស្រាវជ្រាវថ្មីៗ។ កម្ពុជាក៏មានប្រពៃណីស្រាវជ្រាវដ៏សម្បូរបែបនៅក្នុងផ្នែកប្រវត្តិសាស្ត្រនរវិទ្យា និងការអប់រំ រួមទាំងកិច្ចសហការជាមួយដៃគូអន្តរជាតិលើការអភិរក្សបេតិកភណ្ឌវប្បធម៌ និងគំនិតផ្ដួចផ្ដើមដែលទទួលស្គាល់ដោយអង្គការយូណេស្កូ។ ប៉ុន្តែ ប្រទេសនេះនៅតែខ្វះប្រព័ន្ធកណ្ដាល សម្រាប់តាមដានលទ្ធផលស្រាវជ្រាវ ដែលជាការដាក់កំហិតលើការយល់ដឹងអំពីវឌ្ឍនភាពជាតិ និងការសម្របសម្រួលរវាងស្ថាប័ននានា។

ការកំណត់និយមន័យថា អ្នកណាត្រូវបានចាត់ទុកជាអ្នកស្រាវជ្រាវ គឺជាការពិភាក្សាមួយដែលកំពុងបន្តកើតមាន។ មនុស្សមួយចំនួនកំណត់អ្នកស្រាវជ្រាវផ្អែកលើគុណវុឌ្ឍិសិក្សា អ្នកខ្លះទៀតផ្អែកលើថាតើពួកគេបោះពុម្ពផ្សាយក្នុងទិនានុប្បវត្តិស្រាវជ្រាវ

ឬអត់ និងអ្នកខ្លះទៀតតាមរយៈបទពិសោធអនុវត្តផ្ទាល់។ នៅប្រទេសកម្ពុជា ស្ត្រីជាច្រើនបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការស្រាវជ្រាវ តាមរយៈបណ្តាញ និងអង្គការនានា ហើយស្របពេលជាមួយគ្នា ត្រូវរក្សាតុល្យភាពជាមួយនឹងការទទួលខុសត្រូវក្នុងគ្រួសារផងដែរ។ បណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ ( SheThinks Network ) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០២១ ជាក្រុមតូចមួយមិនផ្លូវការនៃស្ត្រីអ្នកស្រាវជ្រាវ បានវិវត្តទៅជាបណ្តាញមួយដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដែលមានសមាជិកចំនួន ៨០នាក់។ សមាជិកនៃបណ្តាញនេះ ប្តេជ្ញាចិត្តក្នុងការរៀនសូត្រ និងរួមចំណែក ទោះបីជាពួកគេជារឿយៗ ខ្វះការទទួលស្គាល់ជាផ្លូវការក៏ដោយ។ បរិយាកាសដែលគិតគូរពីយេនឌ័រ និងផ្តល់ការគាំទ្រ ត្រូវបានគេមើលឃើញថាមានសារៈសំខាន់ ដើម្បីឱ្យវិស័យស្រាវជ្រាវក្នុងប្រទេសកម្ពុជាមានការរីកចម្រើន។

នៅលើសកលលោក លទ្ធផលស្រាវជ្រាវភាគច្រើនលើសលុប ត្រូវបានផលិតក្នុងប្រទេសនានា ដូចជា សហរដ្ឋអាមេរិក ចិន និងចក្រភពអង់គ្លេស ជាដើម។ ថ្មីៗនេះ ប្រទេសចិនបានក្លាយជាអ្នកផលិតការបោះពុម្ពផ្សាយការសិក្សាដ៏ធំបំផុត ទោះបីជាសហរដ្ឋអាមេរិកនៅតែជាប្រទេសដែលមានការដកស្រង់ច្រើនបំផុតក៏ដោយ។ កម្ពុជានៅតែមានកម្រិតទាបបើធៀបនឹងចំនួននៃការបោះពុម្ពផ្សាយ និងការដកស្រង់សកល ប៉ុន្តែសកម្មភាពស្រាវជ្រាវក្នុងស្រុកកំពុងកើនឡើងជាលំដាប់។ ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នផ្សេងទៀត កំពុងគ្រប់គ្រងគម្រោងស្រាវជ្រាវរាប់រយ ដែលបង្ហាញពីសន្ទុះវិជ្ជមាន។ ក្តីកង្វល់ដ៏ស៊ីជម្រៅមួយដែលត្រូវបានលើកឡើងដោយអ្នកសិក្សាដែលមានបទពិសោធ គឺគោលបំណងនៃការស្រាវជ្រាវនេះ។ អ្នកស្រាវជ្រាវកម្ពុជាត្រូវបានលើកទឹកចិត្តឱ្យគិតគូរឱ្យបានឆ្ងាយជាងគោលដៅរយៈពេលខ្លី និងត្រូវចោទសួរនូវសំណួរសំខាន់ៗថា៖ តើយើងធ្វើការស្រាវជ្រាវនេះក្នុងគោលបំណងអ្វី ? តើវាផ្តល់ប្រយោជន៍ដល់នរណា ?

ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០មក ការស្រាវជ្រាវនៅកម្ពុជាភាគច្រើនផ្តោតលើការអភិវឌ្ឍ និងការកសាងឡើងវិញ ដែលជាការចាំបាច់បន្ទាប់ពីជម្លោះជាច្រើនទសវត្សរ៍។ ការស្រាវជ្រាវផ្តោតលើបរិបទជាក់ស្តែងបែបនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងប្រទេសឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ អ្នកសិក្សាស្រាវជ្រាវក៏បានលើកឡើងពីភាពចាំបាច់ ដែលត្រូវមានការស្រាវជ្រាវ ដែលមានលក្ខណៈឆ្លុះបញ្ចាំងបន្ថែមទៀត ដែលជាការសិក្សាស្វែងយល់អំពីអត្តសញ្ញាណ គុណតម្លៃ និងការកសាងចំណេះដឹង

រយៈពេលវែងជាដើម។ ប្រសិនបើការស្រាវជ្រាវត្រូវបានចាត់ទុកថាជាកិច្ចការបច្ចេកទេស ឬលក្ខខណ្ឌតម្រូវរបស់គម្រោងតែប៉ុណ្ណោះ វាអាចនឹងបាត់បង់តម្លៃក្នុងនាមជាសកម្មភាពសិក្សាអប់រំដែលមានអត្ថន័យ។ ការស្រាវជ្រាវបែបសិក្សា គួរតែជួយសម្រួចសង្គម រួមចំណែកដល់អត្តសញ្ញាណជាតិ និងកសាងមូលដ្ឋានចំណេះដឹងដែលបម្រើដល់មនុស្សជំនាន់ក្រោយ។

ស្ថានភាពស្រាវជ្រាវរបស់កម្ពុជា ក្នុងផ្នែកវិទ្យាសាស្ត្រមនុស្ស និងវិទ្យាសាស្ត្រសង្គម កំពុងមានភាពប្រសើរឡើង ដោយសារតែអ្នកសិក្សា និងនិស្សិត ជាពិសេស ស្ត្រីកាន់តែមានការចាប់អារម្មណ៍លើការសិក្សាក្នុងផ្នែកទាំងនេះ។ គោលនយោបាយរបស់រដ្ឋាភិបាល និងភាពជាដៃគូអន្តរជាតិ បានជួយគាំទ្រដល់កំណើននេះ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមសំខាន់ៗនៅតែមាន ដូចជា ការណែនាំបង្ហាញផ្លូវមានកម្រិត ការរំពឹងទុកមិនច្បាស់លាស់ កង្វះប្រព័ន្ធទិន្នន័យ និងភាពចាំបាច់ដែលត្រូវមានការឆ្លុះបញ្ចាំងការសិក្សាឱ្យបានស៊ីជម្រៅ។ សម្រាប់កម្ពុជា ការកសាងវប្បធម៌ស្រាវជ្រាវដ៏រឹងមាំ និងឯករាជ្យ ទាមទារឱ្យមានការថ្លឹងថ្លែងរវាងគោលដៅអភិវឌ្ឍន៍ជាមួយនឹងការឆ្លុះបញ្ចាំងការសិក្សាដ៏ស៊ីជម្រៅ និងធានាថាអ្នកស្រាវជ្រាវទាំងអស់ត្រូវបានផ្តល់សិទ្ធិអំណាច និងទទួលស្គាល់ចំពោះការរួមចំណែករបស់ពួកគេ។

## វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល

**វាគ្មិនកិត្តិយស**

**លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន លាង**

*ព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

**លោកបណ្ឌិត អ៊ា ដារិទ្ធ**

*ប្រធាននាយកដ្ឋានអភិរក្ស និងបុរាណវិទ្យា នៃអាជ្ញាធរជាតិព្រះវិហារ*

**កញ្ញា ប៊ុន ភូរី**

*អនុប្រធាន នៃបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ និងជាទីប្រឹក្សាស្រាវជ្រាវ វាយតម្លៃលទ្ធផលនៃគម្រោងរេដបូក នៃអង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា*

**លោក កែវ ដួង**

*សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាគ្រូបង្គោលនៃកម្មវិធីអ្នកស្រាវជ្រាវពន្លកចំណេះរបស់មជ្ឈមណ្ឌលខេមរសិក្សា*

**អ្នកសម្របសម្រួលកិច្ចពិភាក្សា**

**លោកបណ្ឌិត George Chigas**

*សាស្ត្រាចារ្យរង នៃសាកលវិទ្យាល័យ UMass Lowell*

# ការពិភាក្សាស្របពេលគ្នា ២ខ៖ បទបង្ហាញខ្លីៗ៖ គំនិតគោលនយោបាយតូចសម្រាប់អនាគតរបស់កម្ពុជា

*រៀបចំដោយ វេទិកាអនាគត*

អ្នកស្រាវជ្រាវវ័យក្មេង និងសមាជិកនៃសហគមន៍ដែលមិនសូវទទួលបានការយកចិត្តទុកដាក់ ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួចគន្លងអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ឱកាសសម្រាប់ពួកគេនៅតែមានកម្រិតដើម្បីចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចពិភាក្សាគោលនយោបាយប្រកបដោយបរិយាបន្ន និងផ្តោតលើដំណោះស្រាយ ជាពិសេសលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់លើប្រជាជនកម្ពុជាទូទៅ និងមានចំណូលទាប។

ដើម្បីជួយផ្សារភ្ជាប់គម្លាតនេះ វេទិកាអនាគត បានរៀបចំវគ្គបទបង្ហាញបែបខ្លី រយៈពេល ៨០នាទី ដោយផ្តល់នូវឱកាសដល់អ្នកស្រាវជ្រាវ និងអ្នកត្រិះរិះពិចារណាជំនាន់ក្រោយដែលមានឆន្ទៈខ្ពស់ក្នុងការបង្ហាញនូវគំនិតគោលនយោបាយតូចៗដែលមានឥទ្ធិពល និងប្រកបអត្ថន័យ ដោយផ្តោតលើបញ្ហាប្រចាំថ្ងៃដែលប្រជាជនកម្ពុជាមានចំណូលទាប និងសហគមន៍ដែលមិនសូវទទួលបានការយកចិត្តទុកដាក់កំពុងជួបប្រទះ។

បទបង្ហាញទាំងនេះបានស្វែងយល់ពីដំណោះស្រាយជាក់ស្តែង និងច្នៃប្រឌិត ដើម្បីកែលម្អជីវិតប្រចាំថ្ងៃ ក្រោមប្រធានបទដូចជា ផ្លូវសម្រាប់ថ្មើរជើង គន្លងផ្លូវរថយន្តក្រុងសាធារណៈ ការរៀបចំផ្លូវលំក្នុងសហគមន៍មានភាពងាយស្រួលធ្វើដំណើរសម្រាប់អ្នករស់នៅវ័យចាស់ វត្តអារាមជាកន្លែងផ្តល់ការអប់រំ ផ្លូវសុវត្ថិភាពសម្រាប់សិស្សទៅសាលារៀន ផ្សារប្រពៃណីជាមជ្ឈមណ្ឌលសម្រាប់ពង្រឹងសាមគ្គីភាពសង្គម និងការថែទាំដែលគោរពតាមអត្តសញ្ញាណ យេនឌ័រសម្រាប់សហគមន៍អ្នកប្តូរភេទ។

វាគ្មិនម្នាក់ៗបានបង្ហាញពីគំនិតគោលនយោបាយតូចមួយ ប៉ុន្តែជាគំនិតដែលអាចយកទៅអនុវត្តបាន ដែលជាដំណោះស្រាយដែលមានវិសាលភាពតូច ប៉ុន្តែផ្តល់នូវការ



ឆ្លើយតបជាក់ស្តែងចំពោះបញ្ហាប្រឈមប្រចាំថ្ងៃដែលសហគមន៍មិនសូវទទួលបានការយកចិត្តទុកដាក់នៅកម្ពុជាកំពុងជួបប្រទះ។ វគ្គនេះត្រូវបានរៀបចំឡើងដើម្បីបំផុសការពិភាក្សាដេញដោលលើសំណើគោលនយោបាយដែលមានមូលដ្ឋានច្បាស់លាស់ និងផ្តោតលើសហគមន៍ និងដើម្បីស្រាយបំភ្លឺការសន្មតនានា។ បន្ទាប់ពីបទបង្ហាញនីមួយៗ អ្នកចូលរួមបានចូលរួមដោយផ្ទាល់ជាមួយវាគ្មិន តាមរយៈចោទជាសំណួរ រិះគន់ និងផ្តល់ជាគំនិត ដើម្បីបង្កើនលទ្ធភាពអនុវត្ត និងផលជះនៃគំនិតទាំងនេះ។

តាមរយៈការរំលេចគំនិតដែលផ្តោតការយកចិត្តទុកដាក់លើប្រជាជនទាំងនេះ វគ្គនេះបានបង្ហាញពីរបៀបដែលការស្រាវជ្រាវ និងនវានុវត្តន៍ដឹកនាំដោយយុវជន អាចរួមចំណែកប្រកបដោយអត្ថន័យដល់ការរៀបចំគោលនយោបាយប្រកបដោយបរិយាបន្ន និងឆ្លើយតបនៅកម្ពុជា។



## សង្ខេបកិច្ចពិភាក្សា

វគ្គដែលមានការធ្វើបទបង្ហាញដោយយុវជននេះ បានបង្ហាញនូវគំនិតច្នៃប្រឌិតជាច្រើនពីសំណាក់អ្នកធ្វើបទបង្ហាញវ័យក្មេង ដែលបានឆ្លុះបញ្ចាំងពីបញ្ហាដែលសហគមន៍របស់ពួកគេកំពុងជួបប្រទះ និងបានលើកស្នើនូវដំណោះស្រាយជាក់ស្តែង សម្រាប់អនាគតរបស់កម្ពុជា។ បទបង្ហាញនីមួយៗបានលើកឡើងយ៉ាងច្បាស់ថា បញ្ហាប្រឈមប្រចាំថ្ងៃ ចាប់ពីបញ្ហាលំនៅឋាន និងការរៀបចំដែនដីទីក្រុង រហូតដល់កិច្ចគាំពារសង្គម សិទ្ធិជនជាតិភាគតិច និងការយកពន្ធមានទំនាក់ទំនងទៅនឹងកិច្ចពិភាក្សាគោលនយោបាយក្នុងកម្រិតទូលំទូលាយ។

បទបង្ហាញទី១ ដោយលោក **សែស អរុណសក្តា** បានផ្តោតលើលំនៅឋាន និងការតាំងទីលំនៅទីក្រុង។ លោកបានលើកឡើងថា ខណៈពេលដែលការអភិវឌ្ឍលំនៅឋានថ្មីៗ ដូចជា បុរីជាដើម អាចមើលទៅទំនើប គម្រោងទាំងនោះជារឿយៗចម្លងគំរូពីប្រទេសផ្សេង ដោយមិនបានពិចារណាលើបរិបទក្នុងស្រុករបស់កម្ពុជា។ ផ្ទៃដីសម្រាប់រុក្ខជាតិបៃតង និងកន្លែងដើរប្រកបដោយសុវត្ថិភាពនៅមានកម្រិត រួមជាមួយនឹងការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធមិនល្អ ធ្វើឱ្យគុណភាពជីវិតមានការថយចុះ។ លោក សែស អរុណសក្តា បានផ្តល់អនុសាសន៍ឱ្យផ្តល់អាទិភាពដល់អ្នកថ្មើរជើង ការបែងចែកតំបន់យានយន្ត និងតំបន់លំនៅឋានដាច់ដោយឡែកពីគ្នា និងធានាថាហេដ្ឋារចនាសម្ព័ន្ធ ដូចជាការប្រមូលសំណល់ និងផ្ទៃដីបៃតង ត្រូវបានរៀបចំរួចរាល់មុនពេលសាងសង់។ លោកបានចង្អុលបង្ហាញពីឧទាហរណ៍អន្តរជាតិ ដូចជា ប្លង់មេរបស់ទីក្រុងកូប៉ិនហាក ដែលចំណតរថយន្តស្ថិតនៅខាងក្រៅប្លុកលំនៅឋាន ដែលអនុញ្ញាតឱ្យមានកន្លែងទំនេរច្រើនសម្រាប់ការកម្សាន្ត និងសកម្មភាពសហគមន៍។ លោកបានសន្និដ្ឋានថា



តាមរយៈការផ្លាស់ប្តូរផ្នត់គំនិតបន្តិចបន្តួច កម្ពុជាអាចបង្កើតទីក្រុងដែលគួរឱ្យចង់រស់នៅ ធន់នឹងអាកាសធាតុ និងកាន់តែមានបរិយាបន្ន ។

បន្ទាប់មក **នេត ចន្ទមុនិនាថ** បានធ្វើបទបង្ហាញអំពីស្ត្រីដែលកំពុងធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលជាកម្លាំងពលកម្មស្ត្រីភាគច្រើននៅកម្ពុជា។ ផ្អែកលើការសង្កេតផ្ទាល់របស់កញ្ញា និងទិន្នន័យរបស់ អង្គការអន្តរជាតិខាងការងារ ( ILO ) កញ្ញាបានកត់សម្គាល់ថា ស្ត្រីភាគច្រើននៅតាមទីផ្សារ និងរោងចក្រ រកប្រាក់ចំណូលប្រចាំថ្ងៃដោយគ្មានការចុះបញ្ជី ឬទទួលបានកិច្ចគាំពារសង្គម។ ដើម្បីដោះស្រាយបញ្ហានេះ កញ្ញាបានស្នើឱ្យមានការដាក់ឱ្យប្រើប្រាស់នូវប្រាក់ចំណូលមូលដ្ឋានជាសកល សម្រាប់ស្ត្រីដែលធ្វើការងារក្រៅប្រព័ន្ធ។ កញ្ញាបានលើកឡើងថា ការធ្វើបែបនេះនឹងពង្រឹងសន្តិសុខហិរញ្ញវត្ថុរបស់ស្ត្រី បិទគម្លាតនៅក្នុងប្រព័ន្ធគាំពារសង្គម និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងសង្គម។ កញ្ញាក៏បានអំពាវនាវឱ្យមានការសម្របសម្រួលរវាងក្រសួង និងដៃគូ ក្នុងការកំណត់មុខសញ្ញាអ្នកទទួលផលឱ្យបានច្បាស់លាស់ និងប្រព័ន្ធតាមដានដ៏រឹងមាំ ដើម្បីជានាថិរភាព។

ជុំវិញបញ្ហាអត្តសញ្ញាណយេនឌ័រ និងបរិយាបន្ន **សាយ សៀកឡាយ** បាននិយាយអំពីបទពិសោធនៃសហគមន៍អ្នកប្តូរភេទ។ លោកបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការប្រើប្រាស់ពាក្យពេចន៍ប្រកបដោយការគោរព និងការឈប់ប្រើភាសាដែលមានការរើសអើង។ អ្នកប្តូរភេទជាច្រើនប្រឈមនឹងការចំណាយខ្ពស់សម្រាប់ការថែទាំសុខភាព និងខ្វះលទ្ធភាពទទួលបានសេវា ដែលសមស្របតាមតម្រូវការរបស់ពួកគេ។ លោកបានអំពាវនាវឱ្យមានការបញ្ចូលសំឡេងរបស់អ្នកប្តូរភេទ ក្នុងការរួមគ្នារៀបចំគោលនយោបាយ ដោយប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់ ជាជាងការបង្កើតប្រព័ន្ធថ្មី និងកែលម្អការប្រមូលទិន្នន័យអំពីអ្នក ប្តូរភេទ ដើម្បីធ្វើឱ្យមានការរំលេចកាន់តែច្បាស់ពីតម្រូវការរបស់ពួកគេ។

**ប៊ុន រិទ្ធី** បានរំលេចពីតួនាទីរបស់សហគមន៍ជនជាតិភាគតិចក្នុងការការពារព្រៃឈើរបស់កម្ពុជា។ លោកបានរំលឹកអង្គពិធីថា ជនជាតិដើមភាគតិចនៅលើពិភពលោកការពារជីវចម្រុះជាច្រើនរបស់ពិភពលោក។ ហើយនៅកម្ពុជាការអនុវត្តកសិកម្មបែបប្រពៃណី និងជំនឿវប្បធម៌របស់ពួកគេ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការអភិរក្សព្រៃឈើ។ ទោះជាយ៉ាងណាក៏ដោយ ការចុះបញ្ជីដីធ្លីសម្រាប់ក្រុមជនជាតិភាគតិចនៅតែមានភាពយឺតយ៉ាវ និងស្មុគស្មាញ ហើយមានសហគមន៍មួយចំនួនតូចប៉ុណ្ណោះដែលទទួលបានប័ណ្ណកម្មសិទ្ធិ។ លោកបានជំរុញឱ្យមានការចុះបញ្ជីដីធ្លីលឿនជាងមុន ពង្រឹងការអនុវត្តច្បាប់ និងកិច្ចសហការកាន់តែជិតស្និទ្ធជាមួយក្រុមជនជាតិភាគតិច ដើម្បីឱ្យមានការបញ្ចូលចំណេះដឹងប្រពៃណី និងការអនុវត្តវប្បធម៌ទៅក្នុងគោលនយោបាយគ្រប់គ្រងព្រៃឈើ។

**រុន សាវុទ្ធ** បានសិក្សាពីកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល និងការប្រើប្រាស់ប័ណ្ណគ្រួសារក្រីក្រ (IDPoor)។ លោកបានសង្កេតឃើញថា ប្រជាជនងាយរងគ្រោះជាច្រើនគ្រួសារ ជាពិសេសនៅតំបន់ទីប្រជុំជន ត្រូវបានទុកចោលនៅក្រៅប្រព័ន្ធ។ លោកបានស្នើឱ្យមានការធ្វើបច្ចុប្បន្នកម្មទិន្នន័យភាពក្រីក្រ ជារៀងរាល់ឆ្នាំ ជំនួសឱ្យការធ្វើរៀងរាល់បីឆ្នាំម្តង ការធ្វើដូចនេះបង្កើនតម្លាភាពតាមរយៈសវនកម្មឯករាជ្យ និងវេទិកាសាធារណៈ និងធានាថាជនក្រីក្រ ទាំងនៅជនបទ និងទីប្រជុំជន ត្រូវបានបញ្ចូល។ លោកបានលើកឡើងថា វិធានការបែបនេះនឹងជួយកម្ពុជាសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងការប្តេជ្ញាចិត្ត «មិនទុកនរណាម្នាក់ចោល»។

**និត កុសល** ផ្តោតការយកចិត្តទុកដាក់លើបញ្ហាភាពធន់ផ្នែកសេដ្ឋកិច្ច ដោយស្នើឱ្យមានការកែទម្រង់ប្រព័ន្ធពន្ធដាររបស់កម្ពុជា។ លោកបានពន្យល់ថា ការពឹងផ្អែកខ្លាំងលើការនាំចេញ រួមផ្សំជាមួយនឹងការបង្កើនពន្ធគយ និងសម្ពាធក្នុងតំបន់ ធ្វើឱ្យសេដ្ឋកិច្ចប្រឈមនឹងហានិភ័យ។ ដើម្បីធានាបាននូវប្រាក់ចំណូលបន្ថែម សម្រាប់ប្រើប្រាស់លើការងារអប់រំ សុខាភិបាល និងសុខុមាលភាពសង្គម លោកបានផ្តល់អនុសាសន៍ឱ្យពង្រឹងពន្ធលើអចលនទ្រព្យ និងប្រាក់ចំណូល ការពង្រីកការយកពន្ធលើវិស័យក្រៅប្រព័ន្ធ និងកែលម្អប្រព័ន្ធវាយតម្លៃអចលនទ្រព្យ។ ដើម្បីឱ្យការយកពន្ធទទួលបានជោគជ័យ លោកបានគូសបញ្ជាក់ថា ប្រជាពលរដ្ឋត្រូវចាត់ទុកពន្ធជាការវិនិយោគ និងជឿទុកចិត្តថាការចំណាយរបស់រដ្ឋាភិបាលពិតជាផ្តល់ប្រយោជន៍ដល់សង្គម។

ជាចុងក្រោយ បទបង្ហាញពី **កុច ស្រីមាន** ស្តីពីសុខុមាលភាពសត្វ បានស្នើច្បាប់ដើម្បីហាមឃាត់ការបរិភោគសាច់ឆ្កែ និងឆ្មា នៅកម្ពុជា ដោយដកស្រង់មេរៀនពីប្រទេសកូរ៉េខាងត្បូង និងតួគី។ វាគ្មិនរូបនេះបានលើកឡើងថា ច្បាប់បែបនេះនឹងលើកមុខមាត់របស់កម្ពុជាលើឆាកអន្តរជាតិ លើកកម្ពស់សុខុមាលភាពសត្វ និងជំរុញការផ្លាស់ប្តូរឥរិយាបទរបស់សាធារណជន។ ទន្ទឹមនឹងនេះ យន្តការគាំទ្រគឺពិតជាសម្រាប់ជួយអ្នកលក់ក្នុងការផ្លាស់ប្តូរចេញពីការជួញនេះ រួមនឹងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីគ្រប់គ្រងសត្វអនាថា។

## វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល

---

| | |
|---|---|
| **វាគ្មិនកិត្តិយស** | **លោក សែស អរុណសក្តា**<br>*អ្នកស្រាវជ្រាវ នៃវេទិកាអនាគត* |
| | **នេត ចន្ទមុនិនាថ**<br>*អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត* |
| | **សាយ សៀកឡាយ**<br>*អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត* |
| | **ប៊ុន រិទ្ធី**<br>*អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត* |
| | **វុន សារុទ្ធ**<br>*អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត* |
| | **និត កុសល**<br>*អ្នកស្រាវជ្រាវ នៃវេទិកាអនាគត និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា* |
| | **កុច ស្រីមាន**<br>*អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត* |

---

| | |
|---|---|
| **អ្នកសម្របសម្រួលកិច្ចពិភាក្សា** | **លោក ជា ដារ៉ា**<br>*ប្រធានកម្មវិធី នៃវេទិកាអនាគត* |

# សុន្ទរកថាពេញអង្គ

*លោកស្រី ម៉ាក់ មុនីកា*
*នាយិកាប្រតិបត្តិ*
*អង្គការជនពិការកម្ពុជា (អ.ព.ក)*

នាងខ្ញុំពិតជាមានកិត្តិយសក្រៃលែង ដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នៅក្នុងវេទិកាគោលនយោបាយថ្នាក់ជាតិនៃកម្មវិធីពន្លកចំណេះនាថ្ងៃនេះ ដែលយើងឆ្លុះបញ្ចាំងរួមគ្នាអំពីការអនុវត្តគោលនយោបាយប្រកបដោយបរិយាបន្ននៅកម្ពុជា។ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការមូលនិធិអាស៊ី រដ្ឋាភិបាលអូស្រ្តាលី និងដៃគូពាក់ព័ន្ធទាំងអស់ដែលបានរៀបចំវេទិកានេះឡើង ដែលផ្តល់អាទិភាព មិនត្រឹមតែលើទិន្នន័យ និងគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើមនុស្សផ្ទាល់ ជាពិសេស អ្នកដែលតែងតែត្រូវបានគេផាត់ចេញពីដំណើរការតាក់តែងគោលនយោបាយទៀតផង។

សម្រាប់នាងខ្ញុំ គោលនយោបាយប្រកបដោយបរិយាបន្ន មិនមែនជាគំនិតអរូបីនោះទេ តែវាទាក់ទង ថាតើស្រ្តីវ័យក្មេងម្នាក់ដែលមានពិការភាពដែលរស់នៅទីជនបទ នៃប្រទេសកម្ពុជាអាចបញ្ចប់ការសិក្សា ស្វែងរកការងារធ្វើ និងចូលរួមយ៉ាងពេញលេញនៅក្នុងសហគមន៍របស់នាងបានដែរឬទេ។

សម្រាប់ពួកយើងដែលធ្វើការក្នុងចលនាសិទ្ធិជនពិការ យើងតែងតែនិយាយអំពីបរិយាបន្ន ថាជាគោលការណ៍ ប៉ុន្តែបើនិយាយមែនទែនទៅ បរិយាបន្នគឺលើសពីគោលការណ៍ទៅទៀត គឺវាជាការអនុវត្តជាក់ស្តែង។ វាគឺជាដំណើរការមួយដែលត្រូវមានគោលបំណងច្បាស់លាស់ ត្រូវអនុវត្តជាប់ជាប្រចាំ និងមានការឆ្លុះបញ្ចាំងជាក់លាក់។ ព្រឹកមិញនេះ នាងខ្ញុំបានអង្គុយក្បែរស្រ្តីម្នាក់ដែលខ្សោយគំហើញ ដែលកំពុងកាន់របៀបវារៈជាអក្សរស្ទាបនៅក្នុងដៃរបស់គាត់។ នាងខ្ញុំមានការភ្ញាក់ផ្អើល នៅពេលដែលគាត់បានប្រាប់នាងខ្ញុំអំពីរបៀបវារៈបន្ទាប់ក្នុងវេទិកានេះ។ កម្មវិធីនេះបានបង្ហាញពីការអនុវត្តល្អនៃបរិយាបន្ន។

**អនុញ្ញាតឱ្យនាងខ្ញុំលើកឡើងនូវការវិវត្តសំខាន់ៗចំនួនបី ដែលផ្តល់ឱ្យយើងនូវសុទិដ្ឋិនិយម៖**

- ទី១ ប៉ុន្មានឆ្នាំចុងក្រោយនេះ យើងដឹងថាកម្ពុជាបានចាត់វិធានការប្រកបដោយអត្ថន័យជាច្រើន។ ការអនុម័តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០២៤-២០២៨ គឺជាសមិទ្ធផលដ៏ធំធេង ដែលដាក់ចេញនូវចក្ខុវិស័យលើកកម្ពស់សមធម៌ផាសុកសមរម្យ និងការពង្រឹងភាពអង់អាច។ ប៉ុន្តែបច្ច័យនៃយុទ្ធសាស្ត្រនេះ និងយុទ្ធសាស្ត្រផ្សេងទៀត គឺអាស្រ័យលើថាតើស្ថាប័ន និងប្រព័ន្ធរបស់យើងមានបរិយាបន្នពិតប្រាកដដល់កម្រិតណា។ តើនរណាជាអ្នកចូលរួមចំណែកក្នុងកិច្ចការងារនេះ ?

- ទី២ អូស្ត្រាលីបានដាក់ឱ្យដំណើរការនូវយុទ្ធសាស្ត្របរិយាបន្នពិការភាពថ្មីស្តីពី ការអភិវឌ្ឍសម្រាប់ទាំងអស់គ្នា ដោយចាត់ទុកបរិយាបន្នពិការភាព ជាស្នូលនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ខ្លួន។ ការប្តេជ្ញាចិត្តទាំងនេះបង្ហាញថា បរិយាបន្នពិការភាព មិនមែនជាបញ្ហាបន្ទាប់បន្សំទេ ប៉ុន្តែជាអាទិភាពសម្រាប់រដ្ឋាភិបាល និងដៃគូនានាផងដែរ។

- ទី៣ សម្រាប់អង្គការជនពិការកម្ពុជាផ្ទាល់ ក៏កំពុងស្ថិតក្នុងដំណើរការរៀបចំយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំរបស់ខ្លួន ដែលនឹងទាញប្រយោជន៍ពីប្រវត្តិការងាររបស់យើងជាយូរមកហើយ ពង្រឹងមូលដ្ឋានស្រាវជ្រាវ និងភស្តុតាងរបស់យើង ក៏ដូចជាពង្រីកសំឡេងរបស់ជនមានពិការភាព នៅក្នុងដំណើរការគោលនយោបាយជាតិ។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះរួមគ្នាផ្តល់ឱ្យយើងនូវកម្លាំងចលករ ដើម្បីកសាងសង្គមមួយកាន់តែមានបរិយាបន្ន។

**ប៉ុន្តែ ទន្ទឹមនឹងការវិវត្តដ៏សំខាន់ទាំងនេះ យើងត្រូវតែទទួលស្គាល់បញ្ហាប្រឈមចំនួនបីដែលនៅតែបន្តមាន៖**

- ទី១ បរិយាបន្ននៅតែត្រូវបានគេមើលឃើញថាជា «ការបន្ថែម» ជាជាងជាមូលដ្ឋានគ្រឹះ
- ទី២ ធនធានសម្រាប់បរិយាបន្នពិការភាព ផ្នែកហិរញ្ញវត្ថុ បច្ចេកទេស ឬធនធានមនុស្ស នៅតែមានកម្រិត
- ទី៣ ការចូលរួមតំណាងរបស់ជនមានពិការភាពនៅក្នុងការសម្រេចចិត្តនៅតែស្ថិតក្នុងកម្រិតទាបជាងអ្វីដែលគួរតែមាន។



ដូច្នេះ ទោះបីជាយើងអបអរសាទរចំពោះវឌ្ឍនភាពដែលបានសម្រេចបានកន្លងមកក៏ដោយ ក៏យើងត្រូវតែបង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដងដើម្បីបង្រួមគម្លាតទាំងនេះ។

នោះហើយជាមូលហេតុ ដែលយើងមានសេចក្ដីសោមនស្សរីករាយជាពិសេស ដែលកម្មវិធីពន្លកចំណេះបានជ្រើសរើសយកបរិយាបន្នពិការភាព ជាប្រធានបទសំខាន់សម្រាប់ឆ្នាំ២០២៥ នេះ។ ការសម្រេចចិត្តនេះធ្វើឡើងក្នុងពេលវេលាដ៏សមស្រប។ តាមរយៈការផ្ដល់អាទិភាពលើបរិយាបន្នពិការភាព កម្មវិធីពន្លកចំណេះកំពុងជួយធានាថា ដំណើរការពិភាក្សាគោលនយោបាយនៅកម្ពុជា មិនត្រឹមតែផ្អែកលើទិន្នន័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដំណើរការដែលតំណាងឱ្យប្រជាពលរដ្ឋទាំងអស់ផងដែរ។ ព្រឹកមិញនេះ ខ្ញុំបានលឺអ្នកខ្សោយកំហើញម្នាក់ បានលើកឡើងអំពីការចូលរួមរបស់ជនមានពិការភាពនៅក្នុងការស្រាវជ្រាវ។

បរិយាបន្នត្រូវតែចាប់ផ្ដើមពីសំណួរដំបូង ដែលយើងសួរនៅក្នុងការស្រាវជ្រាវរបស់យើង។ គេត្រូវបញ្ចូលបរិយាបន្នទៅក្នុងរបៀបដែលយើងប្រមូលទិន្នន័យ រៀបចំកិច្ចសន្ទនា ជ្រើសរើសភាសា និងកំណត់និយមន័យនៃភាពជោគជ័យ។ នោះហើយជាមូលហេតុ ដែលការប្រកាសដាក់ឱ្យប្រើប្រាស់ឯកសារគោលការណ៍ណែនាំរបស់កម្មវិធីពន្លកចំណេះស្ដីពីកិច្ចពិភាក្សាប្រកបដោយបរិយាបន្ន ។ ឧបករណ៍ទាំងនេះធ្វើឱ្យការស្រាវជ្រាវ មិនត្រឹមតែមានភាពម៉ត់ចត់ប៉ុណ្ណោះទេ ថែមទាំងកាន់តែមានភាពទូលំទូលាយទៀតផង។

ហើយបរិយាបន្ន មិននៅដាច់ដោយឡែកតែឯងនោះទេ។ វាមានទំនាក់ទំនងកាន់តែខ្លាំងឡើងជាមួយសកម្មភាពផ្សេងទៀត ដូចជា សមធម៌យេនឌ័រ ការចូលរួមរបស់យុវជន យុត្តិធម៌អាកាសធាតុ និងការអភិវឌ្ឍជនបទ។ ទំនាក់ទំនងទាំងនេះឆ្លុះបញ្ចាំងពីការពិតដ៏ស៊ីជម្រៅមួយ៖ ប្រជាជនរស់នៅត្រង់ចំណុចប្រសព្វនៃអត្តសញ្ញាណជាច្រើន ហើយគោលនយោបាយដែលល្អ ត្រូវតែឆ្លុះបញ្ចាំងពីភាពស្មុគស្មាញនោះ។

## បរិយាបន្នពិការភាពមានសារៈសំខាន់ជាមូលដ្ឋាន ដោយសារហេតុផលបួនយ៉ាង៖

- យោងតាមការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា គ្រួសារប្រមាណ ១២% មានសមាជិកយ៉ាងហោចណាស់ម្នាក់ជា ជនមានពិការភាព។ ប៉ុន្តែភាពជាតំណាងនៅក្នុងការសម្រេចចិត្ត និងការទទួលបានសេវាសាធារណៈ នៅតែមានកម្រិត។
- នៅក្នុងការប្រាស្រ័យទាក់ទង ដ្បិតរបៀបដែលយើងចែករំលែកចំណេះដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ របាយការណ៍ ឬវេទិកាសាធារណៈនោះទេ ជាកត្តាកំណត់ថាតើ ជនមានពិការភាពអាចទទួលបានព័ត៌មាន មើលឃើញខ្លួនឯងត្រូវបានគេតំណាង និងចូលរួមប្រកបដោយអត្ថន័យនៅក្នុងកិច្ចសន្ទនាថ្នាក់ជាតិដែរឬទេ។ នាងខ្ញុំកំពុងនិយាយខ្លាំងៗ ដើម្បីធានាថាសំឡេងរបស់នាងខ្ញុំអាចឮច្បាស់ដោយអ្នកដែលខ្សោយគំហើញ។
- នៅក្នុងកិច្ចពិភាក្សា ព្រោះជនមានពិការភាពនាំមកនូវការយល់ដឹងស៊ីជម្រៅ និងដំណោះស្រាយដែលធ្វើឱ្យកិច្ចពិភាក្សាថ្នាក់ជាតិស្តីពីវិស័យអប់រំ ការងារ សុខភាព និងអភិបាលកិច្ច កាន់តែសម្បូរបែប។
- នៅក្នុងគោលនយោបាយ ព្រោះថាច្បាប់ និងកម្មវិធីដែលមិនមានបរិយាបន្នងាយនឹងទុកចោលក្រុមមួយចំនួន និងធ្វើឱ្យវិសមភាពកាន់តែរីកធំ។

នៅអង្គការជនពិការកម្ពុជា និងនៅក្នុងកម្មវិធីពន្លកចំណេះ យើងជឿជាក់ថា ការស្រាវជ្រាវលើពិការភាព យុវជន ស្ត្រី ឬក្រុមណាមួយផ្សេងទៀត មិនត្រូវធ្វើឡើង អំពីពួកគាត់នោះទេ ប៉ុន្តែត្រូវធ្វើជាមួយពួកគាត់ ហើយបើអាចធ្វើទៅបាន គឺត្រូវធ្វើដោយពួកគាត់ផ្ទាល់។ គោលការណ៍នេះ គឺចាំបាច់សម្រាប់ការបង្កើតគំហើញស្រាវជ្រាវដែលសុក្រិត មានក្រមសីលធម៌ និងនាំមកនូវការផ្លាស់ប្តូរពិតប្រាកដ។ នាងខ្ញុំមានមោទនភាព ដែលអង្គការជនពិការកម្ពុជា ត្រូវបានគេទទួលស្គាល់កាន់តែច្រើននៅក្នុងវិស័យស្រាវជ្រាវនៅកម្ពុជា សម្រាប់ការជំរុញឱ្យមានការប្រើប្រាស់វិធីសាស្ត្របែបចូលរួម ដែលយកបទពិសោធក្នុងការរស់នៅជាក់ស្តែង មកដាក់ជាចំណុចស្នូលនៃការស្រាវជ្រាវនានា។

ប្រធានបទសំខាន់នៃវេទិកានេះ គឺការពិភាក្សាប្រកបដោយបរិយាបន្ន ដែលឆ្លុះបញ្ចាំងយ៉ាងជ្រាលជ្រៅពីគោលការណ៍នេះ។ ការពិភាក្សាពិតប្រាកដ មិនមែនជាការនិយាយតំណាងឱ្យបុគ្គលណាម្នាក់នោះទេ ប៉ុន្តែជាការបង្កើតលំហមួយដែលបុគ្គលគ្រប់រូបអាចនិយាយដោយខ្លួនឯងបាន។ ដូច្នេះ ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន គឺនិយាយអំពីអំណាច គឺអំពីថាតើនរណាជាអ្នកកំណត់បញ្ហា កំណត់ទម្រង់នៃការស្រាវជ្រាវ និងសម្រេចលើដំណោះស្រាយ។

ដូច្នេះ តើយើងត្រូវធ្វើអ្វីទៀតបន្ថែមលើការពិភាក្សានាថ្ងៃនេះ និងធានាថាបរិយាបន្នមិនមែនជាប្រធានបទដែលលើកមកការពិភាក្សាតែម្តងហើយចប់នោះទេ ប៉ុន្តែជាកត្តាដែលត្រូវយកមកពិចារណាជានិច្ចក្នុងការរៀបចំគោលនយោបាយនៅកម្ពុជា ?

### កម្មវិធីពន្លកចំណេះ និងដៃគូ អាចប្រើប្រាស់ប្រធានបទផ្តោតសំខាន់ក្នុងឆ្នាំនេះ ដើម្បី៖

- គាំទ្រឱ្យវិធីសាស្រ្តស្រាវជ្រាវ និងការបណ្តុះបណ្តាលនានា កាន់តែមានបរិយាបន្នពិការភាព
- ផ្តល់វេទិកា ដែលជនមានពិការភាព ជាពិសេសស្រ្តី និងយុវជន ជាសំឡេងស្នូល
- កសាងភាពជាដៃគូកាន់តែរឹងមាំ រវាងរដ្ឋាភិបាល សង្គមស៊ីវិល និងស្ថាប័នស្រាវជ្រាវ ដើម្បីអនុវត្តផែនការយុទ្ធសាស្រ្តជាតិស្តីពីពិការភាព



ប៉ុន្តែវាមិនមែនគ្រាន់តែអំពីស្ថាប័នប៉ុណ្ណោះទេ។ យើងម្នាក់ៗមានតួនាទីត្រូវបំពេញ។ មិនថាអ្នកតាក់តែងគោលនយោបាយ អ្នកស្រាវជ្រាវ ឬអ្នកតស៊ូមតិនោះទេ បរិយាបន្នទាមទារឱ្យមានការខិតខំប្រឹងប្រែងយ៉ាងសកម្មពីយើងគ្រប់ៗគ្នា។

នៅពេលដែលជនមានពិការភាព និងក្រុមដែលត្រូវបានគេផាត់ចេញផ្សេងទៀត ចូលរួមក្នុងការស្រាវជ្រាវ រៀបចំកម្មវិធី និងរៀបចំគោលនយោបាយ យើងនឹងទទួលបានលទ្ធផលល្អប្រសើរសម្រាប់មនុស្សគ្រប់គ្នា។



នាពេលបន្តិចទៀតនេះ យើងនឹងអបអរសាទរពិធីប្រគល់ពានរង្វាន់បរិយាបន្ន ហើយសូមយើងទាំងអស់គ្នាចងចាំថា ពានរង្វាន់ពិតប្រាកដមិនមែនជាវិញ្ញាបនបត្រ ឬពាននោះទេ វាគឺជាវឌ្ឍនភាពដែលយើងសម្រេចបានក្នុងការកសាងប្រទេសកម្ពុជាមួយដែលទិន្នន័យ ការពិភាក្សា និងគោលនយោបាយឆ្លុះបញ្ចាំងពីសំឡេងរបស់មនុស្សគ្រប់រូប។

ហើយនោះគឺជាអ្វីដែលពានរង្វាន់ថ្ងៃនេះទទួលស្គាល់យ៉ាងពិតប្រាកដ នោះគឺជា ឧទាហរណ៍ជាក់ស្តែង និងបំផុសគំនិតអំពីការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការពិភាក្សា ដែលមិនត្រឹមតែផ្តោតលើ បរិយាបន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានកម្លាំងជំរុញបរិយាបន្នទៀតផង។

ជាចុងក្រោយ នៅក្នុងយុគសម័យនៃការរំខានដោយសារកត្តាអាកាសធាតុ បម្រែបម្រួលសេដ្ឋកិច្ច និងភាពមិនប្រាកដប្រជាសកល សូមយើងកុំដកខ្លួនថយទៅរកដំណោះស្រាយបែបបច្ចេកទេស ដែលចាត់ទុកមនុស្សគ្រាន់តែជាតួលេខ។ ផ្ទុយទៅវិញ សូមយើងងាកមកពឹងផ្អែកលើការរៀនសូត្ររួមគ្នា ការគោរពគ្នាទៅវិញទៅមក និងជំនឿ ដែលថាសំឡេងរបស់មនុស្សគ្រប់រូបសុទ្ធតែមានតម្លៃ។

នាងខ្ញុំសង្ឃឹមថា វេទិកាថ្ងៃនេះមិនមែនជាទីបញ្ចប់នៃការពិភាក្សានោះទេ ប៉ុន្តែជាចំណុចចាប់ផ្តើមមួយ។ សូមនាំយកថាមពល គំនិត និងការប្តេជ្ញាចិត្តដែលយើងបានឃើញនៅថ្ងៃនេះដើម្បីធ្វើដំណើរទៅមុខ ។

សូមអរគុណ។

# ពិធីប្រគល់ពានរង្វាន់បរិយាបន្ន៖ ចំណាប់អារម្មណ៍របស់ជ័យលាភី

ក្នុងការលើកកម្ពស់បរិយាបន្ននៅក្នុងដំណើរការគោលនយោបាយ កម្មវិធីពន្លកចំណេះបាន រៀបចំ ពិធីប្រគល់ពានរង្វាន់បរិយាបន្ន សម្រាប់ឆ្នាំ២០២៥ ដើម្បីទទួលស្គាល់កិច្ចខិតខំប្រឹង ប្រែងដែលលើកកម្ពស់ទៅលើ ការស្រាវជ្រាវប្រកបដោយបរិយាបន្ន ការផ្សព្វផ្សាយលទ្ធផល ស្រាវជ្រាវប្រកបដោយបរិយាបន្ន និងការពិភាក្សាប្រកបដោយបរិយាបន្ននៅកម្ពុជា ទាំងនៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ពានរង្វាន់ទាំងនេះលើកទឹកចិត្តដល់បុគ្គល ក្រុម និងអង្គការដែល បានបង្ហាញការប្តេជ្ញាចិត្តចំពោះបរិយាបន្ន តាមរយៈការទទួលស្គាល់ និងការដោះស្រាយនូវ តម្រូវការរបស់ក្រុមចម្រុះ និងការលើកកម្ពស់សមធម៌ ផាសុកវត្ត និងការចូលរួមប្រកប ដោយអត្ថន័យរបស់ក្រុមចម្រុះនៅក្នុងការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការពិភាក្សា។

គោលបំណងនៃការប្រគល់ពានរង្វាន់ទាំងនេះ គឺដើម្បីទទួលស្គាល់ និងលើកទឹកចិត្តដល់ស្នាដៃ ដែលបង្ហាញពីបរិយាបន្ន តាមរយៈការស្រាវជ្រាវប្រកបដោយនវានុវត្តន៍ លទ្ធផលស្រាវជ្រាវ ដែលងាយស្រួលយល់ និងប្រកបដោយបរិយាបន្ន ឬការពិភាក្សា ដែលឆ្លើយតបនឹងតម្រូវការ និងទស្សនៈរបស់ក្រុមចម្រុះនៅក្នុងដំណើរការគោលនយោបាយនៅថ្នាក់ក្រោមជាតិ ឬថ្នាក់ជាតិ។

**ពានរង្វាន់ទាំងនេះមានគោលដៅ៖**

**បង្ហាញពីកិច្ចខិតខំប្រឹងប្រែងផ្តួចផ្តើម ដែលលើកកម្ពស់ និងដាក់ឱ្យអនុវត្តនូវបរិយាបន្ន និងផាសុកវត្ត**

**បំផុសគំនិត និងលើកទឹកចិត្តអ្នកដទៃឱ្យបញ្ចូលបរិយាបន្នទៅក្នុងការងាររបស់ពួកគេ**

**ផ្តល់វេទិកាសម្រាប់ចែករំលែកឧត្តមានុវត្តន៍ល្អបំផុតក្នុងការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការពិភាក្សាប្រកបដោយបរិយាបន្ន។**

## ពានរង្វាន់ការស្រាវជ្រាវប្រកបដោយបរិយាបន្ន

*ផ្តល់ការលើកទឹកចិត្តដល់គំនិតផ្តួចផ្តើមស្រាវជ្រាវដែលផ្តោតអាទិភាពលើបរិយាបន្នក្នុងវិធីសាស្ត្រនានា ចំណុចផ្តោតសំខាន់ និងអភិក្រមបែបសហការ។*




ជ័យលាភីនៃពានរង្វាន់ការស្រាវជ្រាវប្រកបដោយបរិយាបន្ន បានទៅលើសមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ (ច.ក.យ៉.ក.ស.ក) សម្រាប់ការស្រាវជ្រាវវាយតម្លៃស្ថានភាពសិទ្ធិកុមារដែលសមាគមនេះបានប្រើប្រាស់ឧបករណ៍កុមារមេត្រី និងផ្តល់សិទ្ធិអំណាចដល់កុមារមកពីមជ្ឈដ្ឋានចម្រុះឱ្យចូលរួម និងចែករំលែកសំឡេង(គំនិត) របស់ពួកគេ ព្រមទាំងបានជំរុញការចូលរួមពីអ្នកពាក់ព័ន្ធដ៏ទៃទៀតផងដែរ។

«សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ គ្រាន់តែជាអង្គការតូចមួយដែលធ្វើការលើសិទ្ធិកុមារ។ ការស្រាវជ្រាវរបស់យើងមានបរិយាបន្នដោយសារយើងបានរាប់បញ្ចូលកុមារ កុមារមានពិការភាព កុមារដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ[១៤] ឬ LGBTQI+ និងកុមារជនជាតិដើមភាគតិចទៅក្នុងការស្រាវជ្រាវ។ យើងបង្កើតស្នាដៃស្រាវជ្រាវនេះឡើង ដើម្បីផ្តល់ព័ត៌មានដល់រដ្ឋាភិបាលដើម្បីបញ្ចូលលទ្ធផលរកឃើញរបស់យើង ទៅក្នុងផែនការគោលនយោបាយជាតិ។ នាងខ្ញុំសូមថ្លែងអំណរគុណដល់អង្គការ Save the Children ដែលបានប្រាប់ព័ត៌មានពានរង្វាន់នេះមកយើងខ្ញុំ និងបានស្នើឈ្មោះយើងខ្ញុំ។ យើងក៏សូមអរគុណដល់កម្មវិធីពន្លកចំណេះ និងការរួមចំណែកពីអង្គការជនពិការកម្ពុជា។ មានអង្គការចំនួនបីដែលធ្វើការលើរឿងនេះ គឺ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ អង្គការជនពិការកម្ពុជា និងអង្គការ WOMEN។

[១៤] SOGIE ជាពាក្យកាត់នៃ និន្នាការផ្លូវភេទ អត្តសញ្ញាណយេនឌ័រ និងការបញ្ចេញមតិយេនឌ័រ។

នាងខ្ញុំសូមថ្លែងអំណរគុណដល់គណៈកម្មការរៀបចំ និងគណៈកម្មការជ្រើសរើសសម្រាប់ពានរង្វាន់ការស្រាវជ្រាវប្រកបដោយបរិយាបន្ននេះ។ ក្នុងនាមសមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ យើងនឹងបន្តខិតខំប្រឹងប្រែង និងពង្រឹងការប្រមូលទិន្នន័យរបស់យើងឱ្យកាន់តែមានបរិយាបន្ន ដើម្បីលើកទឹកចិត្តឱ្យមានការអនុវត្តសិទ្ធិកុមារកាន់តែប្រសើរឡើងនៅក្នុងសហគមន៍កម្ពុជា»។ — *លោកស្រី នាក់ សុគន្ធា ប្រធានគណៈកម្មាធិការប្រតិបត្តិ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ*

## ពានរង្វាន់ការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវប្រកបដោយបរិយាបន្ន

*ការទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយប្រកបដោយនវានុវត្តន៍ ដែលបង្ហាញការស្រាវជ្រាវ តាមរយៈទម្រង់ចម្រុះ និងងាយស្រួលយល់ ដើម្បីឱ្យមនុស្សគ្រប់គ្នាអាចចូលរួម និងយល់ពីទិន្នន័យ។*

ជ័យលាភីនៃពានរង្វាន់ការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវប្រកបដោយបរិយាបន្ន បានទៅលើ **កញ្ញា តាត នីកា** សម្រាប់ការរួមចំណែករបស់កញ្ញា ក្នុងការផ្សព្វផ្សាយមានផាសុកវត្ថុលើការស្រាវជ្រាវក្រោមប្រធានបទ **«សមត្ថភាពយើង លើសពីពិការភាពយើង»** តាមរយៈទម្រង់នានា ដូចជា ការនិទានរឿងជាសំឡេង អក្សរស្ទាប ទម្រង់ដែលងាយស្រួលសម្រាប់កម្មវិធីអានអេក្រង់ និងពិព័រណ៍ ដែលជួយបំបែករបាំងនៃការយល់ដឹងក្នុងចំណោមជនមានពិការភាព និងសាធារណជន ព្រមទាំងជំរុញឱ្យមានការពិភាក្សា និងលើកកម្ពស់ការយល់ដឹង។

«នាងខ្ញុំមិននឹកស្មាន ថានាងខ្ញុំគឺជាជ័យលាភីនៃពានរង្វាន់ការផ្សព្វផ្សាយប្រកបដោយបរិយាបន្ននេះ។ នាងខ្ញុំមកទីនេះដើម្បីចូលរួមកម្មវិធី និងអបអរសាទរជ័យលាភី។ នាងខ្ញុំស្រក់ទឹកភ្នែកដោយក្ដីរំភើប និងរីករាយ។ នាងខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារអង្គការនារីដើម្បីសន្តិភាព រួមមានអ្នកស្រី ស៊ុយហៀង និងអ្នកស្រី ចរិយា ក៏ដូចជា កម្មវិធីពន្លកចំណេះ សម្រាប់ការលើកទឹកចិត្តរបស់ពួកគេ។ នាងខ្ញុំនឹងបន្តខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីជួយជនមានពិការភាព ជាពិសេសស្ត្រី។ ដូច្នេះ សូមកុំអស់សង្ឃឹម ដរាបណាយើងនៅមានដង្ហើម យើងអាចបង្កើតការផ្លាស់ប្ដូរបាន»។ — *កញ្ញា តាត នីកា*

# ពានរង្វាន់ការពិភាក្សាប្រកបដោយបរិយាបន្ន

*ការទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងដែលជំរុញការចូលរួមប្រកបដោយអត្ថន័យរបស់ក្រុមចម្រុះ ដោយបង្កើតលំហដែលមានសុវត្ថិភាព និងការគោរពសំឡេង(គំនិត) ផ្សេងៗ ត្រូវបានស្តាប់ឮ និងផ្តល់តម្លៃ។*

ជ័យលាភីនៃពានរង្វាន់ការពិភាក្សាប្រកបដោយបរិយាបន្ន បានទៅលើ **ក្រុមល្ខោនផ្ទះ** សម្រាប់ការសម្តែងសិល្បៈដឹកនាំដោយសហគមន៍ដ៏មានឥទ្ធិពលរបស់ពួកគេ ដែលចូលរួមដោះស្រាយបញ្ហាសង្គម ចាប់ពីការរើសអើងលើក្រុម LGBTQI+ រហូតដល់បទពិសោធរបស់ជនមានពិការភាព និងអ្នករស់រានមានជីវិតពីអំពើហិង្សាយេនឌ័រ តាមរយៈការលើកកម្ពស់ការយល់ដឹង។

> «សូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះការផ្តល់ពានរង្វាន់នេះដល់ក្រុមរបស់យើងខ្ញុំ។ នាងខ្ញុំតំណាងឱ្យក្រុមល្ខោនផ្ទះ យើងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបង្កើតលទ្ធផលបែបនេះ ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើចីរភាព និងការផ្លាស់ប្តូររយៈពេលវែង។ សូមអរគុណដល់គណៈកម្មការជ្រើសរើស។ យើងចង់ឱ្យទស្សនិកជនមើលឃើញពីតម្លៃនៃការអប់រំ និងសង្គម នៅក្នុងការសម្តែងរបស់យើង ហើយយើងសូមអញ្ជើញអ្នកទាំងអស់គ្នាឱ្យមកទស្សនាស្នាដៃរបស់ក្រុមល្ខោនផ្ទះ»។ — អ្នកស្រី អ៊ឹង ចាន់នី តំណាងក្រុមល្ខោនផ្ទះ






លោកស្រី Evangeline Larsen
លេខាទី២ ស្ថានទូតអូស្ត្រាលី
ប្រចាំប្រទេសកម្ពុជា

# សុន្ទរកថាបិទកម្មវិធី

"

ខ្ញុំពិតជាមានកិត្តិយសក្រៃលែង ដែលបានចូលរួមក្នុងវេទិកាគោលនយោបាយថ្នាក់ជាតិឆ្នាំ២០២៥ ជាមួយអ្នកទាំងអស់គ្នានាថ្ងៃនេះ។ ក្នុងនាមរដ្ឋាភិបាលអូស្ត្រាលី នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះរាជរដ្ឋាភិបាលកម្ពុជា ទីស្តីការគណៈរដ្ឋមន្ត្រី ដៃគូរបស់យើង នៅអង្គការមូលនិធិអាស៊ី ព្រមទាំងស្ថាប័នស្រាវជ្រាវកម្ពុជា អង្គការសង្គមស៊ីវិល និងអ្នកចូលរួមទាំងអស់ដែលបានធ្វើឱ្យព្រឹត្តិការណ៍នេះអាចប្រព្រឹត្តទៅបាន។

ពេញមួយថ្ងៃនេះ យើងបានឃើញពីតម្លៃពិតនៃការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ។ កិច្ចពិភាក្សានានាបានរំលឹកយើងថា ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ន មិនមែនត្រឹមតែជាការសរសេរគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែជាការធានាថាគោលនយោបាយទាំងនោះ ផ្អែកទៅលើទិន្នន័យ ការពិភាក្សា និងឆ្លើយតបទៅនឹងតថភាពជាក់ស្តែងរបស់ប្រជាជនកម្ពុជា រួមទាំងស្ត្រី យុវជន ជនមានពិការភាព និងជនជាតិភាគតិច។

អូស្ត្រាលីមានកិត្តិយស ដែលបានក្លាយជាអ្នកគាំទ្ររយៈពេលវែង ដល់វិស័យស្រាវជ្រាវដ៏មានតម្លៃរបស់កម្ពុជា។ តាមរយៈកម្មវិធីពន្លកចំណេះដំណាក់កាលទី២នេះ យើងកំពុងជួយធ្វើឱ្យកិច្ចសហការរវាងអ្នកតាក់តែងគោលនយោបាយ អ្នកស្រាវជ្រាវ និងសហគមន៍កាន់តែស៊ីជម្រៅ ពង្រឹងការផ្តល់ទិន្នន័យដ៏រឹងមាំ និងមានបរិយាបន្ន និងគាំទ្រភាពជាអ្នកដឹកនាំក្នុងស្រុក ក្នុងការដោះស្រាយបញ្ហាប្រឈមនៃការអភិវឌ្ឍរបស់កម្ពុជា។ នេះគឺជាផ្នែកមួយនៃការរួមចំណែកដ៏ទូលំទូលាយរបស់អូស្ត្រាលី ចំពោះការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា តាមរយៈការគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស ភាពធន់នឹងអាកាសធាតុ អភិបាលកិច្ចប្រកបដោយបរិយាបន្ន និងកំណើនសេដ្ឋកិច្ច។

"

## ចំណុចលេចធ្លោមួយចំនួនពីវេទិកាថ្ងៃនេះ រួមមាន៖

- នាងខ្ញុំមានចិត្តរីករាយក្រៃលែង ដែលរបៀបវារៈ និងកិច្ចពិភាក្សានៃវេទិកាថ្ងៃនេះ ត្រូវបានរៀបចំឡើងដោយដៃគូស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល ដែលជាសញ្ញាដ៏រឹងមាំបង្ហាញថាវិស័យស្រាវជ្រាវកម្ពុជា បានផ្លាស់ប្តូរឆ្ពោះទៅរកការពិភាក្សា និងការបង្កើតរួមគ្នា។[១៥]
- ការពិភាក្សាស្របពេលគ្នា បានស្វែងយល់ពីបញ្ហាចំពោះមុខមួយចំនួន៖ របៀបដែលទិន្នន័យអាចតម្រង់ទិសឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ការធ្វើចំណាកស្រុក និងកិច្ចគាំពារសង្គម របៀបបញ្ចូលសំឡេងសហគមន៍ ទៅក្នុងការសម្រេចចិត្តអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ របៀបដែល ស្ថាប័នសិក្សាអាចពង្រឹងសមត្ថភាពស្រាវជ្រាវ ដើម្បីផ្តល់ព័ត៌មានដល់គោលនយោបាយជាតិ និងរបៀបដែលយុវជន និងបណ្តាញយុវជន កំពុងជំរុញការចូលរួមរបស់ពួកគេនាពេលបច្ចុប្បន្ន។
- វេទិកានេះក៏បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្រោមយុទ្ធសាស្រ្តបញ្ចកោណ ក៏ដូចជាយុទ្ធសាស្រ្តជាតិថ្មីរបស់កម្ពុជាស្តីពីសមភាពយេនឌ័រ ពិការភាព កិច្ចគាំពារសង្គម និងការប្រែប្រួលអាកាសធាតុ និងគំនិតផ្តួចផ្តើមជាច្រើនទៀត ដើម្បីគាំទ្រដល់វិស័យស្រាវជ្រាវកម្ពុជា។
- យើងក៏រីករាយដែលបានឃើញការសម្ពោធដាក់ឱ្យប្រើប្រាស់ឯកសារគោលការណ៍ណែនាំនៃកម្មវិធីពន្លកចំណេះ ស្តីពីគុណភាពនៃការស្រាវជ្រាវ និងកិច្ចពិភាក្សាប្រកបដោយបរិយាបន្នាថ្ងៃនេះ។
- ពិធីប្រគល់ពានរង្វាន់បរិយាបន្ន គឺជាចំណុចលេចធ្លោមួយទៀតនៅថ្ងៃនេះ ដែលបង្ហាញយើងយ៉ាងច្បាស់ថា អ្វីដែលយើងខិតខំសម្រេចឱ្យបាន ដូចជាចំណុចដែលមានចែងនៅក្នុងគោលការណ៍ណែនាំនោះ កំពុងកើតឡើងពិតប្រាកដនៅក្នុងជីវិតជាក់ស្តែង។ យើងសង្ឃឹមថាការងាររបស់ពួកគេនឹងបំផុសគំនិតយើងទាំងអស់គ្នា ធ្វើឱ្យបរិយាបន្នក្លាយជាបទដ្ឋាននៅក្នុងការងាររបស់យើងទាំងអស់គ្នា។

## ដូច្នេះ សំណួរគឺថា៖ តើមានអ្វីបន្តទៀត? វេទិកាដូចនេះមានសារៈសំខាន់ ប៉ុន្តែការធ្វើតេស្តពិតប្រាកដ គឺអ្វីដែលកើតឡើងបន្ទាប់ពីវេទិកាបញ្ចប់។

- តើកិច្ចសហការរវាងវិស័យស្រាវជ្រាវ និងក្រសួងស្ថាប័នរដ្ឋាភិបាល នឹងកាន់តែស៊ីជម្រៅនៅក្នុងការតាក់តែងគោលនយោបាយ និងការធ្វើផែនការដែរឬទេ?
- តើស្ថាប័នស្រាវជ្រាវនឹងបន្តវិនិយោគលើបរិយាបន្ន មិនមែនគ្រាន់តែជាតម្លៃប៉ុណ្ណោះទេ ប៉ុន្តែជាការអនុវត្តដែរឬទេ?
- តើម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ នឹងរក្សាពេលវេលា លំហ និងភាពបត់បែនដែលត្រូវការសម្រាប់កិច្ចពិភាក្សាប្រកបដោយអត្ថន័យដែរឬទេ?

---

[១៥] អ្នកដែលបានរៀបចំវគ្គទាំងនេះរួមមាន៖ CDRI-NISA, CPS – My village, CKS, Future Forum, និង GEDSI Consortium។

នាងខ្ញុំជឿជាក់ថាចម្លើយគឺ «បាទ/ចាស» ហើយ នាងខ្ញុំជឿជាក់បែបនេះ ព្រោះនាងខ្ញុំឃើញការប្តេជ្ញាចិត្តនៅក្នុងសាលវេទិកានេះ។ ហើយនាងខ្ញុំទន្ទឹងរង់ចាំស្តាប់បន្ថែមទៀតអំពីវេទិកាថ្នាក់ខេត្ត ដែលដៃគូកម្មវិធីពន្លកចំណេះនឹងរៀបចំ។

ក្នុងនាមរដ្ឋាភិបាលអូស្ត្រាលី នាងខ្ញុំសូមបញ្ចប់សុន្ទរកថា ដោយបញ្ជាក់ជាថ្មីពីការបន្តប្តេជ្ញាចិត្តរបស់យើង ដើម្បីគាំទ្រដល់អភិបាលកិច្ចប្រកបដោយបរិយាបន្ននៅកម្ពុជា។ យើងជឿជាក់ថាស្ថាប័នរឹងមាំ ភាពជាអ្នកដឹកនាំដែលមានគណនេយ្យភាព និងដំណើរការដែលមានបរិយាបន្នមិនមែនជាភាពប្រណីតនោះទេ តែជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

**ជាចុងក្រោយ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះ៖**

ដៃគូកម្មវិធីពន្លកចំណេះ ទាំងដៃគូយុទ្ធសាស្ត្រ ទាំងដៃគូនវានុវត្តន៍ សមាជិកក្រុមជំនាញផ្នែកយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ

អ្នកស្រាវជ្រាវ និងអ្នកសម្របសម្រួលពោរពេញដោយការប្តេជ្ញាចិត្ត ដែលបានធ្វើឱ្យកិច្ចពិភាក្សាថ្ងៃនេះមានភាពរស់រវើក

ដៃគូរដ្ឋាភិបាល និងតំណាងក្រសួងនានា ដែលបានចែករំលែកមតិដោយបើកចំហ និងក្នុងស្មារតីស្ថាបនា

និងក្រុមការងារអង្គការមូលនិធិអាស៊ី សម្រាប់ការសម្របសម្រួល និងចក្ខុវិស័យរបស់ពួកគេ។

ខណៈដែលយើងបញ្ចប់កម្មវិធីជាផ្លូវការ នាងខ្ញុំសូមអញ្ជើញអ្នកទាំងអស់គ្នាចូលរួមក្នុងកម្មវិធីជប់លៀងភ្ជាប់បណ្តាញ។ វាគឺជាឱកាសមួយ ដើម្បីបន្តកិច្ចពិភាក្សា ពង្រឹងទំនាក់ទំនង និងកសាងភាពជាដៃគូ ដែលនឹងនាំយកស្មារតីនៃកិច្ចពិភាក្សា និងកិច្ចសហការនៃថ្ងៃនេះទៅមុខបន្តទៀត។

សូមអរគុណ និងសូមជូនពរឱ្យអ្នកទាំងអស់គ្នា ទទួលបានជោគជ័យជាបន្តបន្ទាប់នៅក្នុងការងារដ៏សំខាន់របស់ខ្លួន។

# សេចក្តីសន្និដ្ឋាន

វេទិកាគោលនយោបាយថ្នាក់ជាតិនៃកម្មវិធីពន្លកចំណេះ ឆ្នាំ២០២៥ ត្រូវបានរៀបចំឡើងចំពេលដ៏សំខាន់មួយ ខណៈពេលដែលកម្ពុជាកំពុងប្រឹងប្រែងពង្រឹងការតាក់តែងគោលនយោបាយ ផ្អែកលើទិន្នន័យ និងប្រកបដោយបរិយាបន្ន។ រៀបចំឡើងក្រោមប្រធានបទ «ការតាក់តែងគោលនយោបាយប្រកបដោយបរិយាបន្ននៅក្នុងបរិបទប្រែប្រួល៖ ការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ» អ្នកចូលរួមបានបញ្ជាក់ជាថ្មីថា វិស័យស្រាវជ្រាវរបស់កម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួចការសម្រេចចិត្តគោលនយោបាយ ផ្អែកលើទិន្នន័យគួរឱ្យទុកចិត្ត និងការពិភាក្សាប្រកបដោយបរិយាបន្ន។

តាមរយៈកិច្ចពិភាក្សានានា វគ្គពិភាក្សានីមួយៗបានរំលេចពីវឌ្ឍនភាពសំខាន់ៗ ចាប់ពីការពង្រឹងសមត្ថភាពស្រាវជ្រាវ និងការផ្សារភ្ជាប់គម្លាត រវាងទិន្នន័យថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន រហូតដល់ការធ្វើសមាហរណកម្មគោលនយោបាយប្រែប្រួលអាកាសធាតុ ការធ្វើចំណាកស្រុក និងកិច្ចគាំពារសង្គម និងការធានាថា សហគមន៍ជនបទ និងសហគមន៍ដែលមិនសូវទទួលបានការយកចិត្តទុកដាក់ មិនត្រូវបានទុកចោលឡើយ។ វេទិកានេះក៏បានអបអរសាទរចំពោះសមិទ្ធផលលេចធ្លោនៅក្នុងការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការពិភាក្សាប្រកបដោយបរិយាបន្ន តាមរយៈពិធីប្រគល់ពានរង្វាន់បរិយាបន្ន ដែលជាការទទួលស្គាល់អង្គការ និងបុគ្គលនៅកម្ពុជាដែលជំរុញផាសុកវត្ថុ និងការចូលរួមនៅគ្រប់ដំណាក់កាលនៃដំណើរការគោលនយោបាយ។

មេរៀនអន្តរវិស័យមួយចំនួន បានលេចឡើងពីកម្មវិធីនេះ។ ទី១ កិច្ចសហការរវាងរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងសហគមន៍ នៅតែមានសារៈសំខាន់ ដើម្បីធានាការប្រើប្រាស់ទិន្នន័យ និងភស្តុតាងប្រកបដោយអត្ថន័យនៅក្នុងការតាក់តែង និងការអនុវត្តគោលនយោបាយ។ ទី២ បរិយាបន្នត្រូវតែឈានទៅហួសពីការពិគ្រោះយោបល់ ដើម្បីក្លាយជាការអនុវត្តមួយជាស្តង់ដារ ដែលស្ត្រី យុវជន ជនមានពិការភាព និងជនជាតិភាគតិច គឺជាអ្នកចូលរួមចំណែកយ៉ាងសកម្មចំពោះការស្រាវជ្រាវ និងការពិភាក្សា។ និងទី៣ ការវិនិយោគប្រកប



ដោយចីរភាពនៅក្នុងវិស័យស្រាវជ្រាវកម្ពុជា ចាប់ពីប្រព័ន្ធទិន្នន័យថ្នាក់ជាតិ រហូតដល់បណ្តាញស្រាវជ្រាវថ្នាក់មូលដ្ឋាន មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីពង្រឹងភាពធន់ និងសមត្ថភាពបន្សាំរបស់ប្រទេសជាតិ។

វេទិកានេះបានរំលេចពីការប្តេជ្ញាចិត្តរួមគ្នារបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ី ក្នុងការបណ្តុះបរិយាកាសគោលនយោបាយ ដែលចាក់ឫសលើភាពបើកចំហ ទិន្នន័យ និងបរិយាបន្ន។ អ្វីដែលសំខាន់ផងដែរនោះ វេទិកានេះបានឆ្លុះបញ្ចាំងពីភាពជាអ្នកដឹកនាំ ដែលកំពុងកើនឡើងនៃស្ថាប័នស្រាវជ្រាវកម្ពុជា អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ក្នុងការកំណត់ និងទ្រទ្រង់កិច្ចខិតខំប្រឹងប្រែងទាំងនេះ។ ជាជំហានបន្ទាប់ កម្មវិធីពន្លកចំណេះ និងដៃគូ នឹងបន្តពង្រឹងកិច្ចសហការ ក្រោមការដឹកនាំរបស់អ្នកនៅមូលដ្ឋាន កសាងសមត្ថភាពនៅក្នុងវិស័យស្រាវជ្រាវកម្ពុជា និងពង្រីកឱកាសសម្រាប់ការចូលរួមគោលនយោបាយប្រកបដោយបរិយាបន្នដូចជា តាមរយៈវេទិកាគោលនយោបាយថ្នាក់ខេត្ត ដែលនឹងនាំយកកិច្ចសន្ទនាទាំងនេះឱ្យកាន់តែជិតស្និទ្ធជាមួយសហគមន៍នៅទូទាំងប្រទេស។

តាមរយៈការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ វេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៥ បានពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធអេកូឡូស៊ីគោលនយោបាយមួយដែលកាន់តែមានបរិយាបន្ន ផ្អែកលើទិន្នន័យ និងមានការឆ្លើយតប ដែលបម្រើដល់តម្រូវការ និងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាគ្រប់រូប។

# ឧបសម្ព័ន្ធទី១៖ វាគ្មិន វាគ្មិនកិត្តិយស និងអ្នកសម្របសម្រួល



**លោកបណ្ឌិត អាង រស្មី**
អ្នកស្រាវជ្រាវ
*វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

លោកបណ្ឌិត អាង រស្មី គឺជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។ លោកទទួលបានសញ្ញាបត្របណ្ឌិតផ្នែកវិស្វកម្ម ពីវិទ្យាស្ថានបច្ចេកវិទ្យាតូក្យូ ប្រទេសជប៉ុន ដោយមានឯកទេសលើវិស្វកម្មសកលសម្រាប់ការអភិវឌ្ឍ បរិស្ថាន និងសង្គម។ ការស្រាវជ្រាវរបស់លោកផ្តោតសំខាន់លើការប្រែប្រួលអាកាសធាតុ និងបញ្ហាពាក់ព័ន្ធនឹងបរិស្ថាន។ នេះរួមបញ្ចូលទាំងការវាយតម្លៃផលប៉ះពាល់ដែលអាចបង្កឡើងដោយការប្រែប្រួលអាកាសធាតុ និងការប្រែប្រួលការប្រើប្រាស់ដី ទៅលើធនធានទឹក លំហូរទឹក បន្ទុកល្បាប់ និងការប៉ាន់ប្រមាណគុណភាពទឹក ព្រមទាំងការវាយតម្លៃគ្រោះរាំងស្ងួត។ លទ្ធផលនៃការស្រាវជ្រាវរបស់លោកត្រូវបានបោះពុម្ពផ្សាយជាច្រើននៅក្នុងទិនានុប្បវត្តិអន្តរជាតិឈានមុខគេ និងការធ្វើបទបង្ហាញនៅតាមសន្និសីទនានា។ លោកបណ្ឌិត រស្មី មានបទពិសោធ និងជំនាញយ៉ាងទូលំទូលាយក្នុងការធ្វើគំរូម៉ូដែលជលសាស្ត្រ និងការសរសេរកម្មវិធីដោយប្រើប្រាស់សូហ្វវែរផ្សេងៗ។ លោកមានជំនាញក្នុងការកែច្នៃ វិភាគ និងបកស្រាយសំណុំទិន្នន័យធំៗតាមបែបវិទ្យាសាស្ត្រ។ ជំនាញរបស់លោកក៏រួមបញ្ចូលផងដែរនូវកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល និងអាជ្ញាធរជាតិ និងមូលដ្ឋាន ដែលបង្កើតឱ្យមានផលជះតាមវិស័យនានា។ លោកមានភាពស្ទាត់ជំនាញក្នុងការទំនាក់ទំនងអន្តរវប្បធម៌ និងអន្តរវិស័យ។ មុនពេលចូលបម្រើការងារនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា លោកធ្លាប់ធ្វើការជាទីប្រឹក្សាឱ្យក្រុមហ៊ុនវិស្វកម្មឯកជនមួយ ដោយចូលរួមចំណែកដល់ការអភិវឌ្ឍប្លង់មេ សម្រាប់ប្រព័ន្ធរំដោះទឹកក្នុងទីក្រុង។



**លោកជំទាវបណ្ឌិត បូ ច័ន្ទគុលិកា**
អនុរដ្ឋលេខាធិការ នៃក្រសួងអប់រំ
យុវជន និងកីឡា
សមាជិកនៃគណៈកម្មាធិការប្រឹក្សា
ផ្នែកបច្ចេកទេសរបស់កម្មវិធីពន្លក
ចំណេះ

លោកជំទាវបណ្ឌិត បូ ច័ន្ទគុលិកា អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា គឺជាបុគ្គលដ៏សំខាន់នៅក្នុងបរិវត្តកម្មវិស័យអប់រំរបស់ជាតិ។ ជាមួយនឹងសញ្ញាបត្របណ្ឌិតផ្នែកអប់រំពី Flinders University និងបទពិសោធជាងមួយទសវត្សរ៍ក្នុងការស្រាវជ្រាវ និងភាពជាអ្នកដឹកនាំគោលនយោបាយ លោកជំទាវកំពុងសម្រួចគោលនយោបាយអប់រំដែលមានការវាយតម្លៃលទ្ធផល។ លោកជំទាវគឺជាអ្នកឈានមុខគេ ក្នុងការរៀបចំប្រព័ន្ធអប់រំរបស់កម្ពុជាឱ្យស្របនឹងយុគសម័យឌីជីថល តាមរយៈការសហការជាមួយវិស័យនានា ដើម្បីឱ្យការផ្តល់សេវាមានប្រសិទ្ធភាព។ លោកជំទាវស្វែងរកភាពជាដៃគូអន្តរជាតិយ៉ាងសកម្ម ដោយជំរុញកិច្ចសហប្រតិបត្តិការ និងចែករំលែកឧត្តមានុវត្តន៍ សំដៅលើកកម្ពស់វិស័យអប់រំ។ ភាពជាអ្នកដឹកនាំប្រកបដោយចក្ខុវិស័យ និងការប្តេជ្ញាចិត្តរបស់លោកជំទាវចំពោះគោលនយោបាយដែលមានភាពរឹងមាំ មានគោលបំណងបំពាក់បំប៉នសិស្សនិស្សិតកម្ពុជានូវចំណេះដឹង និងជំនាញដែលត្រូវការដើម្បីរីកចម្រើន។



**កញ្ញា ប៊ុន ភូរី**
អនុប្រធាន នៃបណ្ដាញស្ត្រីក្នុង
វិស័យស្រាវជ្រាវ
ទីប្រឹក្សាស្រាវជ្រាវ និងវាយតម្លៃ
លទ្ធផលនៃគម្រោងវេជបូក
*អង្គការសមាគមអភិរក្សសត្វព្រៃ*
*(WCS) - កម្ពុជា*

កញ្ញា ប៊ុន ភូរី បានបញ្ចប់ការសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ (ការស្រាវជ្រាវ) ពី Auckland University ប្រទេសនូវែលសេឡង់។ កញ្ញាក៏មានសញ្ញាបត្រពីរផងដែរ គឺបរិញ្ញាបត្រអប់រំភាសាអង់គ្លេស ពីវិទ្យាស្ថានភាសាបរទេស (IFL) និងបរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ ពីវិទ្យាស្ថានខេមរេដ។ ចំណាប់អារម្មណ៍ស្រាវជ្រាវរបស់កញ្ញា រួមមាន វិជ្ជាជីវៈសិក្សា បញ្ញាសិប្បនិម្មិត(AI) បច្ចេកវិទ្យាអប់រំ បច្ចេកវិទ្យាវិជ្ជាជីវៈ ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចំណុចប្រសព្វនៃសិល្បៈ និងវិទ្យាសាស្ត្រ សហគ្រិនភាពក្នុងវិស័យអប់រំ សេដ្ឋកិច្ចថៃទាំ និងសេដ្ឋកិច្ចបៃតង ចិត្តសាស្ត្រសង្គមនៃថ្នាក់រៀន ការអភិវឌ្ឍជំនាញនាពេលអនាគត ការវាយតម្លៃការសិក្សា និងការបង្រៀន និងការបណ្តុះបណ្តាលប្រកបដោយបរិយាបន្ន។



**លោក ប៊ុន រិទ្ធី**
អ្នកស្រាវជ្រាវវ័យក្មេង
*វេទិកាអនាគត*

ជាជនជាតិដើមភាគតិចទំពួន មកពីភូមិភាគឦសាននៃប្រទេសកម្ពុជា លោក ប៊ុន រិទ្ធី កំពុងសិក្សាជំនាញទំនាក់ទំនងអន្តរជាតិ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ បច្ចុប្បន្នលោកកំពុងបម្រើការងារនៅអង្គការអន្តរជាតិមួយ ដែលផ្តោតលើសិទ្ធិជនជាតិដើមភាគតិច និងបញ្ហា បរិស្ថាន។ លោកក៏ជាអ្នកស្រាវជ្រាវវ័យក្មេងនៅវេទិកាអនាគត ដែលជាស្ថាប័នសិក្សាគោលនយោបាយសាធារណៈឯករាជ្យមួយ ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ ជាកន្លែងដែលលោកសរសេរអំពីបញ្ហាអភិវឌ្ឍន៍ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ក្នុងគោលបំណងផ្តល់ព័ត៌មានដល់សាធារណជនកម្ពុជា និងតស៊ូមតិដើម្បីប្រយោជន៍សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា។



**លោក ច័ន្ទ សុផល**
នាយកប្រតិបត្តិ
*មជ្ឈមណ្ឌលសិក្សា*
*គោលនយោបាយ*

លោក ច័ន្ទ សុផល បច្ចុប្បន្ន ជានាយកប្រតិបត្តិនៃ មជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS) ដែលជាស្ថាប័នសិក្សាគោលនយោបាយកម្ពុជាមួយ  ផ្តល់សេវាស្រាវជ្រាវក្នុងវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ច ជាពិសេស ក្នុងវិស័យកសិកម្ម ការអភិវឌ្ឍជនបទ និងសេដ្ឋកិច្ច។ ក្នុងរយៈពេលជាង ៣០ឆ្នាំកន្លងមកនេះ លោក សុផល បានកាន់តួនាទីជាន់ខ្ពស់នៅក្នុងស្ថាប័នជាច្រើន រួមមាន ធនាគារពិភពលោក គម្រោង HARVEST ដែលទទួលបានមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ  មូលនិធិឯកជនលេអូផាត ឃែបភីថល (Leopard Capital) កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់  និងនេសាទ។  លោកបានធ្វើការសិក្សាស្រាវជ្រាវនិពន្ធឯកសារជាច្រើន និងដឹកនាំបណ្តាញស្រាវជ្រាវនានា រួមមាន សមាគមសេដ្ឋកិច្ចកម្ពុជា (CEA) និងបណ្តាញវិភាគការអភិវឌ្ឍក្នុងតំបន់ (DAN)។ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រផ្នែកសេដ្ឋកិច្ចកសិកម្ម ពី University of London, Imperial College at Wye។ បន្ទាប់ពីលោកបានបញ្ចប់វគ្គសិក្សាបរិញ្ញាបត្រផ្នែកធុរកិច្ចកសិកម្ម ពី University of Queensland, Gatton College និងទទួលបានសញ្ញាបត្រផ្នែកជលសាស្ត្រ ពីវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប។



**លោក ឈុន សុភ័ណ្ឌ**
មន្ត្រីជាន់ខ្ពស់បច្ចេកទេសមុខរបរ
និងចិញ្ចឹមជីវិត
*អង្គការទស្សនៈពិភពលោក*

លោក ឈុន សុភ័ណ្ឌ គឺជាមន្ត្រីជាន់ខ្ពស់បច្ចេកទេសមុខរបរ និងចិញ្ចឹមជីវិត នៃអង្គការទស្សនៈពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា។ លោកមានបទពិសោធជាង ១០ឆ្នាំ ក្នុងការរៀបចំ និងគ្រប់គ្រងកម្មវិធីក្នុងគោលបំណងកាត់បន្ថយភាពអត់ឃ្លាន និងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ដែលងាយរងគ្រោះបំផុត។ លោកមានជំនាញផ្នែកកសិកម្មប្រកបដោយចីរភាព ការអភិវឌ្ឍជនបទ និងទីប្រជុំជន និងបានដឹកនាំគំនិតផ្តួចផ្តើមដោយប្រើប្រាស់ជំនាញទាំងនេះ ដើម្បីឆ្លើយតបចំពោះភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងអសន្តិសុខស្បៀងក្នុងចំណោមសហគមន៍ជនបទដែលមិនសូវទទួលបានការយកចិត្តទុកដាក់បំផុតរបស់កម្ពុជា។ លោក សុភ័ណ្ឌ ទទួលបានសញ្ញាបត្រផ្នែកកសិកម្ម និងត្រូវបានបញ្ជាក់ទទួលស្គាល់ជាគ្រូបង្គោលផ្នែកផែនការអាជីវកម្ម កសិ-អេកូឡូស៊ី CAM-GAPជីវចម្រុះ និងPPB។ លោកបានធ្វើការយ៉ាងទូលំទូលាយ ជាមួយអង្គការអន្តរជាតិ ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអភិវឌ្ឍសហគមន៍ដែលមានភាពធន់។



**លោក ជា ដារ៉ា**
ប្រធានកម្មវិធី
*វេទិកាអនាគត*

លោក ជា ដារ៉ា បានបញ្ចប់ការសិក្សា ពីវិទ្យាស្ថានភាសាបរទេស (IFL) លើជំនាញបរិញ្ញាបត្រអប់រំផ្នែកបង្រៀនភាសាអង់គ្លេសជាភាសាបរទេស។ លោកក៏បានឈ្នះពានរង្វាន់និស្សិតស្រាវជ្រាវឆ្នើម ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ផងដែរ។ បច្ចុប្បន្ន លោកបម្រើការងារនៅវេទិកាអនាគត ជាប្រធានកម្មវិធីនៃកម្មវិធីសហគមន៍អ្នកស្រាវជ្រាវ។ លោកមានការចាប់អារម្មណ៍លើវិស័យអប់រំសិក្សាពេញមួយជីវិត និងអនាគតនៃការងារ និងការអភិវឌ្ឍជំនាញ។ គម្រោងស្រាវជ្រាវគោលនយោបាយចុងក្រោយរបស់លោក ផ្តោតលើការអប់រំនាពេលអនាគតរបស់កម្ពុជា ក្រោមប្រព័ន្ធអេកូឡូស៊ីនៃការសិក្សាពេញមួយជីវិត និងថ្នាក់រៀនអនាគត។



**លោកបណ្ឌិត អ៊ា ដារិទ្ធ**
ប្រធាននាយកដ្ឋានអភិរក្ស
និងបុរាណវិទ្យា
*អាជ្ញាធរជាតិព្រះវិហារ*

លោកបណ្ឌិត អ៊ា ដារិទ្ធ បានទទួលសញ្ញាបត្របណ្ឌិតពី Osaka Ohtani University នៅឆ្នាំ២០១០។ លោកបានបញ្ចប់ការសិក្សាបរិញ្ញាបត្រ ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក្នុងរាជធានីភ្នំពេញ នៅឆ្នាំ១៩៩៥ និងទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ពី Kyoto University នៅឆ្នាំ២០០០។ ចាប់តាំងពីឆ្នាំ២០០០ មក លោកបានបម្រើការងារនៅអាជ្ញាធរជាតិអប្សរា និងបង្រៀនប្រវត្តិសេរ៉ាមិកខ្មែរ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ លោកបានសម្របសម្រួលគម្រោងចម្រុះជាច្រើនរវាងអាជ្ញាធរជាតិអប្សរា និងក្រុមការងារអន្តរជាតិជាច្រើនអស់រយៈពេលជាយូរមកហើយ។ ចំណាប់អារម្មណ៍ស្រាវជ្រាវចម្បងរបស់លោក ដារិទ្ធ ផ្តោតលើសេរ៉ាមិកថ្មខ្មែរ ចាប់ពីសតវត្សរ៍ទី៩ ដល់ទី១៥។ លោកបានបោះពុម្ពផ្សាយយ៉ាងទូលំទូលាយលើប្រធានបទនេះ និងបន្តរក្សាចំណាប់អារម្មណ៍លើការផ្លាស់ប្តូរពីសម័យអង្គរ ទៅសម័យកណ្តាលនៃកម្ពុជានៅតំបន់អង្គរ។



**លោក កែវ ដួង**
សាស្ត្រាចារ្យ សាកលវិទ្យាល័យ
ភូមិន្ទភ្នំពេញ និងជាគ្រូបង្គោល
*កម្មវិធីអ្នកស្រាវជ្រាវ*
*ពន្លកចំណេះ (PCRF)*

លោក កែវ ដួង គឺជាបេក្ខជនបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យ Bundeswehr University Munich នៃប្រទេសអាល្លឺម៉ង់ ដោយមានការគាំទ្រពីមូលនិធិ Gerda Henkel។ អស់រយៈពេលជាងមួយទសវត្សរ៍មកហើយ លោកបានបម្រើការងារជាសាស្ត្រាចារ្យ និងបានណែនាំសារណាបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ជាច្រើន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លោកបានបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវដែលត្រួតពិនិត្យដោយអ្នកជំនាញចំនួន ៥ និងសៀវភៅសិក្សាស្រាវជ្រាវមួយក្បាលជាមួយវិទ្យាស្ថានសិក្សាអាស៊ី នៃសាកលវិទ្យាល័យ Chunlalongkorn University ជាការទទួលស្គាល់ការរួមចំណែកខាងផ្នែកសិក្សារបស់លោក។ លោកទទួលបានពានរង្វាន់ Voltaire Prize ឆ្នាំ២០២២ សម្រាប់ «ការអត់ឱន ការយល់ដឹងអន្តរជាតិ និងការគោរពភាពខុសគ្នា» ដោយ Potsdam University ប្រទេសអាល្លឺម៉ង់។



**លោកបណ្ឌិត George Chigas**
សាស្ត្រាចារ្យរង សាកលវិទ្យាល័យ
UMass Lowell

លោកបណ្ឌិត George Chigas គឺជាសាស្ត្រាចារ្យរងផ្នែកខេមរសិក្សា នៅសាកលវិទ្យាល័យ University of Massachusetts Lowell ជាកន្លែងដែលលោកបង្រៀនវគ្គសិក្សាស្ដីពីអក្សរសិល្ប៍ខ្មែរ និងប្រវត្តិសាស្ត្រវប្បធម៌។ លោកទទួលបានសញ្ញាបត្របណ្ឌិតផ្នែកភាសា និងវប្បធម៌អាស៊ីអាគ្នេយ៍ ពីសាលាសិក្សាបូព៌ា និងអាហ្វ្រិក (SOAS) នៃសាកលវិទ្យាល័យឡុងដ៍ និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិក្សាអាស៊ី ពី Cornell University។ លោកគឺជាអ្នកនិពន្ធសៀវភៅ «ទុំទាវ៖ ការបកប្រែ និងការវិភាគអក្សរសិល្ប៍នៃស្នាដៃឯកខ្មែរ»។ បច្ចុប្បន្ន លោកកំពុងរស់នៅក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា។



**លោកស្រី កែវ អនចាន់**
ជនបង្គោលស្ត្រី នៃឃុំសាមឃួយ
ខេត្តស្ទឹងត្រែង

លោកស្រី កែវ អនចាន់ មានអាយុ ៣៩ឆ្នាំរស់នៅភូមិសាមឃួយ ឃុំសាមឃួយ ស្រុកសេសាន ខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា។ ក្នុងនាមជាជនបង្គោលស្ត្រី និងជាប្រធានសហគមន៍នេសាទសាមឃួយ លោកស្រី អនចាន់ បានក្លាយជាអ្នកដឹកនាំដ៏សំខាន់នៅក្នុងសហគមន៍របស់គាត់។ ចាប់តាំងពីឆ្នាំ២០២០ មក លោកស្រី អនចាន់ បានចូលរួមយ៉ាងសកម្មនៅក្នុងការងារសហគមន៍ ដោយលះបង់កម្លាំងកាយចិត្តដើម្បីកែលម្អជីវភាពរស់នៅរបស់មនុស្សជុំវិញខ្លួន។ លោកស្រីបានចូលរួមវគ្គបណ្ដុះបណ្ដាលផ្សេងៗ ដោយផ្ដោតលើការស្រាវជ្រាវដែលមានមូលដ្ឋានក្នុងសហគមន៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ផែនការគ្រប់គ្រងសហគមន៍នេសាទ និងបញ្ហាសង្គម និងយេនឌ័រ។ បទពិសោធទាំងនេះបានផ្ដល់ឱ្យគាត់នូវជំនាញចាំបាច់ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលសហគមន៍របស់គាត់កំពុងជួបប្រទះ។ លោកស្រី អនចាន់ ដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន និងមានជំនាញផ្នែកគ្រប់គ្រង និងអភិរក្សធនធានជលផល។ លោកស្រីចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការភូមិ និងឃុំ ដោយធានាថាសំឡេងរបស់សមាជិកសហគមន៍ត្រូវបានស្ដាប់ឮ។ ការរួមចំណែកដ៏សំខាន់បំផុតមួយរបស់លោកស្រី គឺសមត្ថភាពក្នុងការកៀរគរស្ត្រីនៅក្នុងសហគមន៍ ដោយលើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងគំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍ និងដោះស្រាយបញ្ហាសហគមន៍បន្ទាន់។ តាមរយៈភាពជាអ្នកដឹកនាំរបស់លោកស្រី លោកស្រី អនចាន់ បានបំផុសគំនិតមនុស្សជាច្រើន ដោយបណ្ដុះស្មារតីសហការ និងភាពធន់នៅក្នុងភូមិសាមឃួយ។ ការប្ដេជ្ញាចិត្តរបស់លោកស្រីចំពោះការអនុវត្តប្រកបដោយចីរភាព និងការចូលរួមសហគមន៍ បន្តផ្ដល់ផលប្រយោជន៍ដល់ទាំងប្រជាជនមូលដ្ឋាន និងបរិស្ថាន។



**លោក ខាន់ ដូនីវ៉ា**
អ្នកស្រាវជ្រាវ
*វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា*

លោក ខាន់ ដូនីវ៉ា គឺជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដែលការងាររបស់លោកស្ថិតនៅចំណុចប្រសព្វរវាងគោលនយោបាយអាកាសធាតុ ការប្រើប្រាស់ថាមពលក្នុងគ្រួសារ ពាណិជ្ជកម្មឆ្លងដែន និងទិដ្ឋភាពសង្គមនៃការប្រែប្រួលអាកាសធាតុ។ លោកមានបទពិសោធទូលំទូលាយក្នុងការរៀបចំការស្រាវជ្រាវ និងបានដឹកនាំការសិក្សាដែលមានការវាយតម្លៃលទ្ធផលលើប្រធានបទដូចជា គំរូនៃការប្រើប្រាស់ហ្គាសរាវ ទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុក និងសក្តានុពលពាណិជ្ជកម្មកសិកម្មឆ្លងដែន។ លើសពីនេះ ជំនាញរបស់លោកស្ថិតនៅក្នុងការជំរុញប្រព័ន្ធកសិកម្មប្រកបដោយចីរភាព ការជំរុញនវានុវត្តន៍កសិកម្ម ការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់តម្លៃ និងការបង្កើនប្រសិទ្ធភាពធនធាន។ លោកមានចំណាប់អារម្មណ៍ជាពិសេសលើសេដ្ឋកិច្ចបរិស្ថាន និងយុទ្ធសាស្ត្រសេដ្ឋកិច្ចចក្រា ដែលផ្តោតលើភាពធន់នឹងអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព។ លោក ដូនីវ៉ា ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ពីរ គឺផ្នែកសេដ្ឋកិច្ចកសិកម្ម និងធនធាន Kasetsart University ប្រទេសថៃ និងផ្នែកវិទ្យាសាស្ត្រក្សេត្រសាស្ត្រ និងកសិ-ចំណីអាហារ ជាមួយនឹងឯកទេសទីផ្សារ អង្គការ និងគោលនយោបាយ ពី Montpellier SupAgro ប្រទេសបារាំង។ ប្រវត្តិនៃការសិក្សា និងការស្រាវជ្រាវដ៏សម្បូរបែបរបស់លោកបានផ្តល់ឱ្យលោកនូវទស្សនវិស័យសកលស្តីពីកសិកម្មប្រកបដោយចីរភាព និងការគ្រប់គ្រងធនធានបរិស្ថាន។



**ឯកឧត្តម យឹម ហ៊ីណាង់**

អនុរដ្ឋលេខាធិការ *នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*
សមាជិកនៃគណៈកម្មាធិការប្រឹក្សាផ្នែកបច្ចេកទេសរបស់កម្មវិធីពន្លកចំណេះ

ឯកឧត្តម យឹម ហ៊ីណាង់ គឺជាអនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មុនពេលទទួលបានការតែងតាំងក្នុងតំណែងនយោបាយ ឯកឧត្តមធ្លាប់បម្រើការងារជាអភិបាលនៃគណៈអភិបាលស្រុកបន្ទាយស្រី ចាប់ពីឆ្នាំ២០១៩ រហូតដល់ទទួលបានការដំឡើងឋានៈទៅរដ្ឋបាលខេត្ត ជាអភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប នៅឆ្នាំ២០២២។ ឯកឧត្តមធ្លាប់ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យក្នុងស្រុកមួយពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១២ ដោយបង្រៀនវគ្គសិក្សាស្តីពីការគ្រប់គ្រងអាជីវកម្មសហគ្រិនភាព និងភាពជាអ្នកដឹកនាំ។ ឯកឧត្តមគឺជាសហគ្រិនម្នាក់ដែលមានអាជីវកម្មចាប់ផ្តើមថ្មីជាច្រើននៅក្នុងវិស័យបដិសណ្ឋារកិច្ច។ ឯកឧត្តមទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកធុរកិច្ច និងសេដ្ឋកិច្ច និងទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលធុរកិច្ចពីសាកលវិទ្យាល័យនៅសហរដ្ឋអាមេរិក។



**កុច ស្រីមាន**

អ្នកស្រាវជ្រាវវ័យក្មេង
*វេទិកាអនាគត*

កុច ស្រីមាន កំណត់អត្តសញ្ញាណខ្លួនឯងថាមានយេនឌ័រមិនមែនប្រុស ហើយក៏មិនមែនស្រី (Non-binary) និងប្រើប្រាស់សព្វនាមនាង/របស់នាង (She/Her)។ ចំណាប់អារម្មណ៍របស់នាងចំពោះសត្វ និងបរិស្ថាន បានចាប់ផ្តើមតាំងពីកុមារភាព ដោយមានការជំរុញបន្ថែមតាមរយៈការទៅទស្សនាឧទ្យានសួនសត្វភ្នំតាម៉ៅជារៀងរាល់ឆ្នាំ និងការទស្សនាភាពយន្តឯកសារជាច្រើនរាប់មិនអស់។ សព្វថ្ងៃនេះ នាងបានបង្វែរការចង់ដឹងចង់ឃើញពីកុមារភាពនោះ ទៅជាការស្រាវជ្រាវស្តីពីសុខុមាលភាពសត្វ សិទ្ធិសត្វ និងការរៀបចំដែនដីទីក្រុង ដែលចំណាប់អារម្មណ៍នេះកាន់តែស៊ីជម្រៅ តាមរយៈការចូលរួមរបស់នាងជាមួយ វេទិកាអនាគត។ ដោយផ្តោតលើបញ្ហាដែលមិនសូវទទួលបានការយកចិត្តទុកដាក់ ស្រីមាន មានគោលបំណងប្រើប្រាស់ការស្រាវជ្រាវ និងការសរសេរ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ។ នាងក៏ជាសំឡេងនៅពីក្រោយប្លុក «Our Neighbor Blog» ផងដែរ ដែលនាងចែករំលែករឿងរ៉ាវ និងការពិតអំពីសត្វ ដើម្បីបំផុសក្តីមេត្តា និងការយល់ដឹង។



**អ្នកស្រី គ្រី ស៊ុយហៀង**
*នាយិកាប្រតិបត្តិ អង្គការនារីដើម្បីសន្តិភាព*
*សមាជិកក្រុមអ្នកជំនាញផ្នែកយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម របស់កម្មវិធីពន្លកចំណេះ*

អ្នកស្រី គ្រី ស៊ុយហៀង គឺជាអ្នកអនុវត្ត និងជាអ្នកសម្របសម្រួលដែលត្រូវបានទទួលស្គាល់នៅក្នុងវិស័យសមភាពយេនឌ័រ ការកសាងសន្តិភាព និងភាពជាអ្នកដឹកនាំហ្វេមមីនីស។ ក្នុងនាមជានាយិកាប្រតិបត្តិនៃអង្គការនារីដើម្បីសន្តិភាព អ្នកស្រីបានចូលរួមអភិវឌ្ឍវិធីសាស្ត្រចេនាការស្តាប់បែបសម្របសម្រួល (FLD) ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងការស្រាវជ្រាវដែលគិតគូរពីផលប៉ះពាល់នៃជម្លោះ។ អ្នកស្រីគឺជាអ្នកតស៊ូមតិដ៏សកម្មលើអភិបាលកិច្ចប្រកបដោយបរិយាបន្ន និងការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រី និងសហគមន៍ដែលមិនសូវទទួលបានការយកចិត្តទុកដាក់។ អ្នកស្រី ស៊ុយហៀង ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិក្សាសន្តិភាព និងជម្លោះ ពី University of Massachusetts Lowell និងបរិញ្ញាបត្រអប់រំ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។



**លោកបណ្ឌិត ម៉ក់ សិទ្ធិរិទ្ធ**
អ្នកវិទ្យាសាស្ត្រ និងនាយកមជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាន
*វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

លោកបណ្ឌិត ម៉ក់ សិទ្ធិរិទ្ធ នាំមកនូវជំនាញដ៏ស៊ីជម្រៅផ្នែកអភិបាលកិច្ចបរិស្ថាន និងធនធានធម្មជាតិ ជាមួយនឹងសញ្ញាបត្របណ្ឌិតផ្នែកភូមិវិទ្យា ពី University of Singapore ជាកន្លែងដែលលោកទទួលបានមេដាយ វ៉ាំង ហ្គុងវូ (Wang Gungwu Medal) ដ៏មានកិត្យានុភាព។ ការស្រាវជ្រាវក្រោយថ្នាក់បណ្ឌិតរបស់លោកនៅ UNESCO-IHE និង WorldFish បានផ្តោតលើប្រព័ន្ធទឹក និងសៀងអាហារនៅក្នុងអាងទន្លេមេគង្គ។ លោកបណ្ឌិត សិទ្ធិរិទ្ធ គឺជាអ្នកសិក្សាដែលបានបោះពុម្ពផ្សាយស្នាដៃ និងជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។



**លោកសាស្ត្រាចារ្យបណ្ឌិត**
**អ៊ុន លាង**
ព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ
*សាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន លាង គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លោកបានបញ្ចប់ការសិក្សាជំនាញវិទ្យាសាស្ត្រសង្គម និងអាកប្បកិរិយា ពី University of Amsterdam ប្រទេសហូឡង់។ លោកធ្លាប់បម្រើការងារជាប្រធានផ្នែកជំនួយនវានុវត្តន៍ និងអភិវឌ្ឍន៍របស់ធនាគារពិភពលោក ក្រោមគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា (HEQCIP)។ លោកធ្លាប់ជាអ្នកស្រាវជ្រាវ និងជាបញ្ញវន្តកិត្តិយសនៅ Makerere University (អ៊ូហ្គង់ដា) ក្នុងឆ្នាំ២០០៩, សាកលវិទ្យាល័យ Northern Illinois (សហរដ្ឋអាមេរិក) ក្នុងឆ្នាំ២០១១ ជាអ្នកស្រាវជ្រាវនៅ Kyoto University (ជប៉ុន) និង University of Sains Malaysia (ម៉ាឡេស៊ី) ក្នុងឆ្នាំ២០១៩ ជាសាស្ត្រាចារ្យទស្សនកិច្ចនៅ Nagoya University (ជប៉ុន) ក្នុងឆ្នាំ២០២២ និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៅមជ្ឈមណ្ឌលខេមរសិក្សា ក្នុងឆ្នាំ២០១៤ និង២០២៤។ កេរ្តិ៍ឈ្មោះសិក្សារបស់លោកបណ្ឌិត អ៊ុន លាង ត្រូវបានបង្ហាញឱ្យឃើញតាមរយៈការអញ្ជើញឱ្យធ្វើជាវាគ្មិននៅតាមស្ថាប័នសិក្សាល្បីៗ និងវេទិកាអភិវឌ្ឍន៍ ទាំងនៅកម្ពុជា និងអន្តរជាតិ ដូចជាEducation University of Hong Kong Kyoto University, Nagoya University សមាគមអប់រំប្រៀបធៀបនៃអាស៊ី (Comparative Education Society of Asia) ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត មជ្ឈមណ្ឌលខេមរសិក្សា ក្រសួងអប់រំ យុវជន និងកីឡា សមាគមសិក្សាកូរ៉េនៃអាស៊ីអាគ្នេយ៍ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា និងសមាគមសិក្សាអាស៊ី។ លោកបានដឹកនាំក្រុមស្រាវជ្រាវសម្រាប់គម្រោងផ្សេងៗដែលទាក់ទងនឹងការអប់រំ វិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ។ ការស្រាវជ្រាវរបស់លោកផ្តោតលើការអប់រំប្រៀបធៀប គោលនយោបាយអប់រំ និងតួនាទីនៃការអប់រំក្នុងការអភិវឌ្ឍក្រោយជម្លោះ ដោយថ្មីៗនេះបានផ្លាស់ប្តូរការផ្តោតទៅលើវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ។



**នេត ចន្ទមុនិនាថ**
អ្នកស្រាវជ្រាវវ័យក្មេង
*វេទិកាអនាគត*

ជាមួយនឹងសញ្ញាបត្រសេដ្ឋកិច្ចអន្តរជាតិ ពីវិទ្យាស្ថានភាសាបរទេស មុនិនាថ មើលឃើញពិភពលោកថាជាប្រព័ន្ធដែលមានទំនាក់ទំនងគ្នាយ៉ាងស៊ីជម្រៅ ដែលគោលនយោបាយសេដ្ឋកិច្ច និងការសម្រេចចិត្តកំណត់ជីវិតរបស់មនុស្សតាមវិធីដែលមានឥទ្ធិពលជាច្រើន។ បច្ចុប្បន្ននៅកម្មវិធីអាហារូបករណ៍អូស្ត្រាលីនៅកម្ពុជា កញ្ញាមានមោទកភាពក្នុងការគាំទ្របុគ្គលដែលមានទេពកោសល្យ ដើម្បីបន្តការសិក្សាក្រោយឧត្តមសិក្សារបស់ពួកគេនៅប្រទេសអូស្ត្រាលី ដែលជាការវិនិយោគដ៏សំខាន់នៅក្នុងមូលធនមនុស្ស ដើម្បីកសាងការគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនសេដ្ឋកិច្ចដ៏សម្បូររុងរឿងនៅកម្ពុជា។ ដោយមានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើទស្សនាទានកំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន កញ្ញាមានគោលបំណងធ្វើការស្រាវជ្រាវអំពីបញ្ហាប្រឈម និងផលប៉ះពាល់នៃការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចរបស់កម្ពុជា ទៅលើស្ត្រីដែលកំពុងធ្វើការក្នុងកម្លាំងពលកម្មក្រៅប្រព័ន្ធ។



**លោក និត កុសល**
*អ្នកស្រាវជ្រាវ នៃវេទិកាអនាគត និងអ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*
*វេទិកាអនាគត*

លោក និត កុសល គឺជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងជាអ្នកសម្របសម្រួលនៃក្រុមការងារអាស៊ីប៉ូស៊ីហ្វិកនៃគំនិតផ្តួចផ្តើមអ្នកសិក្សាវ័យក្មេង។ មុនពេលបម្រើការងារនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ក្នុងខែកក្កដា ឆ្នាំ២០២៣ លោកបានកាន់តួនាទីផ្សេងៗនៅ វេទិកាអនាគត (២០២០–២០២២) ជាអ្នកស្រាវជ្រាវវ័យក្មេង និងអ្នកសម្របសម្រួលកម្មវិធី។ លើសពីនេះ លោកធ្លាប់ធ្វើការជាអ្នកត្រួតពិនិត្យការងារនៅមូលដ្ឋាន នៅអង្គការ WorldFish និងបានចុះកម្មសិក្សា និងស្ម័គ្រចិត្តជាមួយកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន និងអង្គការ Habitat for Humanity។



**លោកបណ្ឌិត ប៉ ណារិទ្ធ**
អ្នកស្រាវជ្រាវ
*អង្គការភូមិខ្ញុំ*

លោកបណ្ឌិត ប៉ ណារិទ្ធ គឺជាអ្នកជំនាញកម្ពុជាដែលមានជំនាញលើការគ្រប់គ្រង គោលនយោបាយអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានធម្មជាតិ។ លោកទទួលបានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជលផល បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគោលនយោបាយអភិវឌ្ឍន៍ និងការគ្រប់គ្រង និងសញ្ញាបត្របណ្ឌិតផ្នែកគ្រប់គ្រង។ ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយរបស់លោក ផ្តោតលើការអនុវត្តរបស់អង្គភាព ការអភិវឌ្ឍប្រកបដោយចីរភាព បច្ចេកវិទ្យាសិក្សាឌីជីថល និងការអនុវត្តអាជីវកម្មបៃតងនៅកម្ពុជា។ លោកបានចូលរួមចំណែកទាំងក្នុងវិស័យសិក្សាធិការ និងការអភិវឌ្ឍសហគមន៍។ បច្ចុប្បន្ន លោក ណារិទ្ធ បម្រើការជាទីប្រឹក្សារបស់អង្គការភូមិខ្ញុំ ដែលលោកផ្តល់ការណែនាំជាយុទ្ធសាស្ត្រ និងជំនាញបច្ចេកទេស ដើម្បីជំរុញការគ្រប់គ្រងធនធានធម្មជាតិតាមសហគមន៍ ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងគំនិតផ្តួចផ្តើមមុខរបរចិញ្ចឹមជីវិតប្រកបដោយចីរភាពនៅភូមិភាគឦសាន នៃប្រទេសកម្ពុជា។



**លោក រុន សាវុទ្ធ**
អ្នកស្រាវជ្រាវវ័យក្មេង
*វេទិកាអនាគត*

លោក រុន សាវុទ្ធ គឺជាមន្ត្រីរដ្ឋបាលនៃកាកបាទក្រហមកម្ពុជា សាខាខេត្តសៀមរាប។ លោកមានសញ្ញាបត្ររដ្ឋបាលសាធារណៈ និងមានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើអភិបាលកិច្ច បរិវត្តកម្មឌីជីថល និងអនាគតនៃការរក្សាទុកឯកសារ។ សាវុទ្ធ មានគោលបំណងធ្វើទំនើបកម្មប្រតិបត្តិការវិស័យសាធារណៈ តាមរយៈការបង្កើនប្រសិទ្ធភាពរដ្ឋបាល និងការអនុលោមតាមបទប្បញ្ញត្តិដោយប្រើប្រាស់ដំណោះស្រាយឌីជីថល ប្រកបដោយនវានុវត្តន៍។ ការប្តេជ្ញាចិត្តរបស់លោកក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងអភិបាលកិច្ចមិនត្រឹមតែជួយសម្រួលដំណើរការប៉ុណ្ណោះទេ ថែមទាំងជំរុញតម្លាភាព និងគណនេយ្យភាពនៅក្នុងអង្គភាពផងដែរ។ តាមរយៈការបើប្រាស់ឧបករណ៍ឌីជីថលទំនើបៗ សាវុទ្ធ មានចក្ខុវិស័យចង់ឃើញការឆ្លើយតបកាន់តែមានប្រសិទ្ធភាព ចំពោះតម្រូវការមនុស្សធម៌នៅក្នុងតំបន់។



**អ្នកស្រី សាន សុផានី**
*ប្រធាន*
*បណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ*

អ្នកស្រី សាន សុផានី គឺជាអ្នកឯកទេសយេនឌ័រ និងការអភិវឌ្ឍ ដែលមានបទពិសោធជិតមួយទសវត្សរ៍ ជាអ្នកស្រាវជ្រាវ ទីប្រឹក្សា និងសាស្ត្រាចារ្យ។ នៅបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ អ្នកស្រីគឺជាអ្នកគាំទ្រយ៉ាងសកម្មក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងការស្រាវជ្រាវ និងការតាក់តែងគោលនយោបាយ។ នៅក្នុងតួនាទីជាទីប្រឹក្សានៅអង្គការ GIZ អ្នកស្រីជានាឱ្យមានការរៀបចំផែនការឆ្លើយតបនឹងយេនឌ័រនៅក្នុងប្រព័ន្ធអភិបាលកិច្ចជាតិ។ ការងាររបស់អ្នកស្រីផ្តោតលើការជំរុញសមភាពយេនឌ័រ សមធម៌សង្គម និងបរិយាបន្ន (GESEI) ជាពិសេស តាមរយៈវិមជ្ឈការ និងកំណែទម្រង់អភិបាលកិច្ចមូលដ្ឋាន។



**លោកបណ្ឌិត សំ ចាន់ធី**
អ្នកស្រាវជ្រាវជាន់ខ្ពស់
*វិទ្យាស្ថានជាតិសង្គមកិច្ច*

លោកបណ្ឌិត សំ ចាន់ធី បច្ចុប្បន្ន គឺជាប្រធានក្រុមស្រាវជ្រាវ និងជាសាស្ត្រាចារ្យជាន់ខ្ពស់ ហើយមានបទពិសោធវិជ្ជាជីវៈជាង ១៨ឆ្នាំ រួមទាំងនៅក្នុងវិស័យគាំពារសង្គម ការងារសង្គម ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការផ្គត់ផ្គង់ទឹក និងអនាម័យ ការគ្រប់គ្រងធនធានទឹក ថាមពល សេវាកម្មប្រព័ន្ធអេកូឡូស៊ី ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រ ការគ្រប់គ្រងបរិស្ថានទីក្រុង ការគ្រប់គ្រងសំណល់រឹង ការគ្រប់គ្រងគម្រោង និងការតាមដាន និងវាយតម្លៃ និងគណនេយ្យភាពសង្គម និងហិរញ្ញវត្ថុ។ លោកក៏ធ្លាប់ធ្វើការលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ បញ្ហាបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ការគ្រប់គ្រងគម្រោង ការតាំងទីលំនៅថ្មី យេនឌ័រ ការិយាល័យប្រជាពលរដ្ឋ និងសេវាច្រកចេញចូលតែមួយ គោលនយោបាយសាធារណៈ អភិបាលកិច្ចល្អ កំណែទម្រង់រដ្ឋបាល និងការវិចរិលដី។ លោកមានបទពិសោធ ៥ឆ្នាំ ក្នុងការតស៊ូមតិឱ្យមានគោលនយោបាយជាតិនៅក្នុងកិច្ចការពារបរិស្ថាន ការអភិវឌ្ឍវារីអគ្គិសនី ការចូលរួមរបស់សាធារណជន ធនធានរ៉ែ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការទំនាក់ទំនង និងការគ្រប់គ្រងធនធានធម្មជាតិផ្សេងទៀត។ បន្ថែមលើនេះ លោកបណ្ឌិត សំ ចាន់ធី ធ្លាប់ធ្វើការលើការស្រាវជ្រាវធនធានធម្មជាតិ និងបរិស្ថាន ការស្រាវជ្រាវជីវចម្រុះ ការចូលរួមរបស់សហគមន៍ ការស្រាវជ្រាវបែបចូលរួមដោយសហគមន៍ និងការអប់រំ និងបណ្តុះបណ្តាលអំពីបរិស្ថានជាដើម។ លោកក៏មានបទពិសោធយ៉ាងទូលំទូលាយជាទីប្រឹក្សាស្រាវជ្រាវចុះស្រាវជ្រាវ និងក្នុងការគ្រប់គ្រងគម្រោងផងដែរ។



**ឯកឧត្តម សរ បុរីរក្ស**
នាយក នៃវិទ្យាស្ថានជាតិសង្គមកិច្ច
*ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*

ឯកឧត្តម សរ បុរីរក្ស បច្ចុប្បន្ន ជានាយកនៃវិទ្យាស្ថានជាតិសង្គមកិច្ច។ ឯកឧត្តមទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលធុរកិច្ច ជំនាញធុរកិច្ចអន្តរជាតិ និងទីផ្សារ ពី Hawaii Pacific University សហរដ្ឋអាមេរិក រួមជាមួយនឹងវិញ្ញាបនបត្រដែលពាក់ព័ន្ធនឹងធុរកិច្ច និងសាធារណៈជាច្រើនទៀតនៅកម្ពុជា។ ឯកឧត្តមបានចូលបម្រើកងទ័ពដោយមានឋានន្តរស័ក្តិជាមេបញ្ជាការនៅក្រោមក្រសួងការពារជាតិ និងក្រោយមកបានផ្លាស់ប្តូរតួនាទីជាមន្ត្រីរាជការ ដោយបម្រើការជាអភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែងចំនួនពីរអាណត្តិ (៨ឆ្នាំ)។ នៅឆ្នាំ២០២៣ ឯកឧត្តមបានក្លាយជានាយកខុទ្ទកាល័យ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។



**សាយ សៀកឡាយ (ពី)**
អ្នកស្រាវជ្រាវវ័យក្មេង
*វេទិកាអនាគត*

សាយ សៀកឡាយ ដែលត្រូវបានគេស្គាល់ថា «ពី» កំណត់អត្តសញ្ញាណជាបុរសកែភេទ (Transgender man) ដែលមានបទពិសោធយ៉ាងទូលំទូលាយក្នុងការតស៊ូមតិ ដើម្បីសិទ្ធិអ្នកដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ (LGBTQIA+) នៅកម្ពុជា ដោយផ្តោតលើការស្រាវជ្រាវ ការរៀបចំសហគមន៍ និងការផ្តល់សិទ្ធិអំណាច។ លោកក៏ធ្លាប់បម្រើការងារនៅស្ថាប័នសាធារណៈផងដែរ។ ពី មានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើសិទ្ធិអ្នកប្តូរភេទ សុខុមាលភាពសង្គម និងយុត្តិធម៌សង្គម ជាមួយនឹងការចាប់អារម្មណ៍យ៉ាងខ្លាំងលើគោលនយោបាយឌីជីថល។



**លោក សែស អរុណសក្តា**
អ្នកស្រាវជ្រាវ
*វេទិកាអនាគត*

លោក សែស អរុណសក្តា គឺជាស្ថាបត្យករ ដែលទទួលបានការបណ្តុះបណ្តាល និងមានចំណាប់អារម្មណ៍យ៉ាងខ្លាំងឆ្ពោះទៅរកការស្រាវជ្រាវ។ លោកបានបន្តក្តីស្រឡាញ់របស់លោកចំពោះការងារស្រាវជ្រាវ និងបានបញ្ចប់កម្មវិធីអ្នកស្រាវជ្រាវវ័យក្មេងឆ្នាំ ២០២១ របស់វេទិកាអនាគត។ លោកគឺជាអ្នកស្រាវជ្រាវនៅវេទិកាអនាគត ដែលធ្វើការដើម្បីជំរុញគោលនយោបាយទីក្រុង ការរៀបចំផែនការ និងការរចនា ដើម្បីធ្វើឱ្យលំហទីក្រុងមានភាពសមស្របសម្រាប់ការរស់នៅ។ លោកសង្ឃឹមថា បទពិសោធរបស់លោកនៅក្នុងវិស័យរចនា គួបផ្សំជាមួយនឹងជំនាញស្រាវជ្រាវ និងការសរសេរដែលកំពុងលេចធ្លោរបស់លោក នឹងចូលរួមចំណែកដល់កិច្ចពិភាក្សានានា ដើម្បីកសាងប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើង។



**លោក ឡុង សូណា**
អនុប្រធាននាយកដ្ឋាន
ប្រែប្រួលអាកាសធាតុ
*នៃអគ្គនាយកដ្ឋានគោលនយោបាយ*
*និងយុទ្ធសាស្ត្រ*
*ក្រសួងបរិស្ថាន*

លោក ឡុង សូណា គឺជាអនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងជានាយកគម្រោងថ្នាក់ជាតិសម្រាប់ការរៀបចំផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុដំណាល់កាលទី ៣.០ (NDC 3.0)។ លោកមានបទពិសោធយ៉ាងទូលំទូលាយក្នុងការរៀបចំគោលនយោបាយប្រែប្រួលអាកាសធាតុ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងហិរញ្ញប្បទានអាកាសធាតុ។ លោកបានគាំទ្រដោយជោគជ័យដល់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) ក្នុងការទទួលបានមូលនិធិអាកាសធាតុបៃតង (Green Climate Fund) តាមរយៈយន្តការផ្តល់ហិរញ្ញប្បទានដល់វិស័យឯកជន ក្រោមក្របខ័ណ្ឌហិរញ្ញវត្ថុអាកាសធាតុកម្ពុជា។ លោកក៏មានជំនាញខាងហិរញ្ញប្បទានបៃតងផងដែរ។



**លោក ស្រេង សោភ័ណរស្មី**
អគ្គលេខាធិការរង
នៃអគ្គលេខាធិការដ្ឋាន
ក្រុមប្រឹក្សាជាតិគាំពារសង្គម

លោក ស្រេង សោភ័ណរស្មី បច្ចុប្បន្នជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបានចូលបម្រើការងារនៅក្រសួងតាំងពីឆ្នាំ២០១៦ ដោយកាន់តួនាទីជាច្រើន រួមមាន ប្រធាននាយកដ្ឋានគោលនយោបាយ ប្រធាននិងអនុប្រធាននាយកដ្ឋានជំនួយសង្គម និងសេដ្ឋវិទូ។ លោកគឺជាអតីតនិស្សិតនៃកម្មវិធីអាហារូបករណ៍រដ្ឋាភិបាលអូស្ត្រាលី និងទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចអន្តរជាតិ និងអភិវឌ្ឍន៍ ពី Australian National University (ANU)។ លោកក៏ទទួលបានសញ្ញាបត្របរិញ្ញាបត្រចំនួនពីរផងដែរ៖ គឺបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាបត្រផ្នែកទំនាក់ទំនងអន្តរជាតិ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។



**លោក ទូច ស៊ីផាត**
អគ្គនាយករងរដ្ឋបាល
និងហិរញ្ញវត្ថុ
*ក្រសួងអភិវឌ្ឍន៍ជនបទ*

លោក ទូច ស៊ីផាត ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកសង្គមវិទ្យា និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងនាមជាអគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ លោកគឺជាបុគ្គលដ៏សំខាន់នៅក្នុងវិស័យអភិវឌ្ឍន៍ជនបទចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ២០០០។ បទពិសោធដ៏ទូលំទូលាយរបស់លោក រួមមាន ការដឹកនាំគំនិតផ្តួចផ្តើមក្នុងការកសាងសមត្ថភាព ការអភិវឌ្ឍសហគមន៍ ការប្រែប្រួលអាកាសធាតុ និងសមភាពយេនឌ័រ។ លោក ស៊ីផាត បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំគោលនយោបាយជនបទ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ សម្រាប់ការអភិវឌ្ឍជនបទ។ ការងាររបស់លោកក៏រួមមានផងដែរនូវការអនុវត្តគម្រោងអភិវឌ្ឍន៍រួមសម្រាប់សហគមន៍ជនបទ និងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ ហើយលោកបានចូលរួមចំណែកក្នុងការស្រាវជ្រាវលើប្រធានបទនានា ដូចជាឥទ្ធិពលរបស់ចិននៅក្នុងតំបន់មេគង្គ និងការបន្សុំានឹងការប្រែប្រួលអាកាសធាតុក្រោយគ្រោះមហន្តរាយនៅកម្ពុជា និងហ្វីជី។

# ឧបសម្ព័ន្ធទី ២៖ របៀបវារៈ

វេទិកាគោលនយោបាយថ្នាក់ជាតិរបស់កម្មវិធីពន្លកចំណេះ ឆ្នាំ២០២៥

*«ការគាំទ្រគោលនយោបាយប្រកបដោយបរិយាបន្ននៅក្នុងបរិបទប្រែប្រួល៖ ការផ្សារភ្ជាប់ចំណេះដឹង គោលនយោបាយ និងមនុស្សជាតិ»*

កាលបរិច្ឆេទ៖ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥
ទីតាំង៖ សណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ (HYATT REGENCY PHNOM PENH)
ភាសាប្រើប្រាស់៖ ភាសាខ្មែរ ដោយមានការបកប្រែជាភាសាអង់គ្លេស

## ពេលព្រឹក

- **៧:៣០ – ៨:១៥ ព្រឹក** — **ចុះឈ្មោះ**
  ក្រុមការងារពន្លកចំណេះ

- **៨:២៥ – ៨:៣០ ព្រឹក** — **គោរពទង់ជាតិ**
  ពិធីការិនី

- **៨:៣០ – ៨:៤០ ព្រឹក** — **សុន្ទរកថាស្វាគមន៍**
  លោកស្រី ដូហ្គីន អាល់ដា (Dolgion Aldar) នាយិកាកម្មវិធីពន្លកចំណេះនៃអង្គការមូលនិធិអាស៊ី

- **៨:៤០ – ៨:៥០ ព្រឹក** — **សុន្ទរកថាបើកកម្មវិធី**
  ឯកឧត្តម Derek Yip ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំប្រទេសកម្ពុជា

- **៨:៥០ – ៩:២០ ព្រឹក** — **សុន្ទរកថាគន្លឹះ**
  ឯកឧត្តម វង្សី វិស្សុត
  ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- **៩:២០ – ៩:៤០ ព្រឹក** — **ពិធីសម្ពោធឯកសារគោលការណ៍ណែនាំ របស់កម្មវិធីពន្លកចំណេះ**
  *(គុណភាពនៃការស្រាវជ្រាវ និងការពិភាក្សាប្រកបដោយបរិយាបន្ន)*
  - លោកស្រី ដូហ្គីន អាល់ដា (Dolgion Aldar)
  - លោក មាន វិបុលរតនៈ អ្នកសម្របសម្រួលគម្រោងនៃអង្គការជនពិការកម្ពុជា (អ.ព.ក)
  - ក្រុមការងារពន្លកចំណេះ

- **៩:៤០ – ១០:១០ ព្រឹក** — **ការសម្រាកអាហារសម្រន់ និងការទស្សនាការតាំងពិព័រណ៍**
  ភ្ញៀវកិត្តិយស និងអ្នកចូលរួមទាំងអស់

## ពេលថ្ងៃត្រង់

**១០:១០ – ១១:៤០ ព្រឹក**

**កិច្ចពិភាក្សាតុមូលពេញអង្គ**

*តួនាទី និងអនាគតនៃវិស័យស្រាវជ្រាវ កម្ពុជានៅក្នុងការពង្រឹង ដំណើរការគោលនយោបាយប្រកបដោយបរិយាបន្ន*

**អ្នកសម្របសម្រួលកិច្ចពិភាក្សា៖**

- អ្នកស្រី គ្រី ស៊ុយហៀង នាយិកាប្រតិបត្តិ នៃអង្គការនារីដើម្បីសន្តិភាព

**វាគ្មិនកិត្តិយស៖**

- ឯកឧត្តម ឃឹម ហ៊ីណង់ អនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លោកជំទាវបណ្ឌិត បូ ច័ន្ទគុលិកា អនុរដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡា
- លោក ច័ន្ទ សុផល នាយក នៃមជ្ឈមណ្ឌលសិក្សាគោលនយោបាយ
- លោកបណ្ឌិត ម៉ក់ សិទ្ធិរិទ្ធ អ្នកវិទ្យាសាស្ត្រ និងនាយកនៃមជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាននៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
- អ្នកស្រី សាន សុផានី ប្រធាន នៃបណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ (SheThinks Network)

**១១:៤០ ព្រឹក – ១:០០ រសៀល**

**សម្រាកអាហារថ្ងៃត្រង់**

ភ្ញៀវកិត្តិយស និងអ្នកចូលរួមទាំងអស់

## ពេលថ្ងៃត្រង់

**១:០០ – ២:២០ រសៀល**

**ការពិភាក្សាស្របពេលគ្នា ជុំទី១** *(ប្រធានបទដំណាលគ្នាចំនួនពីរ)*

១ក.ការរួមបញ្ចូលការធ្វើចំណាកស្រុក ដែលបណ្តាលមកពីអាកាសធាតុ និងការគាំពារសង្គមទៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

**អ្នកសម្របសម្រួលកិច្ចពិភាក្សា៖**

- លោកបណ្ឌិត អាង រស្មី អ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**អ្នកធ្វើបទបង្ហាញ៖**

- លោក ខាន់ ដូនីរ៉ា អ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
- លោកបណ្ឌិត សំ ចាន់ធី អ្នកស្រាវជ្រាវជាន់ខ្ពស់ នៃវិទ្យាស្ថានជាតិសង្គមកិច្ច

**វាគ្មិនកិត្តិយស៖**

- ឯកឧត្តម សរ បុរីរក្ស នាយក នៃវិទ្យាស្ថានជាតិសង្គមកិច្ច
- លោក ស្រេង សោភ័ណរស្មី អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- លោក ឡុង សូណា អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន

## ពេលថ្ងៃត្រង់

**១:០០ – ២:២០ រសៀល**

**ការពិភាក្សាស្របពេលគ្នា ជុំទី១** *(ប្រធានបទដំណាល គ្នាចំនួនពីរ)*

១ខ. ការអភិវឌ្ឍជនបទប្រកបដោយបរិយាបន្ន៖ ការចូលរួមរបស់សហគមន៍និង ក្រុមសង្គមក្នុងការធ្វើផែនការ និងលទ្ធផលនៃវិនិយោគក្នុងស្រុកដើម្បីជួយដល់តម្រូវការរបស់ក្រុមសង្គមនៅក្នុងបរិបទប្រែប្រួលអាកាសធាតុ

**អ្នកសម្របសម្រួលកិច្ចពិភាក្សា៖**

- លោក ច័ន្ទ សុផល នាយក នៃមជ្ឈមណ្ឌលសិក្សាគោលនយោបាយ

**វាគ្មិនកិត្តិយស៖**

- លោក ទូច ស៊ីផាត អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ
- លោកស្រី កែវ អនចាន់ ជនបង្គោលស្ត្រី នៃឃុំសាមឃួយ
- លោក ឈុន សុភ័ណ្ឌ មន្ត្រីជាន់ខ្ពស់បច្ចេកទេសមុខរបរ និងចិញ្ចឹមជីវិត នៃអង្គការទស្សនៈពិភពលោក
- លោកបណ្ឌិត ប៉ ណារិទ្ធ អ្នកស្រាវជ្រាវ នៃអង្គការភូមិខ្ញុំ (MVi)

**២:២០ – ២:៣០ រសៀល**

**ការសម្រាកអាហារសម្រន់**

ភ្ញៀវកិត្តិយស និងអ្នកចូលរួមទាំងអស់

## ពេលថ្ងៃត្រង់

**២:៣០ – ៣:៥០ រសៀល**

**ការពិភាក្សាស្របពេលគ្នា ជុំទី២** *(ប្រធានបទដំណាលគ្នាចំនួនពីរ)*

២ក. វិទ្យាសាស្ត្រមនុស្ស និងវិទ្យាសាស្ត្រសង្គម ក្នុងទេសភាពស្រាវជ្រាវដែលកំពុងលូតលាស់នៅកម្ពុជា

**អ្នកសម្របសម្រួលកិច្ចពិភាក្សា៖**

- លោកបណ្ឌិត George Chigas, សាស្ត្រាចារ្យរង នៃសាកលវិទ្យាល័យ UMass Lowell

**វាគ្មិនកិត្តិយស៖**

- លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន លាង ព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- លោកបណ្ឌិត អ៊ា ដារិទ្ធ ប្រធាននាយកដ្ឋានអភិរក្ស និងបុរាណវិទ្យា នៃអាជ្ញាធរជាតិព្រះវិហារ
- កញ្ញា ប៊ុន ភូរី អនុប្រធាន នៃបណ្ដាញស្ត្រីក្នុងវិស័យស្រាវជ្រាវ និងជាទីប្រឹក្សាស្រាវជ្រាវ វាយតម្លៃនៃគម្រោងវេជបូក នៃអង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា
- លោក កែវ ដួង សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាគ្រូបង្គោលនៃកម្មវិធីអ្នកស្រាវជ្រាវពន្លកចំណេះរបស់មជ្ឈមណ្ឌលខេមរសិក្សា

**ការពិភាក្សាស្របពេលគ្នា ជុំទី២** *(ប្រធានបទដំណាលគ្នាចំនួនពីរ)*

២ខ. បទបង្ហាញ Lightening Talk៖ «គំនិតគោលនយោបាយតូចសម្រាប់អនាគតរបស់កម្ពុជា»

**អ្នកសម្របសម្រួលកិច្ចពិភាក្សា៖**

- លោក ជា ដារ៉ា ប្រធានកម្មវិធី នៃវេទិកាអនាគត

**វាគ្មិនកិត្តិយស៖**

- សែស អរុណសក្កា អ្នកស្រាវជ្រាវ នៃវេទិកាអនាគត
- នេត ចន្ទមុនិនាថ អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត
- សាយ សៀកឡាយ អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត

- ប៊ុន រិទ្ធី អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត
- រុន សារ៉ុទ្ធ អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត
- និត កុសល អ្នកស្រាវជ្រាវ នៃវេទិកាអនាគត និង វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
- កុច ស្រីមាន អ្នកស្រាវជ្រាវវ័យក្មេង នៃវេទិកាអនាគត

## ពេលថ្ងៃត្រង់

**៣:៥០ – ៤:០០ រសៀល**

**ការសម្រាកអាហារសម្រន់**
ភ្ញៀវកិត្តិយស និងអ្នកចូលរួមទាំងអស់

**៤:០០ – ៤:១០ រសៀល**

**សុន្ទរកថាពេញអង្គ៖** *ការឆ្លុះបញ្ចាំងលើការអនុវត្តគោលនយោបាយប្រកបដោយបរិយាបន្ន*
លោកស្រី ម៉ាក់ មុនីកា នាយិកាប្រតិបត្តិ នៃអង្គការជនពិការកម្ពុជា (អ.ព.ក)

**៤:១០ – ៤:៥០ រសៀល**

**ពិធីពានរង្វាន់បរិយាបន្ន៖**
- ការស្រាវជ្រាវប្រកបដោយបរិយាបន្ន
- ការផ្សព្វផ្សាយប្រកបដោយបរិយាបន្ន
- ការពិភាក្សាប្រកបដោយបរិយាបន្ន

ពានរង្វាន់ដែលផ្តល់ដោយអ្នកស្រី អេង ចាន់ឌី និងអ្នកស្រី សោម ច័ន្ទធីតា តំណាងគណៈកម្មាធិការពានរង្វាន់បរិយាបន្ន

**៤:៥០ – ៥:០០ រសៀល**

**សុន្ទរកថាបិទកម្មវិធី**
លោកស្រី Evangeline Larsen លេខាទី២ ស្ថានទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា

**៥:០០ - ៦:០០ រសៀល**

**កម្មវិធីផ្សារភ្ជាប់បណ្តាញ (Networking Reception)**
ភ្ញៀវកិត្តិយស និងអ្នកចូលរួមទាំងអស់-ស្ម័គ្រចិត្ត

# ឧបសម្ព័ន្ធទី ៣៖ ការផ្សាយព័ត៌មាន

Ponlok Chomnes National Policy Forum 2025 ‘ Inclusive Policymaking in the Age of Uncertainty: Connecting Knowledge, Policy and People’, 05092025-Media_Release-Ponlok-Chomnes-National-Policy-Forum2025.English.pdf

Ponlok Chomnes National Policy Forum 2025 ‘ Inclusive Policymaking in the Age of Uncertainty: Connecting Knowledge, Policy and People’, Australian Embassy, Cambodia | Facebook

កម្ពុជាត្រៀមលក្ខណៈជាស្រេច ដើម្បីដោះស្រាយស្ថានភាពនៅក្នុងសង្គមទៅនឹងការប្រែប្រួលក្នុងពិភពលោក
https://youtu.be/L_EDbfBbGhw?si=amJ6Zenjl7cQAusK ( BTV)

Visoth: Vision 2050 Demands Smarter Policy, Stronger Evidence, Broader Dialogue, https://www.kampucheathmey.com/kpt-english/982608

Cambodia Pushes Evidence-Based Policy at National Forum Backed by Australia, Asia Foundation, https://cambodiainvestmentreview.com/2025/09/05/cambodia-pushes-evidence-based-policy-at-national-forum-backed-by-australia-asia-foundation/

Cambodia Struggles to Build Research Capacity as Evidence-Based Policy Lags Behind. Cambodia Struggles to Build Research Capacity as Evidence-Based Policy Lags Behind | Cambodianess

Beyond STEM: Why Cambodia Can’t Ignore Social Science in Its Drive for Innovation. Beyond STEM: Why Cambodia Can’t Ignore Social Science in Its Drive for Innovation | Cambodianess

វីដេអូ៖ លោក ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា លើកឡើងថា នៅឆ្នាំក្រោយនេះ គណៈប្រតិភូធុរកិច្ចអូស្ត្រាលីនឹងមកកម្ពុជា ដើម្បីស្វែងរកឱកាសវិនិយោគទៅលើវិស័យកសិកម្ម និងកែច្នៃចំណីអាហារនៅកម្ពុជា។
https://www.facebook.com/watch/?v=1121339889525214&rdid=3X9o1HPdCtB88PMK

Australia, Asia Foundation Back Cambodia's Knowledge Sector at National Policy Forum 2025. https://www.khmertimeskh.com/501751994/australia-asia-foundation-back-cambodias-knowledge-sector-at-national-policy-forum-2025/

Australia Envoy Highlights Growth Potential in Cambodia Trade, Calls for Greater investor Awareness. https://www.khmertimeskh.com/501752032/australian-envoy-highlights-growth-potential-in-cambodia-trade-calls-for-greater-investor-awareness/

Cambodia Strengthens Evidence-Based Policymaking at National Forum. https://kiripost.com/stories/cambodia-strengthens-evidence-based-policymaking-at-national-forum

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ វង្សី វិស្សុត ផ្តល់នូវអនុសាសន៍៨ចំណុចក្នុងវេទិកាគោលនយោបាយថ្នាក់ជាតិ ឆ្នាំ២០២៥
https://www.facebook.com/story.php?storyfbid=1205114908313624&id=100064453789645&rdid=qQKDGx5083HGXtY7

From Data to Decision: Australia-Cambodia partnership powering evidence-based policy. https://www.phnompenhpost.com/national/from-data-to-decisions-australia-cambodia-partnership-powering-evidence-based-policy

Australia and The Asia Foundation Support Cambodia's Knowledge Sector. https://asiafoundation.org/australia-and-the-asia-foundation-support-cambodias-knowledge-sector/

Highlights from the Ponlok Chomnes National Policy Forum 2025
https://policypulse.org/events/policy-forum/highlights-from-the-ponlok-chomnes-national-policy-forum-2025/

# ឧបសម្ព័ន្ធទី៤៖ ក្រុមការងារតាក់តែងសៀវភៅណែនាំស្ដីពីការស្រាវជ្រាវ និងគោលការណ៍ណែនាំស្ដីពីការពិភាក្សាប្រកបដោយបរិយាបន្នរបស់កម្មវិធីពន្លកចំណេះ

| | | |
|---|---|---|
| ១ | | **លោកបណ្ឌិត អាង រស្មី**<br>វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |
| ២ | | **កញ្ញា សាក់ ស្រីណុច**<br>វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |
| ៣ | | **កញ្ញា ផាំង ម៉ារ៉ុង**<br>វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |
| ៤ | | **កញ្ញា ស៊ួង សាម៉ីឌី**<br>មជ្ឈមណ្ឌលខេមរសិក្សា (CKS) |
| ៥ | | **លោក សួន ពន្លឺ**<br>មជ្ឈមណ្ឌលខេមរសិក្សា (CKS) |
| ៦ | | **អ្នកស្រី រស់ សុផល្លីន**<br>មជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS) |
| ៧ | | **លោក ជា ដារ៉ា**<br>វេទិកាអនាគត (FF) |
| ៨ | | **កញ្ញា សាយ ពុទ្ធី**<br>វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) |
| ៩ | | **លោក មាន វិបុលរតនះ**<br>អង្គការជនពិការកម្ពុជា (CDPO) |
| ១០ | | **កញ្ញា រីមផាត បុប្ផាត្បូង**<br>អង្គការយេនឌ័រ និងការអភិវឌ្ឍនៅកម្ពុជា (GADC) |
| ១១ | | **អ្នកស្រី ឈុន ចរិយា**<br>អង្គការនារីដើម្បីសន្តិភាព (WPM) |
| ១២ | | **កញ្ញា ជ័យ ម៉ារ៉ាមី**<br>អង្គការមូលនិធិអាស៊ី (TAF) |
| ១៣ | | **កញ្ញា ស៊ឹម សុរ៉ចនា**<br>អង្គការមូលនិធិអាស៊ី (TAF) |

ផ្អែកលើសមិទ្ធផលនៃកម្មវិធីពន្លកចំណេះ ដំណាក់កាលទី១ (២០១៩-២០២៣) ដែលមានគោលបំណងពង្រឹងសមត្ថភាពស្ថាប័នវិស័យស្រាវជ្រាវនៅកម្ពុជា ដើម្បីការស្រាវជ្រាវប្រកបដោយគុណភាព អង្គការមូលនិធិអាស៊ី កំពុងអនុវត្តកម្មវិធីពន្លកចំណេះដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា (២០២៣-២០២៧)។ ក្រោមការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី កម្មវិធីនេះ មានគោលដៅរួមចំណែកដល់ការសម្រេចចិត្តផ្នែកគោលនយោបាយសាធារណៈ ដែលផ្អែកលើទិន្នន័យ និងមានការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន ត្រូវបានអនុវត្ត និងក្លាយជាបទដ្ឋាននៅកម្ពុជា។

## ទំនាក់ទំនងយើងខ្ញុំ

អង្គការមូលនិធិអាស៊ី | ការិយាល័យប្រចាំកម្ពុជា
ផ្ទះលេខ ៥៩ ផ្លូវឧកញ៉ាពេជ្រ (ផ្លូវ ២៤២) រាជធានី
ភ្នំពេញ កម្ពុជា
ponlok.chomnes@asiafoundation.org
+855 (0)23 210 431
https://policypulse.org/

Australian Aid

PONLOK CHOMNES

The Asia Foundation